unesco

equimundo

University of East Anglia Norwich
School of Global Development

# ការលើករបាំងចេញ៖
## សៀវភៅណែនាំស្តីពីសម្ភារៈបង្រៀន និងរៀន ដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ

**កម្ពុជា**



Education 2030

KH/២០២៦/ED/RP/១០៣
រៀបរៀងឡើងដោយការិយាល័យអង្គការយូណេស្កូប្រចាំនៅទីក្រុងភ្នំពេញ ផ្ទះលេខ៣៨ មហាវិថីសម្ដេចសុធារស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

©UNESCO, Equimundo and UEA, ២០២៦

ឯកសារបោះពុម្ពផ្សាយនេះមាននៅក្នុង Open Access ក្រោមអាជ្ញាប័ណ្ណ Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) (http://creativecommons.org/licenses/by-sa/3.0/igo/)។ ការប្រើប្រាស់ខ្លឹមសារនៃឯកសារបោះពុម្ពផ្សាយនេះ មានន័យថាអ្នកប្រើប្រាស់យល់ព្រមគោរពតាមលក្ខខណ្ឌនៃការប្រើប្រាស់ UNESCO Open Access Repository (https://www.unesco.org/en/open-access/cc-sa)។

នាមកត្តាដែលបានប្រើប្រាស់ និងការបង្ហាញសម្ភារៈនៅក្នុងឯកសារបោះពុម្ពផ្សាយនេះទាំងមូល មិនមានន័យថាជាការបញ្ចេញមតិណាមួយរបស់អង្គការយូណេស្កូទាក់ទងនឹងស្ថានភាពស្របច្បាប់របស់ប្រទេស ទឹកដី ទីក្រុង ឬតំបន់ណាមួយ ឬអាជ្ញាធររបស់ខ្លួន ឬទាក់ទងនឹងការកំណត់ព្រំដែន ឬព្រំដែនរបស់ខ្លួនឡើយ។

គំនិត និងមតិដែលបានបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះគឺជារបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីគំនិត និងមតិរបស់អង្គការយូណេស្កូ(UNESCO) ឬUEAឡើយហើយក៏មិនបង្ហាញពីការប្ដេជ្ញាចិត្តរបស់ស្ថាប័នទាំងពីរនេះដែរ។

ទស្សនៈដែលបានបង្ហាញនៅទីនេះមិនតំណាងឱ្យទស្សនៈរបស់មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិដែលមានទីស្នាក់ការកណ្ដាលនៅអាសយដ្ឋាន 45 O'Connor, PO Box / CP 8500 Ottawa ON, Canada K1P 1A4 (IDRC) ឬក្រុមប្រឹក្សាភិបាលរបស់មជ្ឈមណ្ឌលនេះឡើយ។

ស្នាដៃនេះទទួលបានការគាំទ្រពីគំនិតផ្ដួចផ្ដើមភាពជាដៃគូសកលសម្រាប់ការផ្លាស់ប្ដូរចំណេះដឹងអប់រំ និងនវានុវត្តន៍ដែលជាការខិតខំប្រឹងប្រែងរួមគ្នាជាមួយ IDRC ប្រទេសកាណាដា។

រូបថតគម្របៈ © UNESCO Phnom Penh/Yuan Xu

រចនាដោយអង្គការយូណេស្កូ

បោះពុម្ពនៅរាជធានីភ្នំពេញ

# សេចក្ដីសង្ខេប

សម្ភារៈបង្រៀន និងរៀន (TLMs) ដើរតួនាទីយ៉ាងសំខាន់ក្នុងការតម្រឹមតម្រង់ផ្នត់គំនិតអ្នកសិក្សាឱ្យយល់ពីខ្លួនឯង អ្នកដទៃ និងទីតាំងរបស់ពួកគេនៅក្នុងសង្គម។ នៅពេលរៀបចំឡើងប្រកបដោយអត្ថន័យសម្ភារៈបង្រៀន និងរៀនអាចគាំទ្រដល់ការសិក្សាហើយទន្ទឹមនឹងនោះរួមចំណែកលើកកម្ពស់សមភាពយេនឌ័រផងដែរ ។ សៀវភៅណែនាំនេះជួយដល់អ្នកដែលពាក់ព័ន្ធក្នុងការត្រួតពិនិត្យ កែសម្រួល ឬអភិវឌ្ឍសម្ភារៈអប់រំសម្រាប់អ្នកសិក្សាគ្រប់វ័យដើម្បីធានាថាសម្ភារៈទាំងនោះគាំទ្រដល់បរិវត្តកម្មយេនឌ័រ។ មានន័យថាបន្ថែមពីលើការបំពេញគោលបំណងផ្នែកសិក្សាធិការ ឬមុខវិជ្ជារបស់ពួកគេ ឯកសារនេះត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់បទដ្ឋានយេនឌ័រដែលវិជ្ជមាន និងប្រកបដោយសុខុមាលភាព។ ការសម្រេចបាននូវចំណុចនេះទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ទៅលើរបៀបដែលយេនឌ័រត្រូវបានបង្ហាញតាមរយៈអត្ថបទ រូបភាព និងការរចនារួមទាំងបទពិសោធន៍សិក្សាដែលឯកសារនេះបង្កើតឡើងដើម្បីឱ្យអ្នកសិក្សាអាចឆ្លុះបញ្ចាំង និងចោទសួរអំពីបទដ្ឋាន និងផ្នត់គំនិតអវិជ្ជមាននានាជាជាងបន្តអនុវត្តតាមបទដ្ឋាននិងផ្នត់គំនិតទាំងនោះ ។

សៀវភៅណែនាំនេះផ្តល់នូវមូលដ្ឋានហេតុផលច្បាស់លាស់សម្រាប់ការធ្វើសកម្មភាព ការណែនាំជាក់ស្តែងជាជំហានៗ និងឧបករណ៍ងាយស្រួលប្រើប្រាស់ដើម្បីជួយសម្រួលដល់ដំណើរការនៃការវិភាគ កែសម្រួល ឬអភិវឌ្ឍសម្ភារៈប្រកបដោយបរិវត្តកម្មយេនឌ័រនៅក្នុងមុខវិជ្ជានានា ។ ឯកសារនេះក៏ពន្យល់ផងដែរអំពីមូលហេតុដែលការអភិវឌ្ឍសម្ភារៈបង្រៀននិងរៀនជួយគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រមានប្រសិទ្ធភាពបំផុតនៅពេលដាក់បញ្ចូលទៅក្នុងអភិក្រមបរិវត្តកម្មយេនឌ័រដ៏ទូលំទូលាយសម្រាប់ការអប់រំនិងកំណត់នូវចំណុចចាប់ផ្តើមជាច្រើនសម្រាប់ការផ្លាស់ប្តូរបទដ្ឋានយេនឌ័រនៅក្នុងនិងតាមរយៈការអប់រំ។

បទដ្ឋានយេនឌ័រជះឥទ្ធិពល
ដល់បទពិសោធន៍ និងលទ្ធផលអប់រំ
របស់កុមារី និងកុមារា។

**កុមារាចំនួន ១៧%**

បានបោះបង់ការសិក្សាត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ
ក្នុងឆ្នាំសិក្សា ២០២២-២០២៣ នៅកម្ពុជា។

**សម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់
បរិវត្តកម្មយេនឌ័រគឺជាផ្នែកមួយនៃ
ដំណោះស្រាយចំពោះបញ្ហាខាងលើ។**

ការចូលរួមក្នុងការអប់រំ និងលទ្ធផលសិក្សានៅកម្ពុជាមានភាពប្រសើរឡើងសម្រាប់កុមារី។ ស្របពេលជាមួយគ្នានេះ បទដ្ឋានយេនឌ័រ បន្តជះឥទ្ធិពលខុសគ្នាទៅលើលទ្ធផលអប់រំរបស់កុមារី និងកុមារា ដោយមាននិន្នាការថ្មីមួយបង្ហាញពីអត្រាបោះបង់ការសិក្សាខ្ពស់ក្នុងចំណោមកុមារានៅគ្រប់កម្រិតនៃការអប់រំមូលដ្ឋាន។ ដោយពិចារណាពីចំណុចនេះ សៀវភៅណែនាំនេះផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការលើកកម្ពស់ភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាពនៅក្នុងសម្ភារៈបង្រៀន និងរៀនទន្ទឹមគ្នានឹងការបង្កើតសម្ភារៈបង្រៀន និងរៀនដែលជួយគាំទ្រដល់ការសិក្សា និងបំណងប្រាថ្នារបស់អ្នកសិក្សាគ្រប់រូប។

# មាតិកា

**១. សេចក្តីផ្តើម** ....... 1

១.១ គោលបំណងនៃសៀវភៅណែនាំនេះ ....... 1

១.២ ក្រុមគោលដៅ ....... 3

១.៣ បរិបទ ....... 4

១.៤ ផ្នែកនានានៃសៀវភៅណែនាំ ....... 8

**២. តើហេតុអ្វីត្រូវមានសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រ?** ....... 9

២.១ ផលជះនៃបទដ្ឋានយេនឌ័រទៅលើបទពិសោធន៍ និងលទ្ធផលអប់រំ ....... 10

២.២ កត្តាប្រទាក់ក្រឡាគ្នា ....... 11

២.៣ ការដកខ្លួនចេញពីការអប់រំរបស់កុមារា ....... 12

២.៤ បទដ្ឋាននៃភាពជាបុរស និងការចូលរួមក្នុងការអប់រំរបស់កុមារា ....... 14

២.៥ តើអ្វីទៅជាអភិក្រមបរិវត្តកម្មយេនឌ័រចំពោះការអប់រំ? ....... 20

២.៦ តើអ្វីទៅជាសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ? ....... 21

២.៧ ការបង្ហាញយេនឌ័រនៅក្នុងសម្ភារៈបង្រៀន និងរៀនបច្ចុប្បន្ន ....... 25

**៣. ការណែនាំជាក់ស្តែង** ....... 29

៣.១ លក្ខណៈពិសេសនៃសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រ ....... 29

៣.២ ការបញ្ជ្រាបខ្លឹមសារដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រទៅក្នុងមុខវិជ្ជានានា ....... 33

៣.៣ គោលការណ៍នៃការអនុវត្តល្អទាក់ទងនឹងដំណើរការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន ....... 38

៣.៤ ការអនុវត្តទស្សនទានយេនឌ័រចំពោះដំណើរការកែសម្រួល/អភិវឌ្ឍសម្ភារៈបង្រៀន និងរៀន ....... 39

៣.៥ ឧបករណ៍អនុវត្តន៍ជាក់ស្តែងដើម្បីគាំទ្រដល់ការកែសម្រួល និងការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន ....... 43

៣.៦ ការអនុវត្តទស្សនទានបរិវត្តកម្មយេនឌ័រនៅពេលបង្រៀនដោយប្រើប្រាស់សម្ភារៈបង្រៀន និងរៀនដែលមានស្រាប់ ......71

**៤. ការដាក់បញ្ចូលសម្ភារៈបង្រៀន និងរៀនទៅក្នុងអភិក្រមបរិវត្តកម្មយេនឌ័រដ៏ទូលំទូលាយ** ...... 74

៤.១ ហេតុអ្វីបានជាអភិក្រមដ៏ទូលំទូលាយមានសារៈសំខាន់ ...... 74

៤.២ ចំណុចចាប់ផ្តើមសម្រាប់ការផ្លាស់ប្តូរបទដ្ឋានយេនឌ័រនៅក្នុង និងតាមរយៈការអប់រំ ...... 75

**ឯកសារយោង** ......81

# បញ្ជីតារាង ប្រអប់ និងឧបករណ៍

## ប្រអប់


ប្រអប់ទី ១. តើនរណានឹងទទួលបានអត្ថប្រយោជន៍ពីសៀវភៅណែនាំនេះ? ........ 2

ប្រអប់ទី ២. តើអ្វីទៅជាសម្ភារៈបង្រៀន និងរៀន? ........ 3

ប្រអប់ទី ៣. សមភាពយេនឌ័រមានន័យថាសមភាពសម្រាប់ទាំងអស់គ្នា ........ 7

ប្រអប់ទី ៤. កម្រិតជាច្រើនជះឥទ្ធិពលលើរបៀបដែលកុមារ និងយុវជនរៀនសូត្រពីបទដ្ឋានយេនឌ័រ ........ 10

ប្រអប់ទី ៥. យេនឌ័រមានទំនាក់ទំនងជាមួយកត្តាជាច្រើន និងជះឥទ្ធិពលលើបទពិសោធន៍ និងលទ្ធផល ........ 12

ប្រអប់ទី ៦. ឧត្តមគតិនៃភាពជាបុរសដែលលេចធ្លោនៅកម្ពុជា ........ 16

ប្រអប់ទី ៧. ចំណុចចាប់ផ្តើមសម្រាប់ការផ្លាស់ប្តូរបទដ្ឋានយេនឌ័រនៅក្នុង និងតាមរយៈការអប់រំ ........ 21

ប្រអប់ទី ៨. សម្ភារៈបង្រៀន និងរៀនអាចបញ្ចៀសការពង្រឹងបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង និងអាចលើកកម្ពស់បទដ្ឋានយេនឌ័របែបវិជ្ជមាន និងប្រកបដោយសុខុមាលភាព ........ 22

ប្រអប់ទី ៩. ការបង្ហាញយេនឌ័រនៅក្នុងសៀវភៅសិក្សាភាសាអង់គ្លេសនៅកម្ពុជា ........ 26

ប្រអប់ទី ១០. គម្រោងបំណិនជីវិតសម្រាប់សមភាព (LSEP) របស់អង្គការរូមធូរីដកម្ពុជា ........ 31

ប្រអប់ទី ១១. ឱកាសដាក់បញ្ចូលទស្សនទានយេនឌ័រទៅក្នុងដំណើរការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀននៅកម្ពុជា........ 42

ប្រអប់ទី ១២. ចំណុចត្រូវពិចារណានៅពេលប្រើប្រាស់ឧបករណ៍ទាំងនេះ ........ 44

ប្រអប់ទី ១៣. ឯកសារធនធានសម្រាប់គម្រោង "ការលើករបាំងចេញ"........ 79


## តារាង


តារាងទី ១. កត្តាជះឥទ្ធិពលលើការចុះឈ្មោះចូលរៀន និងលទ្ធផលសិក្សារបស់កុមារនៅកម្ពុជា ........ 18

តារាងទី ២. ឧទាហរណ៍នៃរបៀបដែលមុខវិជ្ជាផ្សេងៗអាចជួយឱ្យអ្នកសិក្សាគិតពិចារណាអំពីយេនឌ័រ ........ 34

តារាងទី ៣. ឧទាហរណ៍នៃសកម្មភាពគាំទ្រដល់បរិវត្តកម្មយេនឌ័រដែលអាចអនុវត្តនៅចំណុចចាប់ផ្តើមផ្សេងៗគ្នាក្នុងប្រព័ន្ធអប់រំ ........ 76

## រូបភាព

រូបភាពទី ១. ការចុះឈ្មោះចូលរៀនតាមកម្រិតសិក្សា និងយេនឌ័រ (២០២៤-២០២៥) ....................................13
រូបភាពទី ២. ការចុះឈ្មោះចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា តាមកម្រិតសញ្ញាបត្រ និងយេនឌ័រ (២០២៣-២០២៤) ....................................14

## ឧបករណ៍

ឧបករណ៍ទី ១. ឧបករណ៍សម្រាប់ណែនាំដល់ការវិភាគ និងការកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់ ....... 46
ឧបករណ៍ទី ២. ឧបករណ៍សម្រាប់ណែនាំដល់ការវិភាគ និងការកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់សម្រាប់ភាពជាបុរសបែបវិជ្ជមាន និងប្រកបដោយសុខុមាលភាព .................................... 56
ឧបករណ៍ទី ៣. ឧបករណ៍ណែនាំដល់ការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនដែលជួយគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ.... 62
ឧបករណ៍ទី ៤. បញ្ជីត្រួតពិនិត្យសម្រាប់អ្នកអប់រំក្នុងការប្រើប្រាស់ទស្សនទានបរិវត្តកម្មយេនឌ័ររួមជាមួយនឹងសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់....................................71

# សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំនេះត្រូវបានរៀបរៀងឡើងដោយ Sally Beadle ដោយមានការគាំទ្រពីគំនិតផ្តួចផ្តើមផ្លាស់ប្តូរចំណេះដឹង និងនវានុវត្តន៍នៃកម្មវិធីភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE-KIX) ដែលជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាមួយមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC)។ គម្រោង "ការលើករបាំងចេញ៖ ការអប់រំកុមារាសម្រាប់សមភាពយេនឌ័រ" (២០២៤-២០២៧) មានគោលបំណងឈ្វេងយល់ពីរបៀបដែលបទដ្ឋានយេនឌ័រ នៃភាពជាបុរសដែលតឹងរ៉ឹង និងបង្កគ្រោះថ្នាក់ធ្វើឱ្យខូចដល់ទឹកចិត្តនិងការរៀនសូត្ររបស់កុមារាជាពិសេសក្នុងបរិបទដែលភស្តុតាងបង្ហាញពីនិន្នាការកើនឡើងនៃការដកខ្លួនចេញពីការអប់រំរបស់កុមារា។ គម្រោងនេះក៏ខិតខំកំណត់រកេលក្ខខណ្ឌដែលជំរុញឱ្យមាននិន្នាការនេះ និងគាំទ្រដល់ការអនុវត្ត និងការពង្រីកយុទ្ធសាស្ត្រនានា ដើម្បីជំរុញភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាពនៅក្នុង និងតាមរយៈការអប់រំសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រផងដែរ ។ គម្រោងនេះដឹកនាំដោយអង្គការយូណេស្កូ (UNESCO) និងអនុវត្តក្រោមភាពជាដៃគូជាមួយអង្គការ Equimundo និងសាកលវិទ្យាល័យ East Anglia។

សៀវភៅណែនាំនេះកែសម្រួលចេញពី *សៀវភៅណែនាំជាសកលស្តីពីសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ* សម្រាប់បរិបទប្រទេសកម្ពុជា។ សៀវភៅណែនាំនេះក៏ត្រូវបានរៀបរៀងឡើងចេញពីការពិភាក្សាបច្ចេកទេសយ៉ាងទូលំទូលាយនិងផ្អែកលើសិក្ខាសាលាពិគ្រោះយោបល់រយៈពេលបីថ្ងៃដែលបានរៀបចំឡើងនៅរាជធានីភ្នំពេញ កាលពីខែវិច្ឆិកា ឆ្នាំ២០២៥។ ក្នុងអំឡុងពេលនៃសិក្ខាសាលានោះ អ្នកចូលរួមដែលជាតំណាងមកពីក្រសួងអប់រំ យុវជន និងកីឡា (MoEYS) គណៈកម្មាធិការជាតិ GPE-KIX ប្រចាំនៅកម្ពុជា ក្រសួងកិច្ចការនារី (MoWA) វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) អង្គការរូមធូរីដ (RtR) អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) និងអង្គការសង្គមស៊ីវិល (CSOs) បានផ្តល់មតិកែលម្អ ការយល់ដឹងជាក់ស្តែង និងឧទាហរណ៍នានា។ ជារួមការរួមចំណែករបស់ពួកគេបានជួយធានាថាសៀវភៅណែនាំនេះពិតជាផ្អែកលើស្ថានភាពជាក់ស្តែងនិងភស្តុតាងក្នុងស្រុករបស់ប្រទេសកម្ពុជា។

សៀវភៅណែនាំនេះដកស្រង់ចេញពីរបកគំហើញនៃការសិក្សាស្រាវជ្រាវករណីសិក្សានៅកម្ពុជាស្តីពី *"ការលើករបាំងចេញ ៖ ការដកខ្លួនចេញពីការអប់រំរបស់កុមារា* (Lifting barriers Boys' disengagement from education)" ដែលធ្វើឡើងដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) (ក្រុមអ្នកស្រាវជ្រាវស្នូល ៖ ប៊ុន ភូរី និង ជា ផល ដោយមានការចូលរួមពី ម៉ៅ សូសែងភិរុណ និង រ៉េនី រីនដារី) ដែលផ្តល់នូវការយល់ដឹងថ្មីៗ និងសំខាន់ៗអំពីកត្តាជាច្រើនដែលជះឥទ្ធិពលលើការដកខ្លួនពីការអប់រំរបស់កុមារា។

ការរៀបចំ និងការបញ្ចប់សៀវភៅណែនាំនេះ ទទួលបានអត្ថប្រយោជន៍ពីការរួមចំណែក និងមតិកែលម្អដ៏មានតម្លៃរបស់ ឡាយ វុត្ថា (ការិយាល័យអង្គការយូណេស្កូប្រចាំនៅរាជធានីភ្នំពេញ) Justine Sass និងMatthias Eck (ផ្នែកការអប់រំសម្រាប់បរិយាបន្ន និងសមភាពយេនឌ័រអង្គការយូណេស្កូផ្នែកការអប់រំសម្រាប់ឆ្នាំ២០៣០) រួមជាមួយនឹងការគាំទ្រយ៉ាងសំខាន់ពី Tamara Marti Casado (ផ្នែកការអប់រំសម្រាប់បរិយាបន្ន និងសមភាពយេនឌ័រ អង្គការយូណេស្កូ ផ្នែកការអប់រំសម្រាប់ឆ្នាំ២០៣០)ក៏ដូចជា Esther McFarlane, Zu Xian Lee និង Yuan Xu (ការិយាល័យអង្គការយូណេស្កូ ប្រចាំនៅរាជធានីភ្នំពេញ)៕

# អារម្ភកថា

ការអប់រំដើរតួនាទីស្នូលក្នុងការរៀបចំសង្គមឱ្យមានយុត្តិធម៌ បរិយាបន្ន និងចីរភាព ហើយការអភិវឌ្ឍមូលធនមនុស្សជាអាទិភាពមួយនៃរបៀបវារៈអភិវឌ្ឍជាតិរបស់កម្ពុជាដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ ក្រៅពីការខិតខំជំរុញការពង្រីកឱកាសឱ្យកុមារទទួលបានការអប់រំ កត្តាសំខាន់មួយទៀតគឺគុណភាព និងខ្លឹមសារនៃការសិក្សានៅក្នុងថ្នាក់រៀន។ អ្វីដែលសិស្សរៀន និងបទពិសោធដែលពួកគេទទួលបាននៅក្នុងថ្នាក់រៀនមានឥទ្ធិពលយ៉ាងខ្លាំងលើការគិត ការយល់ដឹង និងទស្សនៈរបស់ពួកគេចំពោះតួនាទីយេនឌ័រ ជាពិសេស សម្ភារៈបង្រៀន និងរៀនមានតួនាទីសំខាន់ក្នុងការបញ្ជូនសារដោយផ្ទាល់ និងដោយប្រយោលថា តើចំណេះដឹងបែបណាត្រូវបានគេចាត់ទុកថាមានតម្លៃ ការអនុវត្តតួនាទីបែបណាដែលសង្គមលើកតម្កើង និងអនាគតប្រភេទណាខ្លះដែលសិស្សអាចស្រមៃឃើញសម្រាប់ខ្លួនឯង។

សៀវភៅណែនាំស្តីពីការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀននិងរៀននេះត្រូវបានរៀបចំឡើងដើម្បីគាំទ្រនិងផ្តល់ការណែនាំជាក់ស្តែងសម្រាប់អ្នកបង្កើតគោលនយោបាយ អ្នកអភិវឌ្ឍកម្មវិធីសិក្សា អ្នកនិពន្ធសៀវភៅសិក្សា វិចិត្រករ អ្នកបោះពុម្ពផ្សាយ គ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូ និងអ្នកពិនិត្យតាមដាន និងវាយតម្លៃនៅកម្ពុជា ដើម្បីកំណត់រក និងដោះស្រាយភាពលម្អៀងយេនឌ័រ ក៏ដូចជាដាក់បញ្ចូលគោលការណ៍បរិវត្តកម្មយេនឌ័រទៅក្នុងដំណើរការនៃការអភិវឌ្ឍ ការជ្រើសរើស និងការប្រើប្រាស់សម្ភារៈបង្រៀននិងរៀន។ សៀវភៅណែនាំនេះសង្កត់ធ្ងន់លើការបង្ហាញជាវិជ្ជមាននិងចម្រុះនៃការប្រើប្រាស់ភាសា រូបភាពប្រកបដោយបរិយាបន្ន ការលើកកម្ពស់តួនាទីនិងទំនាក់ទំនងប្រកបដោយសមធម៌ និងស្របតាមអាទិភាពវិស័យអប់រំជាតិ រួមមានផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ២០២៥-២០២៩ និងគោលនយោបាយស្តីពីការអប់រំបរិយាបន្ន(ឆ្នាំ២០១៨)។ ឯកសារនេះក៏រួមចំណែកផងដែរដល់គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ជាពិសេសគោលដៅទី៤ ស្តីពីការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន និងគោលដៅទី៥ ស្តីពីសមភាពយេនឌ័រ និងគូសបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់សមធម៌ និងបរិយាបន្នជាស្នូលនៃកំណែទម្រង់វិស័យអប់រំជាតិ។

សៀវភៅណែនាំនេះ គឺជាឯកសារយោងជាក់ស្តែង ដែលអាចអនុវត្តបាននៅគ្រប់មុខវិជ្ជា គ្រប់កម្រិតថ្នាក់ ហើយទន្ទឹមនឹងនោះ នៅតែអាចបត់បែនទៅតាមបរិបទក្នុងស្រុកនិងការប្រែប្រួលនៃតម្រូវការ។ ក្រសួងអប់រំ យុវជន និងកីឡា សូមលើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំឱ្យខិតខំប្រើប្រាស់សៀវភៅណែនាំនេះ ទៅតាមតួនាទីរៀងៗខ្លួននិងសហការគ្នាដើម្បីធានាថាសម្ភារៈបង្រៀន និងរៀនរួមចំណែកដល់ការជំរុញការអប់រំប្រកបដោយបរិវត្តកម្មយេនឌ័រ។ តាមរយៈការប្តេជ្ញាចិត្តរួមគ្នានិងការធ្វើសកម្មភាពជាប់លាប់ យើងពិតជាអាចធានាបានថាការអប់រំនឹងផ្តល់អំណាចដល់អ្នកសិក្សាគ្រប់រូបដើម្បីឈោងចាប់សក្តានុពលពេញលេញរបស់ពួកគេនិងរួមចំណែកប្រកបដោយអត្ថន័យដល់ការអភិវឌ្ឍប្រទេសកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូណេស្កូ សូមសម្តែងការកោតសរសើរចំពោះការចូលរួមយ៉ាងសកម្ម និងការគាំទ្ររបស់មន្ត្រីក្រសួងអប់រំ យុវជន និងកីឡាគ្រប់លំដាប់ថ្នាក់ ការគាំទ្រផ្នែកហិរញ្ញវត្ថុពីគំនិតផ្តួចផ្តើមផ្លាស់ប្តូរ

ចំណេះដឹង និងនវានុវត្តន៍នៃកម្មវិធីភាពជាដៃគូសកលសម្រាប់ការអប់រំ តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាមួយមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍអន្តរជាតិ ស្ថាប័ន Equimundo និងសាកលវិទ្យាល័យ East Anglia ព្រមទាំងការរួមចំណែកពីភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ក្នុងការរៀបរៀងសៀវភៅណែនាំនេះឡើង។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០២៦

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**Flavio Bonetti**

តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| CDRI | Cambodia Development Resource Institute | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CSO | Civil Society Organization | អង្គការសង្គមស៊ីវិល |
| DCD | Department of Curriculum Development | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ESP | Education Strategic Plan | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| EMIS | Education Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| GADC | Gender and Development for Cambodia | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា |
| GBV | Gender-based violence | អំពើហិង្សាផ្អែកលើយេនឌ័រ |
| GEM | Global Education Monitoring (Report) | របាយការណ៍ពិនិត្យតាមដានការអប់រំជាសកល |
| GPE | Global Partnership for Education | កម្មវិធីភាពជាដៃគូសកលសម្រាប់ការអប់រំ |
| GRESP | Gender-responsive education sector planning | ការរៀបចំផែនការវិស័យអប់រំដែលឆ្លើយតបនឹងយេនឌ័រ |
| KIX | Knowledge and Innovation Exchange | គំនិតផ្តួចផ្តើមផ្លាស់ប្តូរចំណេះដឹង និងនវានុវត្តន៍ |
| LGBT | Lesbian, Gay, Bisexual and Transgender | ស្ត្រីស្រឡាញ់ភេទដូចគ្នា បុរសស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័រ |
| LSEP | Life Skills for Equality Project | គម្រោងបំណិនជីវិតសម្រាប់សមភាព |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MoWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| NEP | NGO Education Partnership | អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| NER | Net Enrolment Rate | អត្រាពិតនៃការសិក្សា |
| NGO | Non-governmental organization | អង្គការមិនមែនរដ្ឋាភិបាល |
| OECD | Organisation for Economic Co-operation and Development | អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| PDH | Publishing and Distribution House | គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ |
| PISA-D | Programme for International Student Assessment for Development | កម្មវិធីវាយតម្លៃសិស្សអន្តរជាតិសម្រាប់ការអភិវឌ្ឍ |
| RtR | Room to Read | អង្គការរូមធូរីដ |
| SDGs | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SEA-PLM | Southeast Asia Primary Learning Metrics | ការវាស់ស្ទង់ការសិក្សានៅបឋមសិក្សានៅអាស៊ីអាគ្នេយ៍ |
| SOGIE-SC | Sexual Orientation, Gender Identity, Expression and Sex Characteristics | ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងចរិតលក្ខណៈភេទ |
| SRGBV | School-related gender-based | អំពើហិង្សាផ្អែកលើយេនឌ័រនៅសាលារៀន |

| | | |
|---|---|---|
| | violence | |
| SRHR | Sexual and reproductive health and rights | សុខភាព និងសិទ្ធិផ្លូវភេទ និងបន្តពូជ |
| STEM | Science Technology Engineering and Mathematics | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |
| TLM | Teaching and learning material | សម្ភារៈបង្រៀន និងរៀន |
| UNAIDS | Joint United Nations Programme on HIV/AIDS | កម្មវិធីរួមសហប្រជាជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ |
| UNESCO | United Nations Educational, Scientific and Cultural Organization | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ/យូណេស្កូ |
| UNFPA | United Nations Population Fund | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| UNESCO-IBE | UNESCO International Bureau of Education | ការិយាល័យអប់រំអន្តរជាតិនៃអង្គការយូណេស្កូ |
| UNESCO-IIEP | UNESCO International Institute for Educational Planning | វិទ្យាស្ថានអន្តរជាតិសម្រាប់ផែនការអប់រំនៃអង្គការយូណេស្កូ |
| UNESCO-UIS | UNESCO Institute for Statistics | វិទ្យាស្ថានស្ថិតិនៃអង្គការយូណេស្កូ |
| UNGEI | United Nations Girls' Education Initiative | គំនិតផ្តួចផ្តើមការអប់រំកុមារីនៃអង្គការសហប្រជាជាតិ |
| UNICEF | United Nations Children’s Fund | មូលនិធិសហប្រជាជាតិសម្រាប់កុមារ/យូនីសេហ្វ |
| UNPRPD | United Nations Partnership on the Rights of Persons with Disabilities | ភាពជាដៃគូរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនមានពិការភាព |
| UN Women | United Nations Entity for Gender Equality and the Empowerment of Women | ទីភ្នាក់ងារអង្គការសហប្រជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី |
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| WHO | World Health Organization | អង្គការសុខភាពពិភពលោក |

# សទ្ទានុក្រមពាក្យគន្លឹះ[1]

**ភេទជីវសាស្ត្រ** (Biological sex) សំដៅលើលក្ខណៈជីវសាស្ត្រដែលបែងចែកមនុស្សជាភេទប្រុស ភេទស្រី និងអន្តរភេទ (UNESCO, 2022b)។

**ការដកខ្លួនចេញពីការអប់រំរបស់កុមារា** (Boys' disengagement from education) គឺជាបញ្ហាពាក់ព័ន្ធនឹងយេនឌ័រដែលរងឥទ្ធិពលពីបទដ្ឋានសង្គម និងទស្សនទាននៃភាពជាបុរស ដែលអាចជំរុញឱ្យកុមារាមួយចំនួនមិនផ្តល់តម្លៃ ឬដកខ្លួនចេញពីការសិក្សា។ កត្តាគ្រួសារ កត្តាសហគមន៍ កត្តាប្រទេស កត្តាសេដ្ឋកិច្ច និងកត្តានៅកម្រិតសាលារៀនអាចជះឥទ្ធិពលលើការដកខ្លួនចេញបែបនេះ។ វាអាចស្តែងឡើងក្នុងទម្រង់ជាការខ្វះចំណាប់អារម្មណ៍ ការមិនសូវចូលរួម អវត្តមាន ការមិនសូវខំប្រឹងរៀនសូត្រ ហើយសម្រាប់កុមារាមួយចំនួន គឺការបោះបង់ការសិក្សា ឬការធ្លាប់ឈប់រៀន (UNESCO, 2022c)។

**កម្មវិធីសិក្សា** (Curriculum) គឺកម្រងសកម្មភាពទាក់ទងនឹងការរចនា ការរៀបចំ និងការធ្វើផែនការនៃសកម្មភាពអប់រំ ឬសកម្មភាពបណ្តុះបណ្តាល រួមទាំងការកំណត់គោលបំណងសិក្សា ខ្លឹមសារ គោលវិធី (រួមទាំងការវាយតម្លៃ) និងសម្ភារៈ។ និយាយឱ្យសាមញ្ញ វាគឺជាការពណ៌នាអំពីអ្វី ហេតុអ្វី របៀបណា និងពេលណាដែលសិស្សគួររៀន (UNESCO-IBE, 2013; UNESCO-IIEP, n.d.)។

**ការរើសអើង** (Discrimination) គឺជាការប្រព្រឹត្តមិនសមរម្យ ឬការបែងចែកតាមអំពើចិត្ត ដោយផ្អែកលើពូជសាសន៍ ភេទ សាសនា សញ្ជាតិ ពិការភាព អាយុ ឬស្ថានភាពផ្សេងៗទៀតរបស់មនុស្ស (UNESCO, 2022b)។

**យេនឌ័រ** (Gender) សំដៅលើតួនាទី គុណលក្ខណៈ អាកប្បកិរិយា អត្តសញ្ញាណ និងការរំពឹងទុកដែលត្រូវបានកំណត់ក្នុងវប្បធម៌ ដែលផ្សារភ្ជាប់ទៅនឹងភាពជាបុរស ឬភាពជាស្ត្រីនៅក្នុងបរិបទណាមួយ។ យេនឌ័រជះឥទ្ធិពលលើរបៀបដែលមនុស្សធ្វើសកម្មភាព និងប្រាស្រ័យទាក់ទងគ្នា ព្រមទាំងការបែងចែកអំណាច និងធនធាននៅក្នុងទំនាក់ទំនង និងសង្គម (UNESCO, 2022b)។

**ការវិភាគយេនឌ័រ** (Gender analysis) គឺជាលំហាត់វាយតម្លៃមួយដើម្បីស្វែងយល់ពីភាពខុសគ្នា និងភាពស្រដៀងគ្នារវាងមនុស្សដែលមានយេនឌ័រខុសៗគ្នា ទាក់ទងនឹងបទពិសោធន៍ ចំណេះដឹង លក្ខខណ្ឌ/ស្ថានភាព តម្រូវការ លទ្ធភាពទទួលបាន និងការគ្រប់គ្រងលើធនធាន និងលទ្ធភាពទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍ ព្រមទាំងអំណាចក្នុងការសម្រេចចិត្ត (UNESCO, 2022b)។

**ការយល់ដឹងពីយេនឌ័រ** (Gender-aware) មានន័យថាជាការដឹងថាមានបញ្ហា ភាពខុសគ្នា និងវិសមភាពរវាងកុមារា និងកុមារី បុរស និងស្ត្រី (UNESCO, 2022b)។

**អំពើហិង្សាផ្អែកលើយេនឌ័រ** (GBV) សំដៅលើអំពើហិង្សាដែលបណ្តាលឱ្យមាន ឬងាយនឹងបណ្តាលឱ្យមានគ្រោះថ្នាក់ឬការឈឺចាប់(ព្យសនកម្ម) ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តទៅលើនរណាម្នាក់ដោយផ្អែកលើការរើសអើងយេនឌ័រ ការរំពឹងទុកលើតួនាទីយេនឌ័រ និង/ ឬផ្នត់គំនិតយេនឌ័រ ឬដោយផ្អែកលើស្ថានភាពអំណាចខុសគ្នាដែលទាក់ទងនឹង

[1] សទ្ទានុក្រមនេះផ្អែកលើប្រភពដែលបានលើកឡើង និងមតិកែលម្អដែលទទួលបានពីអ្នកចូលរួមក្នុងការពិគ្រោះយោបល់ថ្នាក់ជាតិ។

យេនឌ័រ (UNESCO, 2022b)។

**ភាពលម្អៀងយេនឌ័រ** (Gender bias) គឺជាទំនោរក្នុងការចូលចិត្ត ឬផ្តល់អាទិភាពដល់យេនឌ័រណាមួយជាងយេនឌ័រមួយទៀត (UNESCO, 2022b)។

**ការគ្មានទស្សនទានយេនឌ័រ** (Gender blind) គឺជាបរាជ័យក្នុងការកត់សម្គាល់ ទទួលស្គាល់ ឬពិចារណាលើសារៈសំខាន់នៃយេនឌ័រ ក្នុងនាមជាកត្តាដែលជះឥទ្ធិពលលើរចនាសម្ព័ន្ធ និងការរៀបចំជីវិតសង្គម ជីវិតនយោបាយ និងជីវិតសេដ្ឋកិច្ច (UNESCO, 2022b)។

**ភាពចម្រុះនៃយេនឌ័រ** (Gender diversity) គឺជាពាក្យដែលទទួលស្គាល់ថា អត្តសញ្ញាណ និង/ ឬការបង្ហាញអត្តសញ្ញាណរបស់មនុស្សជាច្រើនស្ថិតនៅក្រៅបទដ្ឋានយេនឌ័រទូទៅដែលបែងចែងមនុស្សជាពីរភេទគឺប្រុសនិងស្រី (binary gender norms) (UN Women, n.d.)។

**សមភាពយេនឌ័រនៅក្នុងការអប់រំ** (Gender equality in education) មានន័យថា សិទ្ធិទទួលបានការអប់រំរបស់អ្នកសិក្សាទាំងអស់ ត្រូវបានគោរពស្មើៗគ្នា ដោយមិនគិតពីយេនឌ័រឡើយ (UNESCO, 2019b)។

**សមភាពយេនឌ័រតាមរយៈការអប់រំ** (Gender equality through education) សំដៅលើតួនាទីសំខាន់នៃការអប់រំក្នុងការដោះស្រាយបញ្ហាសមភាពយេនឌ័រដ៏ទូលំទូលាយ (UNESCO, 2019b)។

**អព្យាក្រឹតយេនឌ័រ** (Gender-neutral) ត្រូវបានប្រើប្រាស់សម្រាប់ភាសា ការអនុវត្ត ឬអភិក្រម ដែលមិនលម្អៀងទៅរកយេនឌ័រជាក់លាក់ណាមួយ (Oxfam, 2023; UNESCO, 2022b)។

**បទដ្ឋានយេនឌ័រ** (Gender norms)ត្រូវបានគេយល់ថាជាគំនិតស្តីពីរបៀបដែលបុរស និងស្ត្រីគួរប្រព្រឹត្តៈ ការរំពឹងទុក និងស្តង់ដារដែលត្រូវបានកំណត់សម្រាប់យេនឌ័រនីមួយៗនៅក្នុងសង្គម វប្បធម៌ និងសហគមន៍ផ្សេងៗគ្នា។ បទដ្ឋានទាំងនេះអាស្រ័យលើបរិបទ និងពេលវេលាជាក់លាក់ (Cookson et al., 2023; Marcus et al., 2024; Stromquist, 2007)។

**យុគភាពយេនឌ័រនៅក្នុងការអប់រំ** (Gender parity in education) គឺជាសូចនាករនៃសមាមាត្ររវាងកុមារី និងកុមារា ស្ត្រី និងបុរស។ យុគភាពយេនឌ័រសម្រេចបាន នៅពេលដែលមានការបង្ហាញ និងការចូលរួមស្មើគ្នានៃអ្នកសិក្សាទាំងពីរភេទនៅក្នុងការអប់រំ (UNESCO, 2022b)។

**គរុកោសល្យដែលឆ្លើយតបនឹងយេនឌ័រ** (Gender-responsive pedagogy) ត្រូវបានគេយល់ថាជាដំណើរការនៃការបង្រៀន និងរៀន ដែលយកចិត្តទុកដាក់លើតម្រូវការសិក្សាជាក់លាក់របស់អ្នកសិក្សាដែលមានយេនឌ័រផ្សេងៗគ្នា (UNESCO-IIEP, n.d.)។

**ផ្នត់គំនិតយេនឌ័រ** (Gender stereotypes) គឺជាការសន្និដ្ឋានទូទៅបែបសាមញ្ញអំពីគុណលក្ខណៈយេនឌ័រ ភាពខុសគ្នា និងតួនាទីរបស់កុមារី ស្ត្រី កុមារា និងបុរស (UN Women, n.d.)។

**អភិក្រមបរិវត្តកម្មយេនឌ័រ** (Gender-transformative approaches) ដោះស្រាយមូលហេតុឫសគល់នៃវិសមភាពយេនឌ័រ។ អភិក្រមនេះរួមបញ្ចូលគោលនយោបាយ និងគំនិតផ្តួចផ្តើម ដែលមិនត្រឹមតែដោះស្រាយ

តម្រូវការ បំណងប្រាថ្នា សមត្ថភាព និងការរួមចំណែកផ្សេងៗគ្នារបស់មនុស្សដែលមានយេនឌ័រខុសៗគ្នាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការជជែកដេញដោលគោលនយោបាយ និងការអនុវត្តក្នុងពេលបច្ចុប្បន្នដែលមានលក្ខណៈរើសអើង ដើម្បីបង្កើតឱ្យមានការផ្លាស់ប្តូរជាបន្តបន្ទាប់ (UNESCO, 2019b, 2022c)។

**អភិក្រមបរិវត្តកម្មយេនឌ័រចំពោះការអប់រំ** (Gender-transformative approach to education) គឺជាអភិក្រមដែលគ្របដណ្តប់លើគោលនយោបាយ កម្មវិធី និងអន្តរាគមន៍នានា ដើម្បីបង្កើតឱកាសក្នុងការប្រឈមមុខយ៉ាងសកម្មទៅនឹងបទដ្ឋានយេនឌ័រ និងវិសមភាពដ៏ទូលំទូលាយ។ អភិក្រមនេះរួមបញ្ចូលទាំងការលើកកម្ពស់សមភាពយេនឌ័រតាមរយៈកំណែទម្រង់កម្មវិធីសិក្សា និងការបង្រៀន (UNESCO, 2022c)។

**ភាពជាបុរស ដែលតឹងរ៉ឹង និងបង្កគ្រោះថ្នាក់** (Harmful and restrictive masculinities) ត្រូវបានផ្សារភ្ជាប់ទៅនឹងបទដ្ឋានយេនឌ័រដែលលេចធ្លោ (សូមមើល 'ភាពជាបុរសបែបត្រួតត្រា') ដែលបង្ហាញថា កុមារា និងបុរស គួរតែអនុវត្តតាមវិធី 'ត្រឹមត្រូវ' ឬ 'ឧត្តុងឧត្តម' ក្នុងការធ្វើជាបុរស ឬកុមារា។ 'ឧត្តមគតិ' នេះដាក់សម្ពាធលើកុមារា និងបុរស ឱ្យអនុវត្តតាមការរំពឹងទុកមួយចំនួន ដែលជារឿយៗ រួមមានការពឹងផ្អែកលើខ្លួនឯង ការធ្វើខ្លួនឱ្យរឹងមាំ និងការប្រើប្រាស់ភាពគឃ្លើនដើម្បីដោះស្រាយជម្លោះ។ ឧត្តមគតិនេះត្រូវបានបង្កើតឡើងផ្ទុយពីភាពជាស្ត្រី និង/ ឬភាពជាបុរសដែលមិនទទួលបានការយកចិត្តទុកដាក់។ គំនិត និងការអនុវត្តនៃភាពជាបុរសបែបនេះ បង្កគ្រោះថ្នាក់ដល់កុមារី និងស្ត្រី តាមរយៈការគាំទ្រដល់ឯកសិទ្ធិរបស់បុរសមកលើស្ត្រី។ ឧត្តមគតិនេះក៏បង្កគ្រោះថ្នាក់ផងដែរដល់កុមារា និងបុរស ពេលគឺពួកគេស្ថិតក្រោមការរំពឹងទុកដ៏តឹងរ៉ឹងនៃភាពជាបុរស ដែលរឹតត្បិតសេរីភាពរបស់ពួកគេក្នុងការបង្ហាញអារម្មណ៍ ស្វែងរកជំនួយ ឬងាកចេញពីបទដ្ឋាននៃភាពជាបុរសដែលលេចធ្លោ (Heilman et al., 2017; UNESCO, 2022c; UNESCO-IBE, 2013; WHO, 2019)។

**ភាពជាបុរសបែបត្រួតត្រា** (Hegemonic masculinity) គឺជាទម្រង់នៃភាពជាបុរសដែលលេចធ្លោនៅក្នុងវប្បធម៌ ដែលជាទូទៅត្រូវបានគេចាត់ទុកថាជាវិធី 'ត្រឹមត្រូវ' ឬ 'ឧត្តុងឧត្តម' ក្នុងការធ្វើជាបុរស ឬកុមារា។ ក្នុងបរិបទជាច្រើន ឧត្តមគតិនេះកំណត់ឱ្យបុរស និងកុមារា មានប្រៀបជាងស្ត្រី និងកុមារី ដែលបង្កផលវិបាកអវិជ្ជមានដល់បុរស ស្ត្រី កុមារា និងកុមារី (Connell, 2020; Marcus et al., 2024)។

**កម្មវិធីសិក្សាកំបាំង ឬកម្មវិធីសិក្សាបង្កប់** (Hidden curriculum) សំដៅលើបទដ្ឋាន គុណតម្លៃ ឥរិយាបថ និងសារ ដែលសិស្សរៀននៅសាលា នៅក្រៅកម្មវិធីសិក្សាផ្លូវការ។ កម្មវិធីសិក្សាទាំងនេះត្រូវបានផ្ទេរទាំងដោយដឹងខ្លួន និងដោយមិនដឹងខ្លួន តាមរយៈលោកគ្រូ អ្នកគ្រូ ថ្នាក់គ្រប់គ្រងសាលា មិត្តភក្តិ ការអនុវត្តនៅសាលារៀន គោលនយោបាយ និងវប្បធម៌ដ៏ទូលំទូលាយនៅក្នុងសាលារៀន។ កម្មវិធីសិក្សាបែបនេះគូសបញ្ជាក់ថា ការរៀនសូត្រងឥទ្ធិពលពីបរិយាកាសសង្គម និងវប្បធម៌ដ៏ទូលំទូលាយ ដែលដំណើរការបង្រៀន និងរៀនប្រព្រឹត្តទៅ (Marcus et al., 2024; UNESCO-IBE, 2013)។

**ការអប់រំបរិយាបន្ន** (Inclusive education) គឺជាដំណើរការនៃការពង្រឹងសមត្ថភាពប្រព័ន្ធអប់រំ ដើម្បីគ្របដណ្តប់ទៅដល់ និងរួមបញ្ចូលសិស្សទាំងអស់ដោយមិនគិតពីពិការភាព ឬកត្តាផ្សេងទៀតឡើយ (UNESCO, 2017)។

**ភាពប្រទាក់ក្រឡាគ្នា** (Intersectionality) សំដៅលើរបៀបដែលទិដ្ឋភាពផ្សេងៗនៃអត្តសញ្ញាណរបស់មនុស្ស ដូចជា យេនឌ័រ អាយុ ពិការភាព ជាតិពន្ធុ ភូមិសាស្ត្រ ឬស្ថានភាពសេដ្ឋកិច្ចសង្គម មានទំនាក់ទំនងជាមួយគ្នាក្នុងការជះឥទ្ធិពលលើបទពិសោធន៍ និងលទ្ធភាពទទួលបានអំណាច ឱកាស និងសិទ្ធិរបស់ពួកគេ។ ពាក្យនេះទទួលស្គាល់ថាមនុស្សអាចប្រឈមមុខនឹងការរើសអើង និងការផាត់ចេញពីសង្គមក្នុងទម្រង់ចម្រុះ និងត្រួតគ្នា (Crenshaw, 2019; Marcus et al., 2024; UN Women and UNPRPD, 2022; UNESCO, 2022c)។

**អន្តរភេទ** (Intersex) គឺជាពាក្យដែលប្រើដើម្បីពណ៌នាអំពីមនុស្ស ដែលអាចមានលក្ខណៈជីវសាស្ត្រនៃភេទទាំងពីរ ឬមនុស្សដែលលក្ខណៈជីវសាស្ត្ររបស់ពួកគេមិនស្របតាមការសន្មតរបស់សង្គមអំពីអ្វីដែលកំណត់ថាជាប្រុស ឬស្រី។ មនុស្សអន្តរភេទអាចកំណត់អត្តសញ្ញាណខ្លួនឯងជាប្រុស ស្រី ឬមិនមែនប្រុស ហើយក៏មិនមែនស្រី (Oxfam, 2023)។

**ភាពជាបុរស** (Masculinities) ឬអត្តសញ្ញាណរបស់បុរស អាចសំដៅលើអត្តសញ្ញាណ បទដ្ឋានសង្គម និងឥទ្ធិពលនៃអំណាច ដែលមនុស្សផ្សារភ្ជាប់ទៅនឹងបុរស និងកុមារា។ ភាពជាបុរសត្រូវបានបង្កើតឡើងដោយសង្គម រៀនសូត្រ និងពង្រឹង តាមរយៈការរំពឹងទុករបស់សង្គមលើរបៀបដែលកុមារា និងបុរសគួរប្រព្រឹត្ត។ នៅក្នុងសង្គមភាគច្រើន ទម្រង់មួយចំនួននៃភាពជាបុរសត្រូវបានចាត់ទុកជាវិធី 'ឧត្តុងឧត្តម' ក្នុងការធ្វើជាកុមារា/បុរស។ 'ភាពជាបុរសបែបត្រួតត្រា' ទាំងនេះកំណត់ស្តង់ដារដែលគេរំពឹងថា កុមារា និងបុរសច្រើនតែអនុវត្តតាម។ ឧទាហរណ៍នៃភាពជាបុរសបែបត្រួតត្រា អាចរួមមានការពឹងផ្អែកលើអត្តសញ្ញាណជា 'អ្នកផ្គត់ផ្គង់' ឬ 'អ្នកការពារ' ភាពគឃ្លើន ឬការមិនបង្ហាញអារម្មណ៍ (បទដ្ឋានសង្គម) ឬការដាក់ឱ្យស្ត្រី និងកុមារីស្ថិតក្រោមបង្គាប់ (ឥទ្ធិពលនៃអំណាច) (Connell, 2020; Ragonese et al., 2019; UNESCO, 2022c)។

**ការស្អប់ខ្ពើមស្ត្រី** (Misogyny) សំដៅលើការស្អប់ ឬការរើសអើងចំពោះស្ត្រី និងកុមារី (Marcus et al., 2024)។

**ភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព** (Positive and healthy masculinities) សង្កត់ធ្ងន់លើទិដ្ឋភាពបែបស្ថាបនាក្នុងអត្តសញ្ញាណនៃភាពជាបុរស។ ពាក្យនេះសង្កត់ធ្ងន់ថាកុមារា និងបុរសទាំងអស់គួរតែមានសេរីភាពក្នុងការបង្ហាញភាពជាបុរសដែលមានលក្ខណៈចម្រុះ ប្រកបដោយការគោរព និងការគាំទ្រ ដោយមិនខ្លាចការផាត់ចេញ ការចំអក ឬអំពើហិង្សា (UN Women, 2016; UNESCO-IBE, 2025)។

**អំពើហិង្សាផ្អែកលើយេនឌ័រនៅសាលារៀន** (SRGBV) សំដៅលើការប្រព្រឹត្ត ឬការគំរាមប្រព្រឹត្តអំពើហិង្សាផ្លូវភេទ អំពើហិង្សារាងកាយ ឬអំពើហិង្សាផ្លូវចិត្ត ដែលកើតឡើងនៅក្នុង និងជុំវិញសាលារៀន ដែលប្រព្រឹត្តឡើងដោយសារតែបទដ្ឋាន និងផ្នត់គំនិតយេនឌ័រ ហើយត្រូវបានជំរុញដោយឌីណាមិកអំណាចមិនស្មើគ្នា (UNESCO and UN Women, 2016)។

**បទដ្ឋានសង្គម** (Social norms) សំដៅលើវិធានក្រៅផ្លូវការ ដែលច្រើនតែមិនមានលក្ខណៈផ្លូវការ និងមិនស្តែងឱ្យឃើញ ដែលណែនាំអំពីរបៀបដែលមនុស្សគួរប្រព្រឹត្តនៅក្នុងក្រុម ឬសង្គម។ មនុស្សច្រើនតែទទួលបានការលើកទឹកចិត្តចំពោះការអនុវត្តតាមបទដ្ឋានទាំងនេះ និងទទួលទណ្ឌកម្មចំពោះការងាកចេញពីបទដ្ឋានទាំងនេះ (Marcus et al., 2024)។

**កម្មវិធីសិក្សាលម្អិត** (Syllabus) គឺជាឯកសារដែលរៀបរាប់ពីគោលបំណង ការជ្រើសរើស និងលំដាប់លំដោយនៃខ្លឹមសារដែលត្រូវលើកមកបង្រៀន របៀបបង្រៀន សម្ភារៈដែលត្រូវប្រើប្រាស់ កិច្ចការ និងសកម្មភាពសិក្សា គោលបំណង ឬលទ្ធផលសិក្សាដែលរំពឹងទុក និងវង្វាយតម្លៃ/ការប៉ាន់ប្រមាណលើវគ្គសិក្សា មេរៀន ឬមុខវិជ្ជាជាក់លាក់ណាមួយ។ ជាញឹកញាប់ ពាក្យនេះត្រូវបានគេប្រើខុស ដោយចាត់ទុកថា វាមានន័យស្មើនឹងពាក្យ 'កម្មវិធីសិក្សា "Curriculum" (UNESCO-IBE, 2013)។

**សម្ភារៈបង្រៀន និងរៀន** (TLMs) ត្រូវបានគេយល់ថាជាឧបករណ៍ និងធនធានដែលប្រើប្រាស់ដោយអ្នកអប់រំដើម្បីគាំទ្រដល់ការរៀបចំកិច្ចតែងការបង្រៀន និងការអនុវត្តការបង្រៀនជាក់ស្តែង និងប្រើប្រាស់ដោយសិស្សនៅក្នុងដំណើរការរៀនសូត្ររបស់ពួកគេ។ សម្ភារៈបង្រៀន និងរៀនរួមបញ្ចូលផលិតផលយ៉ាងទូលំទូលាយ ដូចជាសៀវភៅសិក្សា សៀវភៅលំហាត់ ជំនួយជារូបភាព សៀវភៅរឿង ធនធានឌីជីថល ឬអនឡាញ ឯកសារចែកជូនក្នុងថ្នាក់ និងវង្វាយតម្លៃ (UNESCO-IIEP, n.d.)។

# ១. សេចក្តីផ្តើម

ការអប់រំអាចក្លាយជាកម្លាំងចលករដ៏មានឥទ្ធិពលសម្រាប់សមភាពយេនឌ័រ (Plan International et al., 2021; UNESCO, 2019b, 2022c)។ នៅពេលដែលការអប់រំត្រូវបានរៀបចំឡើង និងផ្តល់ជូនដោយមានការគិតគូរពីសមភាពយេនឌ័រ វាអាចប្រឈមដោះស្រាយបទដ្ឋាន និងផ្នត់គំនិតយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង លើកកម្ពស់បទដ្ឋានយេនឌ័រដែលវិជ្ជមាន និងប្រកបដោយសុខុមាលភាព និងបើកផ្លូវឱ្យមានតួនាទី និងអនាគតកាន់តែទូលំទូលាយសម្រាប់អ្នកសិក្សាគ្រប់លក្ខណៈចម្រុះ។ ក្នុងន័យនេះ សម្ភារៈបង្រៀន និងរៀន (TLMs )ដើរតួនាទីយ៉ាងសំខាន់។ ខ្លឹមសារ ភាសា រូបភាព តួអង្គ និងឧទាហរណ៍ដែលបានបង្ហាញក្នុងសម្ភារៈទាំងនេះជះឥទ្ធិពលលើអ្វីដែលគេចាត់ទុកថាជារឿងធម្មតា អ្វីដែលគួរជាទីប៉ងប្រាថ្នា ឬអ្វីដែលអាចទៅរួច តាមរយៈការរឹតត្បិត ឬការពង្រីករបៀបដែលអ្នកសិក្សាមើលឃើញខ្លួនឯង និងអ្នកដទៃ (Brussino and McBrien, 2022; Cheryan et al., 2025; Makarova et al., 2019; UNESCO, 2022d)។

## ១.១ គោលបំណងនៃសៀវភៅណែនាំនេះ

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងសម្រាប់ជាជំនួយដល់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) និងភាគីពាក់ព័ន្ធផ្សេងទៀតនៅកម្ពុជា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន (TLMs) ក្នុងគោលបំណងធានាថាសម្ភារៈទាំងនេះខិតខំលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្ន។ សៀវភៅណែនាំនេះផ្តល់នូវការណែនាំសម្រាប់អ្នកដែលកំពុងត្រួតពិនិត្យសម្ភារៈបង្រៀននិងរៀនដែលមានស្រាប់ ដោយពិចារណាលើទស្សនៈយេនឌ័រ ដើម្បីវាយតម្លៃថាតើសម្ភារៈទាំងនោះបានពង្រឹងបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹងដែរឬទេ និងដើម្បីណែនាំដល់ការកែសម្រួលនៅពេលចាំបាច់ និងសម្រាប់អ្នកដែលពាក់ព័ន្ធក្នុងការបង្កើតសម្ភារៈថ្មីៗដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងគាំទ្រដល់បរិវត្តកម្មយេនឌ័រ **(ប្រអប់ទី ១)**។ ឧបករណ៍អនុវត្តជាក់ស្តែងនៅក្នុងសៀវភៅណែនាំនេះគាំទ្រដល់ការកែសម្រួល ឬការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនជាក់លាក់ណាមួយ ដូចជា៖ សៀវភៅអត្ថបទសិក្សា សៀវភៅអំណាន/សៀវភៅរឿង សៀវភៅលំហាត់ឬវង្វាយតម្លៃ និងអាចអនុវត្តចំពោះសម្ភារៈបង្រៀន និងរៀនដែលត្រូវបានរៀបចំឡើងសម្រាប់មុខវិជ្ជា កម្រិតសិក្សា និងមជ្ឈដ្ឋានសិក្សាយ៉ាងទូលំទូលាយ **(ប្រអប់ទី ២)**។

សៀវភៅណែនាំថ្នាក់ជាតិនេះត្រូវបានកែសម្រួលចេញពី *សៀវភៅណែនាំជាសកលស្តីពីសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ។* ដំណើរការកែសម្រួលនេះធ្វើឡើងដោយផ្អែកលើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធចម្រុះនៅកម្ពុជាដែលបានផ្តល់ធាតុចូល និងមតិកែលម្អដើម្បីធានាថាសៀវភៅណែនាំថ្នាក់ជាតិនេះឆ្លើយតបនឹងតម្រូវការជាតិ និងផ្អែកលើស្ថានភាពជាក់ស្តែង និងភស្តុតាងក្នុងស្រុក។

**ប្រអប់ទី ១. តើអ្នកណានឹងទទួលបានអត្ថប្រយោជន៍ពីសៀវភៅណែនាំនេះ ?**

| | | |
|---|---|---|
| ក្រុមត្រួតពិនិត្យ និង/ឬកែសម្រួល សម្ភារៈបង្រៀន និងរៀនដែលមានស្រាប់ | ក្រុមអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនថ្មី | អ្នកអប់រំដែលពាក់ព័ន្ធក្នុងការជ្រើសរើស និងការប្រើប្រាស់សម្ភារៈបង្រៀន និងរៀន |
|  |  |  |
| *ឧទាហរណ៍ ការធ្វើបច្ចុប្បន្នភាពសៀវភៅសិក្សា ឧបករណ៍បណ្តុះបណ្តាលគ្រូ ឬធនធានឌីជីថល ដើម្បីពង្រឹងខ្លឹមសារបរិវត្តកម្មយេនឌ័រ។* | *ឧទាហរណ៍ ការរៀបរៀងសៀវភៅសិក្សាថ្មី សៀវភៅលំហាត់ ឬឧបករណ៍វាយតម្លៃ ដែលខិតខំលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្ន។* | *ឧទាហរណ៍ ការកំណត់រក និងការបញ្ចូលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់តាមរបៀបដែលលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្ន។* |

*ប្រភព ៖ អ្នកនិពន្ធ*

### ប្រអប់ទី ២. តើអ្វីទៅជាសម្ភារៈបង្រៀន និងរៀន?

សម្ភារៈបង្រៀន និងរៀន(TLMs)គឺជាធនធាន និងឧបករណ៍ដែលប្រើប្រាស់ដោយអ្នកអប់រំដើម្បីជួយសម្រួលដល់ការបង្រៀន និងលើកកម្ពស់បទពិសោធន៍រៀនសូត្រ។ សម្ភារៈបង្រៀន និងរៀន រួមមានសៀវភៅសិក្សាគោល សៀវភៅលំហាត់ ជំនួយជារូបភាព សៀវភៅរឿង ប្រព័ន្ធផ្សព្វផ្សាយឌីជីថល ឯកសារចែកជូនក្នុងថ្នាក់ ឧបករណ៍វាយតម្លៃ និងសៀវភៅគ្រូ។ សម្ភារៈបង្រៀន និងរៀនមួយចំនួន(ឧ. សៀវភៅសិក្សានៅសាលាឬសាកលវិទ្យាល័យ) អាចត្រូវបានរៀបចំឡើងដើម្បីឱ្យស្របតាមគោលបំណងនៃកម្មវិធីសិក្សា ខណៈសម្ភារៈផ្សេងទៀត (ឧ. អត្ថបទអក្សរសិល្ប៍ដែលត្រូវសិក្សា) ត្រូវបានជ្រើសរើសដោយអ្នកអប់រំ ដើម្បីឆ្លើយតបទៅនឹងគោលដៅរៀនសូត្ររបស់ពួកគេ។ បច្ចុប្បន្ន អ្នកអប់រំកំពុងប្រើប្រាស់ឧបករណ៍ឌីជីថលកាន់តែច្រើនឡើង (ឧទាហរណ៍៖ គេហទំព័រអប់រំ វីដេអូ ថ្នាលសិក្សា និងកម្មវិធីអន្តរកម្ម) ដើម្បីគាំទ្រដល់ការបង្រៀន និងការរៀនសូត្រ។ នេះបង្ហាញទាំងឱកាស និងបញ្ហាប្រឈមសម្រាប់ការធានាថាសម្ភារៈដែលអ្នកសិក្សាប្រើប្រាស់ (ទាំងខ្លឹមសារ និងការរចនា) គាំទ្រដល់បរិវត្តកម្មយេនឌ័រ (Hawkins et al., 2019; Schmidthaler et al., 2023)។




*ប្រភព ៖ អ្នកនិពន្ធ*

## ១.២ ក្រុមគោលដៅ

ក្រុមគោលដៅចម្បងដែលគួរអានសៀវភៅណែនាំនេះ រួមមានអ្នកជំនាញដែលពាក់ព័ន្ធក្នុងការជ្រើសរើស ការត្រួតពិនិត្យ ការវិភាគ ការអភិវឌ្ឍ និងការកែសម្រួលសម្ភារៈបង្រៀន និងរៀន(TLMs)សម្រាប់សាលារៀន និងមជ្ឈដ្ឋានអប់រំផ្សេងទៀតនៅកម្ពុជា។ ក្រុមនេះរួមបញ្ចូលទាំងអ្នកពិនិត្យ និងអ្នកអភិវឌ្ឍកម្មវិធីសិក្សា អ្នកសរសេរឯកសារ អ្នកឯកទេសតាមមុខវិជ្ជា វិចិត្រករ និងអ្នកកែសម្រួល (editor) ដែលរួមចំណែកលើកកម្ពស់គុណភាព និងខ្លឹមសារនៃសម្ភារៈសិក្សានៅទូទាំងមុខវិជ្ជា និងកម្រិតសិក្សាផ្សេងៗគ្នា។ នៅក្នុងបរិបទប្រទេសកម្ពុជា អ្នកជំនាញទាំងនេះភាគច្រើនបម្រើការងារនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ជាពិសេសនៅក្នុងនាយកដ្ឋាន

អភិវឌ្ឍកម្មវិធីសិក្សា(DCD)ដោយពួកគេបំពេញការងារយ៉ាងជិតស្និទ្ធជាមួយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ (PDH)។ អាស្រ័យលើមុខវិជ្ជានីមួយៗ អ្នកជំនាញទាំងនេះក៏អាចមកពីគ្រឹះស្ថានអប់រំផ្សេងៗ ឬអង្គភាពបច្ចេកទេសជំនាញដែលគាំទ្រដល់ការអភិវឌ្ឍកម្មវិធីសិក្សា និងសម្ភារៈបង្រៀន និងរៀនផងដែរ។

សៀវភៅណែនាំនេះក៏មានសារៈសំខាន់ផងដែរចំពោះអ្នកអប់រំដូចជាលោកគ្រូអ្នកគ្រូ ថ្នាក់ដឹកនាំសាលារៀន សាស្ត្រាចារ្យ អ្នកអប់រំ និងគ្រូឧទ្ទេស ដែលមានតួនាទីផ្តល់ការបង្រៀនតាមកម្មវិធីសិក្សា ព្រមទាំងជ្រើសរើស និងប្រើប្រាស់សម្ភារៈបង្រៀន និងរៀននៅក្នុងថ្នាក់រៀន និងកន្លែងបណ្តុះបណ្តាល។

នៅពេលដែលការអភិវឌ្ឍ ឬការកែសម្រួលសម្ភារៈបង្រៀន និងរៀនទទួលបានការគាំទ្រពីស្ថាប័នក្រៅ ឬទីប្រឹក្សាឯករាជ្យ សៀវភៅណែនាំនេះអាចត្រូវបានប្រើប្រាស់ជាឯកសារយោងនៅក្នុងលក្ខខណ្ឌប្រតិបត្តិការ (Terms of reference) ឬកិច្ចព្រមព្រៀងកិច្ចសន្យាការងារ ហើយការងារនេះនឹងជួយធានាថា សម្ភារៈបង្រៀន និងរៀនទាំងអស់ស្របតាមអាទិភាពនៃវិស័យអប់រំជាតិ និងការប្តេជ្ញាចិត្តរបស់ក្រសួងអប់រំ យុវជន និងកីឡាចំពោះសមភាពយេនឌ័រ និងការអប់រំប្រកបដោយបរិយាបន្ន។

## ១.៣ បរិបទ

កិច្ចការនៅក្នុងផ្នែកនេះគឺស្របតាមការប្តេជ្ញាចិត្តរបស់កម្ពុជា ក្រោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) រួមមានចំណុចដៅ ៤.៧ ដែលអំពាវនាវឱ្យប្រទេសនានាធានាថា អ្នកសិក្សាទាំងអស់ទទួលបានចំណេះដឹង និងបំណិន ដែលត្រូវការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិមនុស្ស និងចំណុចដៅ ៤.៥ ដែលខិតខំលុបបំបាត់វិសមភាពយេនឌ័រនៅក្នុងការអប់រំ និងធានាថា ក្រុមងាយរងគ្រោះមានលទ្ធភាពទទួលការអប់រំដូចក្រុមផ្សេងទៀតដែរ។ ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងដ៏ទូលំទូលាយ ដើម្បីដោះស្រាយវិសមភាពយេនឌ័រនៅក្នុង និងតាមរយៈការអប់រំកិច្ចការនេះទាមទារឱ្យមានសម្ភារៈបង្រៀន និងរៀន(TLMs)ខិតខំលើកកម្ពស់សមភាព និងបរិយាបន្ន។

កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិក្នុងការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័របន្សុីគ្នានឹងការប្តេជ្ញាចិត្តដ៏ទូលំទូលាយរបស់កម្ពុជាក្នុងផ្នែកគោលនយោបាយ និងការរៀបចំផែនការនៅទូទាំងវិស័យអប់រំ និង វិស័យផ្សេងៗទៀត។ ឧទាហរណ៍ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ឆ្នាំ២០២៤-២០២៨ បានចាត់ទុក 'ការកែទម្រង់សាលារៀនសម្រាប់ការទទួលការអប់រំប្រកបដោយគុណភាព បរិយាបន្ននិងសមធម៌ជាអាទិភាពនិងប្តេជ្ញាកាត់បន្ថយគម្លាតក្នុងការចូលរួម និងលទ្ធផលសិក្សារវាងកុមារី និងកុមារា សិស្សមានពិការភាព និងកុមារជនជាតិដើមភាគតិច (MoEYS, 2025b)។ ស្រដៀងគ្នានេះដែរគោលនយោបាយស្តីពីការអប់រំបរិយាបន្ន (ឆ្នាំ២០១៨) មានគោលបំណងធានាបាននូវឱកាសស្មើគ្នាសម្រាប់កុមារនិងយុវជនទាំងអស់ក្នុងការទទួលបានការអប់រំមូលដ្ឋាន ដោយមិនគិតពីយេនឌ័រ ពិការភាព តំបន់ភូមិសាស្ត្រ ឬជាតិពន្ធុ ដែលនាំឱ្យមានការរឹតទុកកាន់តែខ្លាំងថាកម្មវិធីសិក្សា និងសម្ភារៈបង្រៀន និងរៀននឹងគាំទ្រដល់បរិយាបន្ននៅក្នុងការអនុវត្តជាក់ស្តែង (MoEYS, 2018a )។

ពាក់ព័ន្ធនឹងយេនឌ័រ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ឆ្នាំ២០២៥-២០២៩ របស់ក្រសួងអប់រំ យុវជន និងកីឡា បានប្តេជ្ញាធ្វើយ៉ាងណាឱ្យវិស័យអប់រំរួមបញ្ចូលសមភាពយេនឌ័រទៅក្នុងគោលនយោបាយ ការធ្វើផែនការ ការអភិវឌ្ឍកម្មវិធីសិក្សា និងការបង្រៀន និងរៀនដែលផ្តល់នូវអាណត្តិយ៉ាងច្បាស់លាស់សម្រាប់ការអនុវត្តទស្សនទានយេនឌ័រនៅក្នុងសម្ភារៈបង្រៀន និងរៀន (MoEYS, 2025c)។ ចំណុចនេះត្រូវបានបំពេញបន្ថែមដោយ ផែនការយុទ្ធសាស្ត្រនារីរតនៈទី ៦ (ឆ្នាំ២០២៤-២០២៨) របស់ក្រសួងកិច្ចការនារី (MoWA) ដែលជាយុទ្ធសាស្ត្រអន្តរក្រសួងដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងកុមារីរួមទាំងតាមរយៈការបង្កើនឱកាស និងលទ្ធផលនៅក្នុងការអប់រំ (MoWA, 2024)។

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន(ឆ្នាំ២០១១) សង្កត់ធ្ងន់លើលទ្ធភាពជាសកលក្នុងការទទួលបានការអប់រំ និងការបណ្តុះបណ្តាលប្រកបដោយគុណភាព និងសមភាព និងរួមបញ្ចូលការយកចិត្តទុកដាក់ជាក់លាក់លើការលើកកម្ពស់សមភាពយេនឌ័រសម្រាប់យុវជន (រាជរដ្ឋាភិបាលកម្ពុជា, 2011)។ គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត(ឆ្នាំ២០១៨)កំណត់វិធីសាស្ត្ររៀនសូត្របែបក្រៅប្រព័ន្ធ និងមានភាពបត់បែន ដើម្បីទប់ស្កាត់ការផាត់ចេញពីការអប់រំជារៀងរហូត ជាពិសេសសម្រាប់អ្នកសិក្សាដែលបានបោះបង់ការសិក្សា តាមរយៈការគាំទ្រឱ្យកុមារី និងកុមារាបានចូលរៀនឡើងវិញ (MoEYS, 2018b)។ ជាចុងក្រោយ ការប្តេជ្ញាចិត្តក្នុងវិស័យទាំងនេះស្ថិតនៅក្រោមវិសាលភាពនៃយុទ្ធសាស្ត្របញ្ចកោណ(ក្របខ័ណ្ឌអភិវឌ្ឍន៍រួមនៃរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន)ដែលផ្តោតអាទិភាពលើការអភិវឌ្ឍមូលធនមនុស្ស សមធម៌ និងសមភាពយេនឌ័រជាមូលដ្ឋានគ្រឹះសម្រាប់វឌ្ឍនភាពជាតិ(រាជរដ្ឋាភិបាលកម្ពុជា, 2023)។

ជារួម គោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រទាំងនេះ ផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ការដាក់បញ្ចូលអភិក្រមបរិវត្តកម្មយេនឌ័រទៅក្នុងសម្ភារៈបង្រៀន និងរៀន ទន្ទឹមនឹងរបៀបវារៈដ៏ទូលំទូលាយរបស់កម្ពុជាសម្រាប់ការអប់រំប្រកបដោយបរិយាបន្ន សមធម៌ និងគុណភាពខ្ពស់។

បន្ថែមលើការបន្សុីគ្នាទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញសមភាពយេនឌ័រក៏មានហេតុផលជាក់ស្តែង និងច្បាស់លាស់ផងដែរក្នុងការវិនិយោគលើការអភិវឌ្ឍន៍សម្ភារៈបង្រៀន និងរៀនដែលជួយគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងដ៏ទូលំទូលាយដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅក្នុង និងតាមរយៈការអប់រំ។ បទដ្ឋានយេនឌ័រនៅតែបន្តជះឥទ្ធិពលលើលទ្ធភាពរបស់របស់កុមារ និងយុវជនក្នុងការទទួលបានការអប់រំ ជម្រើសមុខវិជ្ជារបស់ពួកគេ ការប្រឡូកក្នុងការរៀនសូត្រនៅក្នុងថ្នាក់រៀន និងឱកាសឡើងថ្នាក់ និងបញ្ចប់ការសិក្សា។ បទដ្ឋានទាំងនេះធ្វើឱ្យកុមារី និងកុមារាប្រឈមនឹងគុណវិបត្តិតាមរបៀបផ្សេងៗគ្នា។ សម្រាប់កុមារី ការរំពឹងទុកជុំវិញការរៀបការវ័យក្មេង ការមានផ្ទៃពោះ កាតព្វកិច្ចក្នុងគ្រួសារ និងការទទួលយកការត្រួតត្រារបស់បុរស អាចកម្រិតពេលវេលាសិក្សា រួមចំណែកធ្វើឱ្យកុមារីអវត្តមានពីការសិក្សា និងបោះបង់ការសិក្សា ព្រមទាំងបង្រួញបំណងប្រាថ្នារបស់ពួកគេផងដែរ (NGO Education Partnership, 2024; UNESCO, 2022a)។ សម្រាប់កុមារា បទដ្ឋានដែលសង្កត់ធ្ងន់លើការផ្គត់ផ្គង់គ្រួសារ ការពឹងផ្អែកលើខ្លួនឯង និងឯករាជ្យភាពអាចជំរុញឱ្យពួកគេឆាប់ចូលធ្វើការ ឬធ្វើចំណាកស្រុក កាត់បន្ថយការផ្តល់តម្លៃដល់ការសិក្សានៅសាលារៀន និងបន្ទុចបង្អាក់មិនឱ្យស្វែងរកជំនួយ ឬចូលរួមក្នុងការរៀនសូត្រ (Bo et al., 2023; UNESCO, 2026)។

ទោះជាយ៉ាងណាក៏ដោយ ការអប់រំអាចត្រូវបានរៀបចំឡើងក្នុងចេតនាជួយផ្លាស់ប្តូរបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ នៅពេលដែលបទដ្ឋានទាំងនោះរឹតត្បិតឱកាសរបស់អ្នកសិក្សា។ សម្ភារៈបង្រៀន និងរៀនគឺជាកត្តាជំរុញដ៏

សំខាន់មួយ។ សម្ភារៈបង្រៀន និងរៀនជះឥទ្ធិពលលើគំនិតរបស់អ្នកសិក្សាអំពីតួនាទីយេនឌ័រដែលអាចទទួលយកបានការរំពឹងទុករបស់ពួកគេចំពោះអ្វីដែលអាចទៅរួចនិងអនាគតដែលពួកគេប្រាថ្នាចង់បាន (RTI International, 2015; Spinner et al., 2021)។ ក៏ប៉ុន្តែ ភស្តុតាងពីប្រទេសជាច្រើន រួមទាំងកម្ពុជា បានបង្ហាញថា សម្ភារៈបង្រៀន និងរៀនដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ជារឿយៗមិនសូវបង្ហាញពីកុមារី និងស្ត្រីឡើយ ដោយពណ៌នាទាំងស្ត្រី និងបុរសក្នុងលក្ខណៈចង្អៀត និងបង្កប់ដោយផ្នត់គំនិតបែបប្រពៃណីនិងមិនឆ្លុះបញ្ចាំងពីភាពចម្រុះនៃជីវិតរបស់អ្នកសិក្សា (Crawfurd et al., 2024; Phorn and Arsyad, 2022)។ ជំនួសឱ្យការដេញដោលបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ សម្ភារៈទាំងនោះច្រើនតែពង្រឹងបទដ្ឋានទាំងនោះ ដែលរួមចំណែកដល់កម្មវិធីសិក្សាកំបាំងឬបង្កប់ដែលបន្តបង្កើតឱ្យមានវិសមភាពឡើងវិញ។ ចំណុចនេះគូសបញ្ជាក់ពីតម្រូវការរៀបចំសម្ភារៈបង្រៀន និងរៀនឡើងវិញដោយមានចេតនាច្បាស់លាស់ដើម្បីឱ្យសម្ភារៈទាំងនោះដេញដោលផ្នត់គំនិតចាស់កម្រិល និងលើកកម្ពស់បទដ្ឋានយេនឌ័រដែលមានបរិយាបន្ន វិជ្ជមាន ប្រកបដោយសុខុមាលភាព គោរពភាពចម្រុះ និងមានសមធម៌។

ចុងបញ្ចប់ ខណៈដែលកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់បទដ្ឋានយេនឌ័របែបវិជ្ជមាន និងប្រកបដោយសុខុមាលភាពនៅក្នុង និងតាមរយៈការអប់រំនៅកម្ពុជា ច្រើនតែផ្តោតទៅលើ និងនាំឱ្យមានលទ្ធផលល្អប្រសើរសម្រាប់កុមារី និងស្ត្រី ភស្តុតាងកាន់តែច្រើនឡើងដែលបង្ហាញពីការដកខ្លួនចេញពីការអប់រំរបស់កុមារា គូសបញ្ជាក់ពីភាពចាំបាច់នៃការដោះស្រាយរបៀបដែលបទដ្ឋានយេនឌ័រជះឥទ្ធិពលលើអ្នកសិក្សាទាំងអស់។ ហេតុដូច្នេះហើយ ការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រចាំបាច់ត្រូវរួមបញ្ចូលការយកចិត្តទុកដាក់ជាពិសេសលើការលើកកម្ពស់ភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព ទន្ទឹមនឹងការបន្តយកចិត្តទុកដាក់លើការពង្រីកលទ្ធភាព និងឱកាសសម្រាប់កុមារី និងសិស្សានុសិស្សទាំងអស់ (**ប្រអប់ទី ៣**)។ សៀវភៅណែនាំនេះឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងអស់នេះ ដោយផ្តល់នូវឧបករណ៍អនុវត្តន៍ជាក់ស្តែងសម្រាប់បង្កើតសម្ភារៈបង្រៀន និងរៀនដែលពង្រីកលទ្ធភាពសម្រាប់អ្នកសិក្សាគ្រប់រូប និងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងដ៏ទូលំទូលាយដើម្បីផ្លាស់ប្តូរបទដ្ឋានយេនឌ័រតាមរយៈការអប់រំ។

## អប់ទី ៣. សមភាពយេនឌ័រមានន័យថាសមភាពសម្រាប់ទាំងអស់គ្នា

សមភាពយេនឌ័រមានន័យថា សមភាព និងបរិយាបន្នសម្រាប់អ្នកសិក្សាទាំងអស់។ អ្វីដែលជាចំណុចវិជ្ជមានគឺមានការទទួលស្គាល់កាន់តែច្រើនឡើងចំពោះកិច្ចខិតខំប្រឹងប្រែងជំរុញសមភាពយេនឌ័រដោយកុមារា និងបុរស ជាពិសេសក្នុងករណីដែលកិច្ចខិតខំប្រឹងប្រែងបែបនេះកំពុងថយចុះ ឬប្រឈមនឹងហានិភ័យមួយចំនួន។ ទោះជាយ៉ាងណាក៏ដោយ ការទទួលស្គាល់បែបនេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់កុមារី និងស្ត្រីដែលនៅតែបន្តប្រឈមមុខនឹងឧបសគ្គយ៉ាងធំធេង និងបន្តលេចឡើង ដែលរារាំងដល់ការទទួលបាន និងការសម្រេចបានលទ្ធផលក្នុងការអប់រំនោះទេ។ ខណៈដែលកុមារាពិតជាមានភាគរយចូលរៀនតិចជាងកុមារី នៅកម្រិតមធ្យមសិក្សាបឋមភូមិ និងកម្រិតខ្ពស់ជាងនេះ (សូមមើល**រូបភាពទី ១**) ទិន្នន័យក៏បង្ហាញផងដែរថាអត្រាបោះបង់ការសិក្សាចាប់ពីកម្រិតមធ្យមសិក្សាបឋមភូមិ នៅតែមានកម្រិតខ្ពស់ទាំងសម្រាប់កុមារី និងកុមារា។

នៅកម្ពុជាអ្នកតស៊ូមតិជាច្រើនក៏បានទាមទារឱ្យមានការយកចិត្តទុកដាក់ និងការដាក់បញ្ចូលអ្នកសិក្សាដែលកំណត់អត្តសញ្ញាណខ្លួនឯងថាជាបុគ្គលមានទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងចរិតលក្ខណៈភេទចម្រុះ (SOGIE-SC) ផងដែរ។ នេះគឺដោយសារតែភស្តុតាងដែលមានស្រាប់បានគូសបញ្ជាក់ថា អ្នកសិក្សាទាំងនេះតែងតែប្រឈមមុខនឹងការមាក់ងាយ ការរករឿងរំខាន និងការផាត់ចេញពីសង្គម នៅក្នុង និងជុំវិញសាលារៀន ដែលពិតជាបង្កផលប៉ះពាល់អវិជ្ជមានលើសុខុមាលភាព សុវត្ថិភាព និងការចូលរួមក្នុងការរៀនសូត្ររបស់ពួកគេ (មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, 2015; UNESCO, 2015)។ បច្ចុប្បន្នប្រធានបទ ដូចជា ទំនោរផ្លូវភេទ អត្តសញ្ញាណ/ការបង្ហាញយេនឌ័រ និងសិទ្ធិរបស់ស្ត្រីស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័រ (LGBT) ត្រូវបានដាក់បញ្ចូលទៅក្នុងការអប់រំសុខភាព និងបំណិនជីវិតសម្រាប់សិស្សធំពេញវ័យ (Rainbow Community Kampuchea Organisation et al., 2022)។

លើសពីនេះ វាជារឿងសំខាន់ក្នុងការទទួលស្គាល់ថា យេនឌ័រមិនដំណើរការតែឯកឯងនោះទេ។ បទពិសោធន៍របស់អ្នកសិក្សាត្រូវបានកំណត់ដោយរបៀបដែលយេនឌ័ររួមបញ្ចូលជាមួយកត្តាផ្សេងៗទៀត ដូចជា ទីកន្លែងដែលពួកគេរស់នៅ ទ្រព្យសម្បត្តិ សមត្ថភាព ឬទំនួលខុសត្រូវលើកិច្ចការថៃទាំ។ កត្តាប្រទាក់ក្រឡាគ្នាទាំងនេះ ជះឥទ្ធិពលទៅលើថាតើនរណាដែលងាយនឹងបានចូលរៀន ឬបោះបង់ការសិក្សា និងថាតើនរណាដែលអាចរៀនបានពូកែ (សូមមើល**ប្រអប់ទី ៥**)។

## ១.៤ ផ្នែកនានានៃសៀវភៅណែនាំ

ផ្នែកទី ២ ស្វែងយល់ពីទស្សនទាននៃអភិក្រមបរិវត្តកម្មយេនឌ័រចំពោះការអប់រំ និងបង្ហាញពីភាពចាំបាច់នៃការអភិវឌ្ឍន៍សម្ភារៈបង្រៀន និងរៀន (TLMs) ដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រនៅកម្ពុជា។ ផ្នែកនេះបង្ហាញភស្តុតាងដែលបញ្ជាក់ថា សម្ភារៈបង្រៀន និងរៀនដែលមានស្រាប់ច្រើនតែរំលេច និងពង្រឹងបទដ្ឋាន និងផ្នត់គំនិតយេនឌ័រ ដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង។ ផ្នែកនេះពិនិត្យមើលផលប៉ះពាល់ដែលអាចកើតមានលើការយល់ឃើញ បំណងប្រាថ្នា និងលទ្ធផលរបស់អ្នកសិក្សា និងទាញការយកចិត្តទុកដាក់ទៅលើរបៀបដែលការបង្ហាញភាពជាបុរសនៅក្នុងសម្ភារៈបង្រៀន និងរៀន មានទំនាក់ទំនងទៅនឹងនិន្នាការគួរឱ្យព្រួយបារម្ភនៃការចូលរួមក្នុងការអប់រំរបស់កុមារ។

ផ្នែកទី ៣ ផ្តល់នូវការណែនាំជាក់ស្តែងសម្រាប់ការអភិវឌ្ឍសម្ភារៈបង្រៀននិងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ ។ ផ្នែកនេះរៀបរាប់អំពីគោលការណ៍ និងយុទ្ធសាស្ត្រគន្លឹះសម្រាប់ការកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់និងការអភិវឌ្ឍសម្ភារៈបង្រៀននិងរៀនថ្មី។ ផ្នែកនេះកំណត់នូវលក្ខណៈពិសេសៗនៃការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀនបង្ហាញពីភាពចាំបាច់នៃការធានាថា ការអភិវឌ្ឍន៍លើសម្ភារៈបង្រៀន និងរៀននេះគាំទ្រដល់បរិវត្តកម្មយេនឌ័រនៅគ្រប់មុខវិជ្ជាទាំងអស់ និងផ្តល់នូវគន្លឹះសម្រាប់ជំរុញការចូលរួមគាំទ្រចំពោះគំនិតផ្តួចផ្តើមសមភាពយេនឌ័រ។ ផ្នែកនេះក៏ផ្តល់នូវដំណើរការជាជំហានៗ និងឧបករណ៍ងាយស្រួលប្រើប្រាស់ដើម្បីអនុវត្តទស្សនទានបរិវត្តកម្មយេនឌ័រនៅពេលកែសម្រួល ឬអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន។

ផ្នែកទី ៤ ពន្យល់ពីមូលហេតុដែលការអភិវឌ្ឍន៍សម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រកាន់តែមានប្រសិទ្ធភាពនៅពេលដាក់បញ្ចូលទៅក្នុងអភិក្រមបរិវត្តកម្មយេនឌ័រដ៏ទូលំទូលាយសម្រាប់ការអប់រំ។ ផ្នែកនេះកំណត់រកចំណុចចាប់ផ្តើមជាច្រើនសម្រាប់ការផ្លាស់ប្តូរបទដ្ឋានយេនឌ័រនៅក្នុង និងតាមរយៈការអប់រំនិងអះអាងថា អភិក្រមគ្រប់ជ្រុងជ្រោយគឺជាគន្លឹះក្នុងការបង្ហាញសក្តានុពលនៃការអប់រំ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងជំរុញឱ្យមានការផ្លាស់ប្តូរយូរអង្វែងប្រកបដោយបរិវត្តកម្ម ។

ផ្នែកនីមួយៗផ្តើមពីទិដ្ឋភាពទូទៅនៃចំណុចរំពឹងទុក និងបញ្ចប់ដោយចំណុចសំខាន់ៗដែលត្រូវចងចាំ។

## ២. តើហេតុអ្វីត្រូវមានសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ?

នៅពេលបញ្ចប់ផ្នែកនេះ អ្នកអាននឹង ៖

- ✓ យល់ដឹងពីរបៀបដែលបទដ្ឋានយេនឌ័រជះឥទ្ធិពលលើការចូលរួម ការរៀនសូត្រ ព្រមទាំងសុខភាព និងសុខុមាលភាពទូទៅរបស់សិស្ស និងរបៀបដែលបទដ្ឋានទាំងនេះមានទំនាក់ទំនងជាមួយទម្រង់វិសមភាពផ្សេងៗទៀត។
- ✓ កត់សម្គាល់ថាតើឧត្តមគតិនៃភាពជាបុរសដែលលេចធ្លោអាចរួមចំណែកដល់ការដកខ្លួនចេញពីការអប់រំរបស់កុមារាដោយរបៀបណា។
- ✓ យល់ដឹងថាតើអភិក្រមបរិវត្តកម្មយេនឌ័រចំពោះការអប់រំពាក់ព័ន្ធនឹងអ្វីខ្លះ និងចំណុចចាប់ផ្តើមផ្សេងៗដើម្បីឱ្យមានការផ្លាស់ប្តូរនៅទូទាំងប្រព័ន្ធអប់រំ។
- ✓ យល់ដឹងពីរបៀបដែលសម្ភារៈបង្រៀន និងរៀន (TLMs) អាចពង្រឹង ឬជេញដោលបទដ្ឋាន និងផ្នត់គំនិតយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង។
- ✓ ផ្តល់តម្លៃដល់សារៈសំខាន់នៃការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀនដែលលើកកម្ពស់បរិយាបន្ន ផ្តល់តម្លៃដល់ភាពចម្រុះ និងគាំទ្រដល់ភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព។

## ២.១ ផលជះនៃបទដ្ឋានយេនឌ័រនៅលើបទពិសោធន៍ និងលទ្ធផលអប់រំ

បទដ្ឋានយេនឌ័រ គឺជាការរំពឹងទុកជារួមនៅក្នុងសង្គមមួយចំពោះអ្វីដែលកុមារី និងកុមារា ស្ត្រី និងបុរស អាចធ្វើ និងគួរធ្វើ។ បទដ្ឋានទាំងនេះអាចមានលក្ខណៈរឹតត្បិត និងបង្កគ្រោះថ្នាក់ ជាពិសេសនៅពេលដែលវាកម្រិតនូវអ្វី ដែលកុមារយល់ថា ពួកគេអាចប៉ងប្រាថ្នាបាន ឬរបៀបដែលពួកគេគួរប្រព្រឹត្ត។ តាំងពីវ័យកុមារភាព កុមាររៀនសូត្រពីអ្វីដែលគេចាត់ទុកថាអាចទទួលយកបាន សមស្រប ឬគួរជាទីប៉ងប្រាថ្នាសម្រាប់យេនឌ័ររបស់ពួកគេ ហើយបទដ្ឋានទាំងនេះ ជះឥទ្ធិពលលើការយល់ឃើញរបស់កុមារចំពោះខ្លួនឯង ទំនាក់ទំនង និងជម្រើសជីវិតរបស់ពួកគេ (UNICEF, 2022)។

កុមារ និងយុវជនរៀនសូត្រពីបទដ្ឋានយេនឌ័រតាមរយៈមជ្ឈដ្ឋានជាច្រើន។ មជ្ឈដ្ឋានទាំងនេះរួមមានគ្រួសារ ក្រុមមិត្តភក្តិ សាលារៀន (រួមទាំងសម្ភារៈបង្រៀន និងរៀន) ប្រព័ន្ធផ្សព្វផ្សាយ និងបរិបទសង្គម និងវប្បធម៌ដ៏ទូលំទូលាយដែលពួកគេរស់នៅ (UNESCO, 2026; **ប្រអប់ទី ៤**)។

នៅទូទាំងមជ្ឈដ្ឋានទាំងនេះ បទដ្ឋានយេនឌ័រត្រូវបានបង្ហាញឱ្យឃើញតាមវិធីផ្សេងៗ ឧទាហរណ៍ តាមរយៈភាសា ការរំពឹងទុក និងភាពជាតំណាង ហើយវាអាចបង្កផលជះយ៉ាងទូលំទូលាយ។ នៅក្នុងការអប់រំ បទដ្ឋានយេនឌ័រជះឥទ្ធិពលលើរបៀបដែលសិស្សរៀនមុខវិជ្ជាផ្សេងៗ កម្រិតនៃការខំប្រឹងប្រែងរបស់ពួកគេ ការប្រព្រឹត្តរបស់ពួកគេនៅក្នុងថ្នាក់រៀន និងតួនាទីដែលពួកគេគិតស្រមៃសម្រាប់ខ្លួនឯងនាពេលអនាគត (Brussino and McBrien, 2022)។ ឧទាហរណ៍ កុមារីអាចត្រូវបានបន្ទុចបង្អាក់មិនឱ្យរៀនមុខវិជ្ជាវិទ្យាសាស្ត្រ ឬទទួលយកតួនាទីជាអ្នកដឹកនាំ ខណៈដែលកុមារាអាចនឹងត្រូវបានគេរារាំងមិនឱ្យបង្ហាញអារម្មណ៍ ឬចាប់យកមុខវិជ្ជាបែបច្នៃប្រឌិត (Brussino and McBrien, 2022; Cheryan et al., 2025; Makarova et al., 2019; UNESCO, 2022d)។

ប្រអប់ទី ៤. កម្រិតជាច្រើនជះឥទ្ធិពលលើរបៀបដែលកុមារ និងយុវជនរៀនសូត្រពីបទដ្ឋានយេនឌ័រ




*ប្រភព ៖ UNESCO, 2026*

ចំណុចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគំរូយេនឌ័រនៃការចុះឈ្មោះចូលរៀន ក្នុងកម្មវិធីអប់រំឧត្តមសិក្សានៅកម្ពុជា។ ការសិក្សាមួយបានរកឃើញថា ស្ត្រីមានចំនួនច្រើនលើសលប់នៅក្នុងមុខជំនាញមិនមែនវិទ្យាសាស្ត្រ ដូចជា ភាសាអង់គ្លេស មនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ខណៈដែលបុរសច្រើនតែចុះឈ្មោះចូលរៀនមុខជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) (Dom and Yi, 2018)។ អ្នកស្រាវជ្រាវបានគូសបញ្ជាក់ថាគំរូទាំងនេះពាក់ព័ន្ធនឹងការរំពឹងទុករបស់គ្រួសារ និងបទដ្ឋានបិតាធិបតេយ្យដ៏ទូលំទូលាយ ដែលចាត់ទុកវិទ្យាសាស្ត្រជាមុខវិជ្ជារបស់ 'បុរស' ជាមុខវិជ្ជាកម្រិតខ្ពស់ និងជាមុខវិជ្ជាពិបាករៀន ស្របពេលដែលកុមារីមិនសូវបានដឹងអំពីមុខវិជ្ជា STEM និងមិនសូវត្រូវបានគេលើកទឹកចិត្តឱ្យរៀនមុខវិជ្ជានេះនៅសាលារៀន។ បទដ្ឋាននិងផ្នត់គំនិតយេនឌ័រក៏រួមចំណែកដល់ការប្រព្រឹត្តអំពើហិង្សាផ្អែកលើយេនឌ័រនៅសាលារៀន (SRGBV) ផងដែរ ហើយបញ្ហានេះអាចបណ្តាលឱ្យសិស្សដកខ្លួនចេញពីការសិក្សា រៀនខ្សោយ និងធ្លាប់បោះបង់ការសិក្សា (UNESCO, 2019a; UNESCO and UN Women, 2016)។

បទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹងក៏ប៉ះពាល់ដល់សុខភាព និងសុខុមាលភាពផងដែរ។ ការរំពឹងទុកលើរបៀបដែលកុមារា និងបុរសគួរប្រព្រឹត្តពាក់ព័ន្ធនឹងអត្រាខ្ពស់នៃការប្រព្រឹត្តអំពើហិង្សា ការប្រើប្រាស់គ្រឿងញៀន និងអាយុសង្ឃឹមរស់ខ្លីជាងក្នុងចំណោមបុរស។ បទដ្ឋានដែលពង្រឹងភាពក្រោមបង្គាប់របស់ស្ត្រី និងកុមារី រួមចំណែកដល់គំរូនៃការរៀបអាពាហ៍ពិពាហ៍វ័យក្មេង អំពើហិង្សាផ្អែកលើយេនឌ័រ (GBV) និងការលំបាកផ្នែកសេដ្ឋកិច្ច (Kennedy et al., 2020; Stavropoulou, 2019; WHO, 2021)។ បទដ្ឋានទាំងនេះមិនត្រឹមតែបង្កផលវិបាកលើបុគ្គលម្នាក់ៗប៉ុណ្ណោះទេ ប៉ុន្តែវាក៏ពង្រឹងវិសមភាពយេនឌ័រដ៏ទូលំទូលាយ និងបង្កឱ្យមានការខាតបង់សេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរផងដែរ (Kennedy et al., 2020)។ ដូច្នេះការងារផ្លាស់ប្តូរបទដ្ឋានយេនឌ័រ មិនមែនជាការផ្តល់អាទិភាពលើកុមារីជាងកុមារា ឬកុមារាជាងកុមារីនោះទេ។ នៅពេលដែលមានការរំពឹងទុកដូចគ្នា និងកាន់តែបត់បែនជាងមុនចំពោះកុមារី និងកុមារា មនុស្សគ្រប់រូបនឹងទទួលបានអត្ថប្រយោជន៍ តាមរយៈការលើកកម្ពស់ភាពយុត្តិធម៌ បរិយាបន្ន និងការទទួលខុសត្រូវរួមគ្នា ដែលនឹងផ្តល់ផលចំណេញដល់ សុខុមាលភាពបុគ្គល គ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។

## ២.២ កត្តាប្រទាក់ក្រឡាគ្នា

យេនឌ័រជះឥទ្ធិពលលើការអប់រំ ប៉ុន្តែវាមិនដំណើរការតែឯកឯងនោះទេ។ ដើម្បីស្វែងយល់ថាតើនរណាទទួលបានផលប្រយោជន៍ ឬរងគុណវិបត្តិច្រើនជាងគេ ចាំបាច់ត្រូវពិចារណាលើរបៀបដែលយេនឌ័រមានទំនាក់ទំនងជាមួយកត្តាផ្សេងៗទៀត (**ប្រអប់ទី ៥**)។

កត្តានានាដូចជា៖ទីតាំងភូមិសាស្ត្រ ពិការភាព និងស្ថានភាព សេដ្ឋកិច្ចសង្គម ក៏កំណត់លទ្ធភាពទទួលបានការចូលរួម និងលទ្ធផលនៃការអប់រំផងដែរ។ នៅក្នុងបរិបទជាច្រើន អ្នកសិក្សាដែលងាយរងគ្រោះបំផុត គឺជាអ្នកដែលស្ថិតនៅចំណុចប្រសព្វនៃវិសមភាពជាច្រើន ឧទាហរណ៍៖ កុមារមកពីគ្រួសារក្រីក្រនៅតំបន់ជនបទ។ ដូច្នេះ កិច្ចខិតខំប្រឹងប្រែងដោះស្រាយគុណវិបត្តិរបស់កុមារា ឬកុមារីនៅក្នុងការអប់រំ ចាំបាច់ត្រូវប្រកាន់យកអភិក្រមប្រទាក់ក្រឡាគ្នា ដែលទទួលស្គាល់ និងឆ្លើយតបទៅនឹងទម្រង់ត្រួតគ្នានៃវិសមភាពទាំងនេះ ជាជាងដោះស្រាយបញ្ហាយេនឌ័រដោយឡែកៗពីគ្នា។

**ប្រអប់ទី ៥. យេនឌ័រមានទំនាក់ទំនងជាមួយកត្តាជាច្រើនបានជះឥទ្ធិពលលើបទពិសោធន៍ និងលទ្ធផលនៃការអប់រំ**




*(ប្រភព៖ អ្នកនិពន្ធ)*

## ២.៣ ការដកខ្លួនចេញពីការអប់រំរបស់កុមារា

នៅកម្ពុជាគំរូនៃការចុះឈ្មោះចូលរៀនបង្ហាញពីសមាមាត្រស្មើរតែស្មើគ្នារវាងកុមារី និងកុមារានៅកម្រិតបឋមសិក្សាដោយជាទូទៅការចូលរៀនមានតុល្យភាព។ នៅកម្រិតមធ្យមសិក្សាបឋមភូមិ ការចុះឈ្មោះចូលរៀនសរុបមានការធ្លាក់ចុះសម្រាប់សិស្សទាំងពីរភេទ ហើយគម្លាតយេនឌ័រនៅមានកម្រិតតូចនៅឡើយ ប៉ុន្តែវាមានលក្ខណៈបញ្ច្រាសទិសដោយកុមារីមានចំនួនច្រើនជាងកុមារាបន្តិចក្នុងចំណោមអ្នកសិក្សាដែលបានចុះឈ្មោះ។ ចាប់ពីកម្រិតនោះមកភាពខុសគ្នាកាន់តែស្តែងឱ្យឃើញច្បាស់៖ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ចំនួនកុមារីដែលចុះឈ្មោះចូលរៀនមានច្រើនជាងខ្លាំង បើធៀបនឹងកុមារាដែលបង្ហាញពីគម្លាតយេនឌ័រកាន់តែធំនៅក្នុងការបន្តការសិក្សា នៅពេលដែលកម្រិតអប់រំកាន់តែខ្ពស់ (MoEYS, 2025a, រូបភាពទី ១)។ ទិន្នន័យក៏បង្ហាញផងដែរថា នៅកម្រិតអប់រំមូលដ្ឋាន កុមារាមានអត្រារៀនត្រួតថ្នាក់ខ្ពស់ជាងកុមារី (MoEYS, 2025a)។

យោងតាមទិន្នន័យ EMIS ឆ្នាំសិក្សា ២០២៤–២០២៥ សិស្សចុះឈ្មោះចូលរៀនសរុបនៅកម្រិតបឋមសិក្សាមានចំនួន ២,២៦១,២១៦ នាក់ ក្នុងនោះសិស្សស្រីមាន ៤៨ ភាគរយ និងសិស្សប្រុសមាន៥២ ភាគរយ។ នៅកម្រិតមធ្យមសិក្សា

បឋមភូមិចំនួនសិស្សចុះឈ្មោះចូលរៀនសរុបបានថយចុះមកនៅត្រឹមតែ ៧១២,២៩៨ នាក់ ក្នុងនោះសិស្សស្រីមាន៥២ ភាគរយ និងសិស្សប្រុសមាន៤៨ ភាគរយ ដែលបានបង្ហាញពីការប្រែប្រួលនៃគម្លាតយេនឌ័របន្តិចបន្តួច។ គម្លាតនេះកាន់តែរីកធំទៅនៅកម្រិតមធ្យមសិក្សាទុតិយភូមិដែលមានសិស្សចុះឈ្មោះចូលរៀនសរុបចំនួន៤៥៦,៨០៤ នាក់ ក្នុងនោះសិស្សស្រីមាន ៥៦ភាគរយ ប្រៀបធៀបទៅនឹងសិស្សប្រុសមានត្រឹមតែ ៤៤ភាគរយប៉ុណ្ណោះ។

ការថយចុះនៃការចុះឈ្មោះចូលរៀននៅដំណាក់កាលឆ្លងភូមិសិក្សាទាំងពីរ(ពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ និងពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ)បង្ហាញពីការរួមបញ្ចូលគ្នានៃកត្តារចនាសម្ព័ន្ធនិងសង្គមសេដ្ឋកិច្ច។ ភស្តុតាងបង្ហាញថាដំណាក់កាលផ្លាស់ប្តូរនេះពាក់ព័ន្ធនឹងហានិភ័យនៃការកើនឡើងចំពោះការបោះបង់ការសិក្សាដោយសារថ្លៃចំណាយលើការអប់រំកើនឡើង និងការបាត់បង់ឱកាសរកប្រាក់ពីការងារ(opportunity cost) កាន់តែមានសារៈសំខាន់ មានយុវជនជាច្រើនត្រូវបានរំពឹងឱ្យចូលរួមរកប្រាក់ចំណូលសម្រាប់គ្រួសារ ឬចូលទៅកាន់ទីផ្សារការងារ ។ ឧបសគ្គដ៏ទៃទៀតរួមមានការទទួលបានសេវាអប់រំនៅមានកម្រិត ជាពិសេសនៅតំបន់ជនបទ និងការយល់ឃើញអំពីភាពពាក់ព័ន្ធ និងគុណភាពនៃការអប់រំនៅកម្រិតមធ្យមសិក្សា។ ភាពក្រីក្រ និងតម្រូវការធ្វើការងារ ជាមូលហេតុដែលត្រូវបានរាយការណ៍ញឹកញាប់បំផុតសម្រាប់ការចាកចេញពីសាលារៀន ដែលប៉ះពាល់ទាំងក្មេងស្រី និងក្មេងប្រុស ក្នុងទម្រង់ខុសៗគ្នា (វិទ្យាស្ថានជាតិស្ថិតិ, ២០២០ យូនីសេហ្វ ២០២០)។

ទិន្នន័យស្តីពីការចុះឈ្មោះចូលរៀនកម្រិតឧត្តមសិក្សានៅតាមគ្រឹះស្ថាននានារបស់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បង្ហាញថា ជារួមនិស្សិតស្រីមានចំនួនច្រើនជាងនិស្សិតប្រុសបន្តិចនៅកម្រិតបរិញ្ញាបត្រ ប៉ុន្តែចំនួននិស្សិតស្រីបានថយចុះយ៉ាងខ្លាំងនៅកម្រិតក្រោយបរិញ្ញាបត្រ (អនុបណ្ឌិត និងបណ្ឌិត) ដែលនៅកម្រិតទាំងនេះមាននិស្សិតប្រុសភាគច្រើនបានចុះឈ្មោះចូលរៀន (MoEYS, 2025g, **រូបភាពទី ២**)។

### រូបភាពទី ១. ការចុះឈ្មោះចូលរៀនតាមកម្រិតសិក្សា និងយេនឌ័រ (២០២៤-២០២៥)




ប្រភព ៖ *MoEYS, 2025a.*

**រូបភាពទី២. ការចុះឈ្មោះចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា តាមកម្រិតសញ្ញាបត្រ និងយេនឌ័រ (២០២៣-២០២៤)**




ប្រភព ៖ *MoEYS, 2025g*

ទិន្នន័យស្តីពីលទ្ធផលសិក្សាបង្ហាញពីវិសមភាពយេនឌ័រក្នុងមុខវិជ្ជាអំណាន វិទ្យាសាស្ត្រ និងគណិតវិទ្យា ក្នុងចំណោមសិស្សនៅកម្ពុជា (Phal et al., 2023; UNICEF and SEAMEO Secretariat, 2025) ។ កុមារាមានសមត្ថភាពខ្សោយខ្លាំងលើមុខវិជ្ជាអំណាន សំណេរ គណិតវិទ្យា និងវិទ្យាសាស្ត្រ បើធៀបនឹងកុមារី ហើយគម្លាតនេះរីកកាន់តែធំក្នុង មុខវិជ្ជាអំណាន និងសំណេរ។

ការស្រាវជ្រាវដែលស៊ើបអង្កេតពីមូលហេតុដែលកុមារគ្រប់អាយុត្រូវសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ មិនចូលសាលារៀន បានរកឃើញថា សម្ពាធសេដ្ឋកិច្ចគឺជាហេតុផលដ៏សំខាន់ទាំងសម្រាប់កុមារី និងកុមារា ។ ហេតុផលផ្សេងទៀតបង្ហាញពីគំរូទាក់ទងនឹងយេនឌ័រ។ សម្រាប់កុមារី ភាពចាំបាច់នៃការជួយធ្វើកិច្ចការផ្ទះមានកម្រិតខ្ពស់ខ្លាំងជាងបើធៀបនឹងកុមារា។ សម្រាប់កុមារា សម្ពាធសេដ្ឋកិច្ច លទ្ធផលសិក្សាខ្សោយ និងការខ្វះការលើកទឹកចិត្ត មានកម្រិតខ្ពស់ខ្លាំងជាងបើធៀបនឹងកុមារី (វិទ្យាស្ថានជាតិស្ថិតិ, 2020) ។

របកគំហើញទាំងនេះគូសបញ្ជាក់ថា ការដោះស្រាយបញ្ហានៃការដកខ្លួនចេញពីការអប់រំរបស់កុមារា មិនអាចធ្វើឡើងតាមរយៈដំណោះស្រាយរួមតែមួយបានឡើយ។ ផ្ទុយទៅវិញ ដំណោះស្រាយត្រូវពិចារណាលើរបៀបដែលបទដ្ឋាន និងការរំពឹងទុកយេនឌ័រដែលលេចធ្លោ ការកំណត់អាកប្បកិរិយា បំណងប្រាថ្នា និងឱកាស ដែលជះឥទ្ធិពលលើការចូលរួមក្នុងការអប់រំ ការឡើងថ្នាក់ និងការបញ្ចប់ការសិក្សារបស់កុមារី និងកុមារានៅកម្រិតអប់រំផ្សេងៗគ្នា។ ដូចដែលបានកត់សម្គាល់ខាងដើម ឥទ្ធិពលទាំងនេះក៏មានទំនាក់ទំនងផងដែរជាមួយនឹងកត្តាផ្សេងទៀតដែលជំរុញឱ្យមានវិសមភាព ដូចជា ភាពក្រីក្រ ពិការភាព ទីតាំងភូមិសាស្ត្រ និងភាសា ដែលរឹតតែបន្ថែមការលំបាកដល់ក្រុមកុមារី និងក្រុមកុមារាមួយចំនួន (**ប្រអប់ទី ៥**)។

## ២.៤ បទដ្ឋាននៃភាពជាបុរស និងការចូលរួមក្នុងការអប់រំរបស់កុមារា

តាំងពីដើមរៀងមក កិច្ចខិតខំប្រឹងប្រែងដោះស្រាយវិសមភាពយេនឌ័រនៅក្នុង និងតាមរយៈការអប់រំ តែងតែផ្តោតលើបទពិសោធន៍ និងគុណវិបត្តិដែលកុមារី និងស្ត្រីជួបប្រទះ ដែលឆ្លុះបញ្ចាំងពីគម្លាតយេនឌ័រជាសកលដែល

មានតាំងពីយូរលង់ណាស់មកហើយ រួមជាមួយនឹងការប្តេជ្ញាចិត្តលើកកម្ពស់យុគភាពយេនឌ័រ និងការបង្កើនភាពអង់អាចក្លាហានដល់ស្ត្រី។ ការផ្តោតយកចិត្តទុកដាក់នេះមានសារៈសំខាន់ណាស់ ជាពិសេសក្នុងបរិបទដែលកុមារីត្រូវបានផាត់ចេញពីសាលារៀន មានចំនួនតិចតួចនៅក្នុងការសិក្សាមុខវិជ្ជាមួយចំនួន ឬងាយប្រឈមនឹងការរើសអើង អំពើហិង្សា ឬការឆាប់បោះបង់ការសិក្សាជាងកុមារា (Marcus, 2018; UNESCO, 2020)។ ទោះជាយ៉ាងណាក៏ដោយក្នុងផ្នែកដែលទិន្នន័យបង្ហាញថា កុមារាកំពុងមានវឌ្ឍនភាពទាបជាងកុមារី ទាក់ទងនឹងការចុះឈ្មោះចូលរៀន និងលទ្ធផលសិក្សា វាក៏ជារឿងចាំបាច់ផងដែរក្នុងការទទួលស្គាល់នូវកត្តាយេនឌ័រដែលជះឥទ្ធិពលលើលទ្ធភាពទទួលការអប់រំ និងការចូលរួមក្នុងការអប់រំរបស់កុមារា។ ចំណុចនេះស្របនឹងទស្សនៈដែលលើកឡើងថា វិសមភាពយេនឌ័រមិនអាចដោះស្រាយបានទាំងស្រុងឡើយប្រសិនបើមិនមានការពិនិត្យមើលថា តើបទដ្ឋានទាំងនេះជះឥទ្ធិពលដូចម្តេចលើអ្នកសិក្សាទាំងអស់ (UNESCO, 2018a, 2022c)។

ពិតណាស់ ការស្រាវជ្រាវនៅជុំវិញពិភពលោកបង្ហាញថា ឧត្តមគតិនៃភាពជាបុរសដែលលេចធ្លោពោលគឺការរំពឹងទុករបស់សង្គមចំពោះរបៀបដែលកុមារា និងបុរសគួរប្រព្រឹត្តអាចមានភាពផ្ទុយគ្នានឹងអាកប្បកិរិយា និងឥរិយាបថដែលផ្សារភ្ជាប់ទៅនឹងការខិតខំប្រឹងប្រែង និងភាពជោគជ័យក្នុងការសិក្សា (Marcus et al., 2024; UNESCO, 2022c)។ ការរំពឹងទុកដ៏លេចធ្លោទាំងនេះចំពោះរបៀបដែលកុមារា និងបុរសគួរប្រព្រឹត្ត (ជួនកាលគេហៅថា 'ភាពជាបុរសបែបត្រួតត្រា') គឺជាចំណុចសំខាន់នៃការស្រាវជ្រាវនៅក្នុងប្រទេសមួយចំនួន។ គំនិតដែលយល់ថា បទដ្ឋានទាំងនេះមានលក្ខណៈរឹតត្បិត បាននាំឱ្យមានទស្សនទាននៃ '**ប្រអប់បុរស**' (man box) ដែលជាបណ្តុំនៃការរំពឹងទុកដ៏តូចចង្អៀតចំពោះអត្ថន័យនៃការធ្វើជា 'បុរសពិត'។ មានន័យថា កុមារា និងបុរសណាដែលបោះជំហានចេញក្រៅប្រអប់នេះ អាចប្រឈមនឹងការសើចចំអក ឬការផាត់ចេញពីសង្គម។ ការរំពឹងទុកនៅក្នុងប្រអប់នេះរួមមានការពឹងផ្អែកលើខ្លួនឯង ភាពរឹងមាំ ការត្រួតត្រាផ្លូវភេទ និងការហ៊ានប្រើប្រាស់ភាពគឃ្លើន ដើម្បីដោះស្រាយបញ្ហា (Heilman et al., 2017; The Men’s Project and Flood, 2024)។

ខណៈដែលបទដ្ឋាននៃភាពជាបុរសដែលលេចធ្លោប្រែប្រួលទៅតាមបរិបទ ការរំពឹងទុកជាច្រើនដែលត្រូវបានរកឃើញនៅក្នុងការស្រាវជ្រាវស្តីពី 'ប្រអប់បុរស' ត្រូវបានរំលេចនៅក្នុងការសិក្សាពីតំបន់ផ្សេងៗ ដែលបង្ហាញថា ការរំពឹងទុកទាំងនោះអាចត្រូវបានគេស្គាល់យ៉ាងច្បាស់នៅក្នុងបរិបទវប្បធម៌ជាច្រើន។ ការស្រាវជ្រាវស្តីពីការរំពឹងទុកលើកុមារា និងបុរសនៅកម្ពុជា បង្ហាញថា ក្តីរំពឹងទុកទាំងនោះត្រួតគ្នាជាមួយនឹងឧត្តមគតិនៃ 'ប្រអប់បុរស' (UNFPA, 2023, **ប្រអប់ទី ៦**)។ ការស្រាវជ្រាវបែបគុណវិស័យផ្សេងទៀតបង្ហាញថា កុមារាច្រើនតែទទួលរងសម្ពាធយ៉ាងខ្លាំងក្នុងការបង្ហាញភាព 'រឹងមាំ' ឬទម្រង់នៃភាពជាបុរសដែលស្វែងរកការទទួលស្គាល់ក្នុងសង្គម (status-seeking) នៅជុំវិញសាលារៀន រួមទាំងតាមរយៈឥទ្ធិពលអវិជ្ជមានពីមិត្តភក្តិ ការប្រជុំយប្រជាន និងអាកប្បកិរិយាមិនសហការ ដែលត្រូវបានគេមើលឃើញថាមិនស៊ីគ្នានឹងការសិក្សារៀនសូត្រ។ ទន្ទឹមនឹងនេះ ការរំពឹងថា កុមារាគួរតែចេញរកប្រាក់ និងក្លាយជាជនបង្គោលគ្រួសារ អាចរួមចំណែកធ្វើឱ្យកុមារាដកខ្លួនពីការអប់រំ និងឆាប់បោះបង់ការសិក្សា (UNICEF, 2020)។

### ប្រអប់ទី ៦. ឧត្តមគតិនៃភាពជាបុរសដែលលេចធ្លោនៅកម្ពុជា

ការស្រាវជ្រាវដែលសិក្សាអំពីការយល់ឃើញចំពោះភាពជាបុរសដែលលេចធ្លោនៅកម្ពុជា បានគូសបញ្ជាក់ពី 'ឧត្តមគតិ' ដូចខាងក្រោម ៖

- អ្នកផ្គត់ផ្គង់ហិរញ្ញវត្ថុ ៖ រំពឹងថាត្រូវរកចំណូល និងផ្គត់ផ្គង់គ្រួសារ
- ត្រួតត្រា និងមានឋានៈខ្ពស់ជាងស្ត្រី
- តឹងរ៉ឹង/រឹងមាំ និងឧស្សាហ៍ព្យាយាម
- ជាអ្នកដឹកនាំ
- ជាមេគ្រួសារ
- ជាអ្នកធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ
- មានបទពិសោធន៍ខាងផ្លូវភេទ
- មានសិទ្ធិរួមភេទ
- បញ្ចៀសការបង្ហាញភាពទន់ខ្សោយ (ភាពសោកសៅ ឬការភ័យខ្លាច ត្រូវបានគេមើលឃើញថាជាភាពទន់ខ្សោយ) ។

ស្រដៀងគ្នានឹងការស្រាវជ្រាវស្តីពីប្រអប់បុរស ការសិក្សានេះបានរកឃើញថា មានសម្ពាធយ៉ាងខ្លាំងពីមិត្តភក្តិដែលបង្ខំឱ្យបុរសប្រកាន់ខ្ជាប់ឧត្តមគតិនៃភាពជាបុរសទាំងនេះ ហើយបុរសដែលមានឧត្តមគតិនៃភាពជាបុរសផ្សេងពីនេះ ឬលើកកម្ពស់សមភាពយេនឌ័រ មានអារម្មណ៍ថា ពួកគេមិនអាចពិភាក្សាអំពីគំនិតទាំងនេះដោយបើកចំហបានទេ ជាពិសេសក្នុងចំណោមបុរសផ្សេងទៀត ហើយនេះគូសបញ្ជាក់ពីការរងសម្ពាធពីមិត្តភក្តិដែលបង្ខំឱ្យ បុរសអនុលោមតាមឧត្តមគតិនៃភាពជាបុរសដែលលេចធ្លោ សូម្បីតែនៅពេលដែលពួកគេមិនគាំទ្រទស្សនៈទាំងនោះក៏ដោយ។

ប្រភព ៖ Adapted from UNFPA, 2023.

ទោះបីជាមានការបង្ហាញយ៉ាងច្បាស់ថា បទដ្ឋានដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹងទាំងនេះ កំពុងជំរុញឱ្យមានវិសមភាពយេនឌ័រ ឥទ្ធិពលនៃអំណាចមិនស្មើគ្នា និងអំពើហិង្សាផ្អែកលើយេនឌ័រក៏ដោយប៉ុន្តែមានការព្រួយបារម្ភកាន់តែខ្លាំងឡើងចំពោះផលប៉ះពាល់នៃបទដ្ឋានយេនឌ័រទាំងនេះមកលើបទពិសោធន៍អប់រំ បំណងប្រាថ្នា និងលទ្ធផលសិក្សារបស់កុមារា។ ខណៈដែលកត្តាជាច្រើនជះឥទ្ធិពលលើបញ្ហានេះ ការស្រាវជ្រាវបានបង្ហាញថា កត្តារួមចំណែកមួយគឺរបៀបដែលបទដ្ឋាននៃភាពជាបុរសដែលលេចធ្លោ មានភាពផ្ទុយគ្នានឹងអាកប្បកិរិយា និងឥរិយាបថដែលផ្សារភ្ជាប់នឹងបំណងប្រាថ្នា និងភាពជោគជ័យក្នុងការសិក្សា (Marcus et al., 2024; UNESCO, 2022c)។ និយាយឱ្យសាមញ្ញ គំនិតលេចធ្លោអំពីអត្ថន័យនៃការធ្វើជា 'បុរសពិត' មិនលើកទឹកចិត្តកុមារាឱ្យបង្ហាញភាពឧស្សាហ៍ព្យាយាម ឬមានមហិច្ឆិតានៅសាលារៀនឡើយ។ កុមារាអាចគេចវេសមិនចង់បង្ហាញការចូលរួមនៅក្នុងមជ្ឈដ្ឋានសិក្សា ដោយសារខ្លាចគេមើលឃើញថាទន់ខ្សោយ ឬមិនមែនជាបុរសពិត។ កត្តានេះរួមចំណែកធ្វើឱ្យកុមារាមិនសូវចង់រៀនសូត្រ រៀនមិនសូវពូកែ និងងាយបោះបង់ការសិក្សា។ សិស្សានុសិស្សក៏បានចូលរួមក្នុងការ

'ត្រួតពិនិត្យយេនឌ័រ' (gender policing) ផងដែរ ដោយការសិក្សាបង្ហាញថា ជារឿយៗកុមារត្រូវបានមិត្តភក្តិចំអក ផាត់ចេញ ឬករឿងរំខាន នៅពេលពួកគេបង្ហាញចំណាប់អារម្មណ៍លើការសិក្សា ឬការខិតខំរៀនសូត្រ (Olavarría et al., 2015; Skipper and Fox, 2022; UNICEF, 2020)។

ការស្រាវជ្រាវក្នុងប្រទេសជាច្រើនបង្ហាញថា អំណានត្រូវបានគេចាត់ទុកយ៉ាងទូលំទូលាយថាជាសកម្មភាពរបស់ 'ស្ត្រី' ដែលមិនស័ក្តិសមសម្រាប់កុមារឡើយ។ កុមារដែលបង្ហាញចំណាប់អារម្មណ៍លើការអាន ច្រើនតែត្រូវបានមិត្តភក្តិចំអក ដែលធ្វើឱ្យពួកគេលែងសូវចង់អាន និងពង្រឹងគំនិតដែលយល់ថា អំណានមិនស៊ីគ្នានឹង អត្តសញ្ញាណនៃភាពជាបុរសដ៏ឧត្តុងឧត្តម(គាប់ប្រសើរ) (Eck et al., 2024; Olavarría et al., 2015; Wolter et al., 2015)។ របកគំហើញទាំងនេះបានបង្កឱ្យមានការព្រួយបារម្ភ ព្រោះទិន្នន័យបានបង្ហាញពីទំនោរដែលកុមារមានសមត្ថភាពទាបក្នុងការអានបានស្ទាត់ បើធៀបនឹងកុមារី ដែលមានន័យថា បទដ្ឋានយេនឌ័រដែល លេចធ្លោ អាចនឹងកំពុងជះឥទ្ធិពលលើការទទួលបានបំណិនអក្ខរកម្មមូលដ្ឋានរបស់កុមារា (Phal et al., 2023, 2024; UNESCO, 2022c)។

ការស្រាវជ្រាវថ្មីៗនេះបានផ្តល់ការយល់ដឹងមួយចំនួនអំពីការដកខ្លួនចេញពីការអប់រំរបស់កុមារានៅកម្ពុជា។ ការស្រាវជ្រាវដែលដឹកនាំដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានសិក្សាពីមូលហេតុដែលកុមារាដកខ្លួនចេញពីការអប់រំ។ ការស្រាវជ្រាវនេះរួមបញ្ចូលការពិនិត្យឯកសារពាក់ព័ន្ធ និងការប្រមូលទិន្នន័យបែបគុណវិស័យជាមួយកុមារា (សិស្សពូកែ និងសិស្សខ្សោយ ក៏ដូចជាកុមារាដែលបានបោះបង់ការសិក្សា) កុមារីដែលកំពុងសិក្សា មាតាបិតារបស់កុមារាដែលរៀនពូកែ រៀនខ្សោយ និងបោះបង់ការសិក្សា លោកគ្រូអ្នកគ្រូ នាយកសាលា មន្ត្រីការិយាល័យអប់រំស្រុក និងមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា(អ.យ.ក) ថ្នាក់ជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល (CSOs)។ ការស្រាវជ្រាវបានរកឃើញកត្តាជាច្រើនដែលជួយជំរុញផង និងរារាំងផងដល់ការចូលរួមក្នុងការអប់រំរបស់កុមារា (**តារាងទី ១**)។ អ្វីដែលគួរកត់សម្គាល់នោះគឺ កុមារា និងយុវជនមួយចំនួនយល់ថា ការរៀនសូត្រមិនសូវមានភាពពាក់ព័ន្ធនឹងជីវិត និងឱកាសការងារនាពេលអនាគតរបស់ពួកគេឡើយ ។ ការស្រាវជ្រាវរបស់អង្គការUNESCO បានរកឃើញថា ជាពិសេសនៅតំបន់ជនបទ ការសិក្សាត្រូវបានមើលឃើញថាបានផ្តល់អត្ថប្រយោជន៍មិនច្បាស់លាស់ ឬយឺតយ៉ាវ ខណៈដែលការងារដែលមានប្រាក់កម្រៃអាចផ្តល់ប្រាក់ចំណូលភ្លាមៗ។ ដោយសារតែហេតុផលនេះ ក្មេងប្រុសដែលជាញឹកញាប់ត្រូវបានរំពឹងឱ្យចូលរួមក្នុងផ្នែកសេដ្ឋកិច្ច ហើយអាចមើលឃើញថាការអប់រំមិនសូវពាក់ព័ន្ធនឹងអនាគតរបស់ពួកគេទេ។ ភាពក្រីក្រនៅក្នុងគ្រួសារ ការរំពឹងទុកទាបរបស់មាតាបិតាចំពោះការអប់រំ និងការចូលរួមនៅមានកម្រិតរបស់មាតាបិតាកាន់តែបង្កើនការយល់ឃើញបែបនេះ ដោយគ្រួសារខ្លះថែមទាំងលើកទឹកចិត្តឱ្យក្មេងប្រុសចាកចេញពីសាលារៀន ដើម្បីរកប្រាក់ចំណូលជំនួសវិញថែមទៀត។ ស្របពេលដែលបំណងប្រាថ្នាផ្នែកសម្ភារៈនិងការរងសម្ពាធឱ្យរួមចំណែកផ្នែកសេដ្ឋកិច្ចបានធ្វើឱ្យអន់ថយបន្ថែមទៀតដល់ការចូលរួមនិងការតស៊ូប្រឹងប្រែងរបស់ពួកគេនៅសាលារៀន (UNESCO, 2026)។

## តារាងទី ១. កត្តាជះឥទ្ធិពលលើការចុះឈ្មោះចូលរៀន និងលទ្ធផលសិក្សារបស់កុមារនៅកម្ពុជា

| | |
|---|---|
| **កម្រិតបុគ្គល** | • បំណិនមូលដ្ឋានខ្សោយ និងបញ្ហាប្រឈមក្នុងការសិក្សារៀនសូត្រ<br>• ខ្វះការលើកទឹកចិត្ត ការតស៊ូ និងបំណងប្រាថ្នាក្នុងការសិក្សារៀនសូត្រ<br>• ការវាយតម្លៃខ្លួនឯងទាប និងសុខុមាលភាពផ្លូវចិត្ត<br>• ការរំខានអារម្មណ៍ និងចំណាប់អារម្មណ៍លើអ្វីផ្សេងទៀត<br>• សុខភាព អាហារូបត្ថម្ភ និងការប្រើប្រាស់គ្រឿងញៀន |
| **កម្រិតគ្រួសារ** | • សម្ពាធសេដ្ឋកិច្ច និងតម្រូវការជីវភាព<br>• មាតាបិតាសិស្សមិនសូវចូលរួម និងមិនសូវផ្ដល់តម្លៃលើការអប់រំ<br>• រចនាសម្ព័ន្ធគ្រួសារ និងអស្ថិរភាពក្នុងគ្រួសារ (ឧ. ឪពុកម្ដាយធ្វើចំណាកស្រុកទៅរកការងារធ្វើ ការលែងលះ ឬការបែកបាក់ក្នុងគ្រួសារ)<br>• របៀបចិញ្ចឹមបីបាច់ និងបរិយាកាសផ្លូវចិត្ត (ឧ. ការរិះគន់ វិន័យតឹងរ៉ឹងពេក ឬការព្រងើយកន្តើយចំពោះអារម្មណ៍/សញ្ចេតនា)<br>• ការយល់ឃើញចំពោះយេនឌ័រ និងការរំពឹងទុកមិនស្មើគ្នា<br>• ការឆ្លងភូមិសិក្សា (transition) ឆាប់រហ័សពេក និងបំណងប្រាថ្នាផ្នែកសម្ភារៈ |
| **កម្រិតមិត្តភក្តិ** | • សម្ពាធឱ្យប្រឡូកក្នុងអាកប្បកិរិយាដែលជះផលមិនល្អលើលទ្ធផលសិក្សា<br>• ការចរចាសង្គមនៅក្នុងក្រុមមិត្តភក្តិ<br>• សម្ភារៈនិយម និងឋានៈ |
| **កម្រិតសាលារៀន** | • គុណវុឌ្ឍិគ្រូបង្រៀន និងគម្លាតនៃការចូលរួម<br>• ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន<br>• សេវា និងគោលនយោបាយគាំទ្រ<br>• ការរៀនគួរ និងការពង្រឹងវិសមភាពអប់រំ<br>• បរិយាកាសសិក្សា និងសុវត្ថិភាពក្នុងសាលារៀន<br>• តម្រូវការផ្នែកសិក្សាធិការ និងបញ្ហាប្រឈមក្នុងការឆ្លងភូមិសិក្សា |
| **កម្រិតសហគមន៍** | • ការចូលរួមរបស់សហគមន៍ក្នុងការអប់រំ នៅមានកម្រិត<br>• ការប្រជែងដណ្ដើមឱកាសសេដ្ឋកិច្ច<br>• របាំងរចនាសម្ព័ន្ធ និងគម្លាតធនធាន |

| | |
|---|---|
| | • ការរំពឹងទុកក្នុងវប្បធម៌ និងបទដ្ឋានយេនឌ័រ |
| **កម្រិតប្រទេស និងសង្គម** | • តម្លៃវប្បធម៌ទូទៅ បទដ្ឋានយេនឌ័រ និងការរំពឹងទុក ជំនឿ ច្បាប់ និងរចនាសម្ព័ន្ធសង្គម ដែលជះឥទ្ធិពលលើកម្រិតផ្សេងទៀត។ |

ប្រភព ៖ *UNESCO et al.,* 2026.

និន្នាការថ្មីៗនៃការដកខ្លួនចេញពីការអប់រំរបស់កុមារា បានបញ្ជូនសារយ៉ាងច្បាស់មួយថា កិច្ចខិតខំប្រឹងប្រែងលើកកម្ពស់សមភាពយេនឌ័រនៅក្នុង និងតាមរយៈការអប់រំ ក៏ត្រូវតែដោះស្រាយរបៀបដែលបទដ្ឋាននៃភាពជាបុរសជះឥទ្ធិពលលើអាកប្បកិរិយា និងបទពិសោធន៍របស់កុមារានៅសាលារៀនផងដែរ។ ទម្រង់ជាច្រើននៃភាពជាបុរសដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹងដែលជាប់ពាក់ព័ន្ធនឹងការដកខ្លួនចេញពីការអប់រំរបស់កុមារាគឺជាបទដ្ឋានដដែលដែលនាំឱ្យមានបញ្ហានានា ដូចជា ទំនាក់ទំនងអំណាចមិនស្មើគ្នា និងអំពើហិង្សាលើស្ត្រី។ ដូច្នេះ ការខិតខំផ្លាស់ប្តូរបទដ្ឋានទាំងនេះ និងលើកកម្ពស់ជម្រើស ដែលវិជ្ជមាន និងប្រកបដោយសុខុមាលភាព មិនត្រឹមតែផ្តល់អត្ថយោជន៍ដល់កុមារា និងបុរសប៉ុណ្ណោះទេប៉ុន្តែថែមទាំងផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សាទាំងអស់ និងសង្គមទាំងមូលផងដែរ។ ស្របពេលជាមួយគ្នានេះការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការដោះស្រាយបញ្ហានៃការដកខ្លួនចេញពីការអប់រំរបស់កុមារាមិនត្រូវធ្វើឡើង ដោយទាត់ចោលកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការដោះស្រាយរបាំង និងគុណវិបត្តិដែលបន្តកើតមានលើកុមារីនៅក្នុងការអប់រំនោះឡើយ ។

## ២.៥ តើអ្វីទៅជាអភិក្រមបរិវត្តកម្មយេនឌ័រចំពោះការអប់រំ?

នៅពេលដែលបទដ្ឋានយេនឌ័រកំណត់ថាតើអ្នកណាចូលរៀន អ្នកណាចូលរួមក្នុងសកម្មភាពរៀនសូត្រ និងអ្នកណាទទួលបានជោគជ័យនៅសាលារៀន ប្រព័ន្ធអប់រំចាំបាច់ត្រូវតែក្លាយជាផ្នែកមួយនៃដំណោះស្រាយជាជាងជាដំណើរការដើម្បីឆ្លុះបញ្ចាំង ឬពង្រឹងវិសមភាពដែលមានស្រាប់។ ពិតណាស់ ការអប់រំមានអនុភាពក្នុងការផ្លាស់ប្តូរបទដ្ឋានដែលបង្កគ្រោះថ្នាក់ រួមទាំងបទដ្ឋានដែលទាក់ទងនឹងយេនឌ័រផងដែរ។ តាមរយៈការផ្តល់ឱកាសឱ្យគិតស្រមៃហួសពីបទដ្ឋាន និងផ្នត់គំនិតយេនឌ័រដែលមានស្រាប់ក៏ដូចជាការផ្តល់មូលដ្ឋានសម្រាប់ការគិតពិចារណា ការអប់រំអាចផ្តល់អំណាចដល់សិស្សឱ្យកត់សម្គាល់ និងខិតខំដេញដោលបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងវិសមភាពដ៏ទូលំទូលាយព្រមទាំងតស៊ូមតិឱ្យមានការផ្លាស់ប្តូរ (Plan International et al., 2021; UNESCO, 2022c)។

ទោះជាយ៉ាងណាក៏ដោយ តាមរយៈការរៀបចំ និងការអនុវត្តប្រចាំថ្ងៃ ជារឿយៗប្រព័ន្ធអប់រំអាចនឹងពង្រឹងដោយប្រយោលនូវបទដ្ឋាន និងផ្នត់គំនិតយេនឌ័រដែលបង្កគ្រោះថ្នាក់ទៅវិញ។ ចំណុចនេះរួមបញ្ចូលទាំង 'កម្មវិធីសិក្សាបង្កប់៖ បទដ្ឋាន គុណតម្លៃ និងការរំពឹងទុកដែលមិនបានសរសេរបង្ហាញ ដែលសិស្សក្រេបជញ្ជក់តាមរយៈការរៀនសូត្រប្រចាំថ្ងៃ លើសពីអ្វីដែលត្រូវបានបង្រៀនជាផ្លូវការ (Marcus et al., 2024)។ កម្មវិធីសិក្សាបង្កប់ដំណើរការតាមរយៈរបៀបដែលគ្រូប្រាស្រ័យទាក់ទងជាមួយសិស្ស គំរូនៃការដាក់វិន័យ និងរង្វាន់លើកទឹកចិត្ត និងថាតើអត្តសញ្ញាណ បទពិសោធន៍ និងគ្រួសាររបស់អ្នកណាខ្លះដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសម្ភារៈបង្រៀន និងរៀន និងការពិភាក្សាក្នុងថ្នាក់។

ហេតុនេះហើយទើបបច្ចុប្បន្ន មានកិច្ចខិតខំប្រឹងប្រែងកាន់តែច្រើនឡើងដើម្បីធ្វើយ៉ាងណាឱ្យការអប់រំគាំទ្រដល់បរិវត្តកម្មយេនឌ័រ (Plan International et al., 2021; UNESCO, 2019b, 2022c)។ ការអប់រំប្រកបដោយបរិវត្តកម្មយេនឌ័រគឺលើសពីការខិតខំប្រឹងប្រែងសម្រេចបានយុគភាពយេនឌ័រ។ ការអប់រំបែបនេះមានគោលបំណងផ្លាស់ប្តូរបទដ្ឋាន និងផ្នត់គំនិតយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង ដោយទាញការយកចិត្តទុកដាក់ទៅលើមូលហេតុឫសគល់នៃវិសមភាព ការដេញដោលទំនាក់ទំនងអំណាច និងការជួយឱ្យសិស្សគិតស្រមៃឡើងវិញ និងទទួលយកជម្រើសផ្សេងទៀតដែលកាន់តែមានសមធម៌យេនឌ័រ។ ចំណុចនេះទាមទារឱ្យមានសកម្មភាពច្បាស់លាស់នៅក្នុងផ្នែកជាច្រើនចាប់ពីគោលនយោបាយរហូតដល់គរុកោសល្យ និងសម្ភារៈបង្រៀន និងរៀន (សូមមើល **ប្រអប់ទី ៧**)។

| ប្រអប់ទី ៧. ចំណុចចាប់ផ្ដើមសម្រាប់ការផ្លាស់ប្ដូរបទដ្ឋានយេនឌ័រនៅក្នុង និងតាមរយៈការអប់រំ | | |
|---|---|---|
| គោលនយោបាយ ផែនការ និងថវិកា | កម្មវិធីសិក្សា | គ្រូបង្រៀន ការបណ្ដុះបណ្ដាលគ្រូ និងការគាំទ្រជាបន្តបន្ទាប់ |
| គរុកោសល្យ | សម្ភារៈបង្រៀន និងរៀន (TLMs) | ភាពជាអ្នកដឹកនាំ |
| បរិស្ថានសិក្សា | ការចូលរួមរបស់មាតាបិតាសិស្ស អ្នកថែទាំ និងសហគមន៍ | ប្រព័ន្ធទិន្នន័យ |
| *ប្រភព ៖ អ្នកនិពន្ធ* | | |

ខណៈដែលសៀវភៅណែនាំនេះផ្ដោតជាចម្បងលើការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀន ផ្នែកទី៤ នឹងងាកទៅផ្ដោតឡើងវិញលើចំណុចចាប់ផ្ដើមផ្សេងទៀត និងរៀបរាប់ពីសកម្មភាពជាក់ស្ដែងដែលអាចធ្វើឡើងនៅទូទាំងផ្នែកផ្សេងៗនៃប្រព័ន្ធអប់រំ ដើម្បីពង្រឹង និងទ្រទ្រង់ការផ្លាស់ប្ដូរ។

## ២.៦ តើអ្វីខ្លះជាសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ?

ក្រៅពីការជួយឱ្យសិស្សស្ទាត់ជំនាញលើចំណេះដឹង និងបំណិនជាក់លាក់តាមមុខវិជ្ជា សម្ភារៈបង្រៀន និងរៀន(TLMs)ផ្ដល់មធ្យោបាយមួយសម្រាប់ឱ្យសិស្សកំណត់អត្តសញ្ញាណ និងស្គាល់ខ្លួនឯង និងអ្នកដទៃ (UNESCO, 2020)។ សម្ភារៈបង្រៀន និងរៀនមានច្រើនទម្រង់ (**ប្រអប់ទី ២**)។ សម្ភារៈបង្រៀន និងរៀនគ្រប់ទម្រង់ទាំងអស់អាចពង្រឹងគំនិតចង្អៀតចង្អល់ និងផ្នត់គំនិតអំពីយេនឌ័រ ឬក៏វាអាចខិតខំដេញដោលបទដ្ឋានដែលបង្គ្រោះថ្នាក់ និងតឹងរ៉ឹងលើកកម្ពស់បទដ្ឋានជាវិជ្ជមាន និងពង្រីកការយល់ដឹងរបស់សិស្សអំពីអ្វីដែលអាចទៅរួច (**ប្រអប់ទី ៨**)។

**ប្រអប់ទី ៨. សម្ភារៈបង្រៀន និងរៀន អាចបញ្ចៀសការពង្រឹងបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង និង អាចលើកកម្ពស់បទដ្ឋានយេនឌ័រដែលវិជ្ជមាន និងប្រកបដោយសុខុមាលភាព**[2]

| ឧទាហរណ៍នៃរូបភាព ដែលអាចពង្រឹងបទដ្ឋានយេនឌ័រ ដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង | ឧទាហរណ៍នៃរូបភាព ដែលលើកកម្ពស់បទដ្ឋានយេនឌ័រដែលវិជ្ជមាននិងប្រកបដោយសុខុមាលភាព |
|---|---|
|   សៀវភៅគណិតវិទ្យាថ្នាក់ទី២ បង្ហាញរូបភាពស្ត្រីកំពុងដេរខោអាវ និងបុរសកំពុងធ្វើការងារជាងឈើ។<br>ប្រភព ៖ MoEYS, 2025e |   សៀវភៅភាសាខ្មែរថ្នាក់ទី ១ បង្ហាញរូបភាពកុមារា និងកុមារីកំពុងសម្អាតថ្នាក់រៀនរបស់ពួកគេ។<br>ប្រភព ៖ MoEYS, 2026 |
|   ឆា |   កុមារខ្លះធ្វើការងាររបស់ពួកគេនៅក្រោមដើមឈើក្នុងទីធ្លាសាលារៀន |

[2] សូមកត់សម្គាល់ថា ឧទាហរណ៍ទាំងនេះគឺសម្រាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយឯកសារប្រភពមិនត្រូវបានវិភាគពេញលេញនោះទេ។ ចំណុចសំខាន់គឺត្រូវទទួលស្គាល់ថាការធ្វើបរិវត្តមកម្មយ៉េនឌ័រលើសម្ភារៈបង្រៀន និងរៀនមានគោលបំណងបង្ហាញយេនឌ័រប្រកបដោយតុល្យភាពពោលគឺ តួនាទី គន្លងអាជីព និងសមិទ្ធផល ត្រូវបានពណ៌នាប្រកបដោយសមធម៌នៅទូទាំងយេនឌ័រផ្សេងៗ ជាជាងផ្សារភ្ជាប់តែនឹងយេនឌ័រជាក់លាក់ណាមួយ។










សៀវភៅភាសាខ្មែរថ្នាក់ទី ១ បង្ហាញរូបភាពស្ត្រីកំពុងចម្អិនអាហារ និងធ្វើកិច្ចការផ្ទះហើយកុមារកំពុងធ្វើការងារជាងឈើ ជួសជុលកង់ និងលេងកីឡា (រូបភាពទាំង៣)។

ប្រភព ៖ MoEYS, 2026




សៀវភៅភាសាខ្មែរថ្នាក់ទី ២ បង្ហាញរូបភាពកុមារា និងកុមារី កំពុងអានសៀវភៅ និងបោសសម្អាត។

ប្រភព ៖ MoEYS, 2025d



សៀវភៅភាសាខ្មែរថ្នាក់ទី ៥ បង្ហាញរូបភាពមន្ត្រីនគរបាលជាស្ត្រី។

ប្រភព ៖ MoEYS, 2000



សៀវភៅគណិតវិទ្យាថ្នាក់ទី ១ បង្ហាញរូបភាពកុមារាកំពុងលេងបាល់ទាត់ និងកុមារីកំពុងលោតអន្ទាក់។

ប្រភព ៖ MoEYS, 2025f

នៅពេលដែលសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្ន វាមិនត្រឹមតែបញ្ចៀសភាពលម្អៀងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដេញដោលផ្នត់គំនិតយេនឌ័រ ផ្តល់ការបង្ហាញយេនឌ័រយ៉ាងចម្រុះ និងប្រកបដោយបរិយាបន្នព្រមទាំងគាំទ្រដល់ការគិតពិចារណាអំពីបទដ្ឋានយេនឌ័រ និងឥទ្ធិពលនៃអំណាចទៀតផង (Commonwealth of Learning, 2019; RTI International, 2015; UNESCO, 2018b)។ សម្ភារៈបង្រៀន និងរៀនទាំងនេះខិតខំរួមចំណែកដល់ការផ្លាស់ប្តូរទំនាក់ទំនងយេនឌ័រមិនស្មើភាពគ្នា តាមរយៈការលើកកម្ពស់បុគ្គលគំរូជាវិជ្ជមាន ការទទួលខុសត្រូវរួមគ្នា និងការចូលរួមស្មើៗគ្នានៃគ្រប់យេនឌ័រទាំងអស់នៅក្នុងការរៀនសូត្រ និងការធ្វើសេចក្តីសម្រេចចិត្ត។ ដើម្បីធ្វើកិច្ចការនេះ សម្ភារៈបង្រៀន និងរៀន ត្រូវតែយកចិត្តទុកដាក់លើរបៀបដែលយេនឌ័រត្រូវបានបង្ហាញនៅក្នុងអត្ថបទ រូបភាព និងការរចនា ព្រមទាំងបង្កើតឱកាសសម្រាប់ឱ្យសិស្សកត់សម្គាល់ ពិនិត្យមើលនិងដេញដោលបទដ្ឋាន និងផ្នត់គំនិតយេនឌ័រដែលពាក់ព័ន្ធនឹងមុខវិជ្ជាសិក្សា។

ការស្រាវជ្រាវបង្ហាញពីសក្តានុពលរបស់សម្ភារៈបង្រៀន និងរៀនក្នុងការផ្លាស់ប្តូរបទដ្ឋានយេនឌ័រ និងលើកកម្ពស់សមភាពយេនឌ័រ។ ឧទាហរណ៍ ការសិក្សាបានបង្ហាញថា ការមានទំនាក់ទំនង ឬការប្រាស្រ័យទាក់ទងជាមួយបុគ្គលគំរូដែលប្រឆាំងនឹងផ្នត់គំនិតយេនឌ័រ អាចកាត់បន្ថយផ្នត់គំនិតយេនឌ័រ ទោះបីជាការស្រាវជ្រាវភាគច្រើនផ្តោតលើការដេញដោលផ្នត់គំនិតដែលប៉ះពាល់ដល់ស្ត្រី និងកុមារីក៏ដោយ (Crawfurd et al., 2024; Olsson and Martiny, 2018)។ ការសិក្សានៅក្នុងវិស័យសេដ្ឋកិច្ច បង្ហាញពីសារៈសំខាន់របស់បុគ្គលគំរូក្នុងការកំណត់បំណងប្រាថ្នា និងលទ្ធផលនៃការសិក្សានិងការងារ។ បុគ្គលគំរូទាំងនេះអាចមានឥទ្ធិពលដូចនៅពេលដែលពួកគេជាមនុស្សពិតដែរ ទោះបីពួកគេជាតួអង្គក្នុងរឿងប្រឌិតក៏ដោយ (Crawfurd et al., 2024; Serra, 2025)។

ការសិក្សាមួយដែលពិនិត្យមើលឥទ្ធិពលនៃរូបភាពក្នុងសៀវភៅសិក្សាដែលបង្កប់ផ្នត់គំនិតយេនឌ័រ និងផ្ទុយពីផ្នត់គំនិតយេនឌ័រ មកលើលទ្ធផលសិក្សាវិទ្យាសាស្ត្រ រកឃើញថា កុមារីទទួលបានពិន្ទុខ្ពស់ជាងខ្លាំងបើធៀបនឹង

កុមារាលើការធ្វើតេស្តការយល់ដឹង នៅពេលពួកគេបានមើលឃើញរូបភាពអ្នកវិទ្យាសាស្ត្រជាស្ត្រី ដែលផ្ទុយពីផ្នត់គំនិតយេនឌ័រ (Good et al., 2010)។ ការស្រាវជ្រាវនៅចក្រភពអង់គ្លេសជាមួយសិស្សបឋមសិក្សា បានរកឃើញថា ការដឹងលឺ/មើលឃើញផ្នត់គំនិតដែលផ្ទុយពីផ្នត់គំនិតយេនឌ័រ (counter-stereotype) នៅក្នុងថ្នាក់រៀនបានបង្កើនលទ្ធភាពដែលកុមារយល់ថា ពួកគេកាន់តែស្រដៀងគ្នានឹងយេនឌ័រមួយផ្សេងទៀត ហើយពួកគេពិចារណាពីជម្រើសអាជីពកាន់តែច្រើន (Spinner et al., 2021)។ កុមារាក៏ទំនងជារាយការណ៍កាន់តែច្រើនផងដែរថា ផ្នត់គំនិតយេនឌ័រគឺជារឿងមិនយុត្តិធម៌។ ការសិក្សាមួយផ្សេងទៀតបានបង្ហាញថា ការឱ្យសិស្សថ្នាក់ទី៥ បានឃើញឧទាហរណ៍នៃបុរស និងស្ត្រីដែលបំពេញតួនាទីខុសពីទម្លាប់ពីមុនឬពីបុរាណតរៀងមកទាំងនៅកន្លែងធ្វើការ និងនៅផ្ទះបាននាំឱ្យមានការយល់ឃើញជាវិជ្ជមានកាន់តែខ្លាំងចំពោះអ្វីដែលកុមារា និងកុមារីអាចធ្វើបាន និងអាចក្លាយខ្លួន (Flynn, 2003)។

## ២.៧ ការបង្ហាញយេនឌ័រនៅក្នុងសម្ភារៈបង្រៀន និងរៀនបច្ចុប្បន្ន

ទោះបីជាសម្ភារៈបង្រៀន និងរៀន (TLMs) មានអាចជួយលុបបំបាត់បទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង និងលើកកម្ពស់បទដ្ឋានជាវិជ្ជមានក៏ដោយប៉ុន្តែការវិភាគលើឯកសារមកពីប្រទេសនានានៅជុំវិញពិភពលោកបានរកឃើញថាជារឿយៗសម្ភារៈបង្រៀន និងរៀនបានពង្រឹងជាជាងដេញដោលបទដ្ឋានយេនឌ័រ និងការរំពឹងទុកជាប្រពៃណី។ លើសពីនេះ ការសិក្សានានានៅតែបង្ហាញថាកុមារី និងស្ត្រីត្រូវបានលើកឡើង/បង្ហាញតិចតួចនៅក្នុងឯកសារដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ (Crawfurd et al., 2024; Islam and Asadullah, 2018; UNESCO, 2020)។ ការប្រៀបធៀបសៀវភៅសិក្សាក្នុង ៣៤ ប្រទេស បានរកឃើញលំនាំជាប់លាប់នៃការបង្ហាញស្ត្រីតិចតួចនៅក្នុងអត្ថបទ (Crawfurd et al., 2024)។

ក្រៅពីការបង្ហាញមិនស្មើគ្នា ការវិភាគលើសម្ភារៈបង្រៀន និងរៀននៅជុំវិញពិភពលោកនៅតែរកឃើញថា ជារឿយៗសម្ភារៈបង្រៀន និងរៀនបានពង្រឹងផ្នត់គំនិត និងតួនាទីយេនឌ័រ (Crawfurd et al., 2024; UNESCO, 2020)។ ការសិក្សាតាមប្រទេសជាច្រើនស្តីពីសៀវភៅសិក្សាបានរកឃើញថាស្ត្រី និងកុមារីច្រើនតែត្រូវបានពណ៌នាថាអសកម្ម និងមានលទ្ធភាពតិចជាងបុរសក្នុងការផ្សារភ្ជាប់ទៅនឹងការងារ ឬសមិទ្ធផលនានា។ ចំណែកឯកុមារា និងបុរសច្រើនតែត្រូវបានពណ៌នាថាសកម្ម មានហេតុផល និងមានចរិតត្រួតត្រា (Crawfurd et al., 2024)។ ជារឿយៗស្ត្រី និងបុរសត្រូវបានកំណត់ត្រឹមតួនាទីវិជ្ជាជីវៈតាមបែបផ្នត់គំនិតចាស់កម្រិល ។ ឧទាហរណ៍៖ស្ត្រីជាគ្រូបង្រៀន គិលានុបដ្ឋាយិកា ឬអ្នកថែទាំ ហើយបុរសជាអ្នកវិទ្យាសាស្ត្រ វិស្វករ ឬអ្នកដឹកនាំ។ នេះជាការពង្រឹងការសន្មតហួសសម័យអំពីប្រភេទការងារដែលស័ក្តិសម ឬអាចទៅរួចសម្រាប់បុរស និងស្ត្រី (Crawfurd et al., 2024)។ ការវិភាគលើឯកសារកម្មវិធីសិក្សាថ្នាក់ជាតិចំនួន ១១០ នៅក្នុង ៧៨ ប្រទេស បានរកឃើញភាពលម្អៀង និងផ្នត់គំនិតយេនឌ័រដែលបន្តលេចឡើង ជាពិសេសនៅក្នុងសៀវភៅគណិតវិទ្យា និងវិទ្យាសាស្ត្រ ជាវិស័យដែលស្ត្រីមានចំនួនតិចតួចបំផុត (UNESCO, 2017)។ ស្រដៀងគ្នានេះដែរ ការសិក្សាថ្មីមួយស្តីពីការសន្ទនាស្តាប់ក្នុងសៀវភៅភាសាអង់គ្លេសថ្នាក់ទី៧ នៅទូទាំងប្រទេសនៅកម្ពុជា បានរកឃើញថាទោះបីជាចំនួនតួអង្គប្រុស និងតួអង្គស្រីស្ទើរតែស្មើគ្នាក៏ដោយ ប៉ុន្តែកុមារាច្រើនតែត្រូវបានពណ៌នាថាមានសមត្ថភាព ឯករាជ្យ និងផ្តោតលើសមិទ្ធផលខណៈដែលកុមារីត្រូវបានផ្សារភ្ជាប់ទៅនឹងជីវិតរស់នៅប្រចាំថ្ងៃ រូបសម្បត្តិ និងកង្វល់ក្នុងគ្រួសារ ដែលនេះជាការពង្រឹងផ្នត់គំនិតយេនឌ័រដោយប្រយោល (Phorn and Arsyad, 2022, **ប្រអប់ទី ៩** ) ។

### ប្រអប់ទី ៩. ការបង្ហាញយេនឌ័រនៅក្នុងសៀវភៅសិក្សាភាសាអង់គ្លេសនៅកម្ពុជា

ការសិក្សាមួយក្នុងឆ្នាំ ២០២២ បានវិភាគពីរបៀបដែលតួអង្គស្រី និងតួអង្គប្រុស ត្រូវបានបង្ហាញនៅក្នុងការសន្ទនាស្តាប់ (listening dialogues) នៃសៀវភៅភាសាអង់គ្លេសថ្នាក់ទី៧ (English for Cambodia Grade 7) ដែលដាក់ឱ្យប្រើប្រាស់នៅតាមសាលាមធ្យមសិក្សាទូទាំងប្រទេស។ អ្នកនិពន្ធបានធ្វើការវិភាគខ្លឹមសារបែបបរិមាណលើការសន្ទនាដែលបានជ្រើសរើសដោយចៃដន្យ ដោយពិនិត្យមើលភាពលេចធ្លោនៃតួអង្គស្រី និងតួអង្គប្រុស ប្រភេទទំនាក់ទំនងដែលពួកគេចូលរួម និងតួនាទីដែលបង្កប់ក្នុងខ្លឹមសារនៃការសន្ទនា។

ការសិក្សាបានរកឃើញថា តុល្យភាពយេនឌ័រនៅក្នុងចំនួនតួអង្គប្រុស និងតួអង្គស្រី មិនឆ្លុះបញ្ចាំងពីតុល្យភាពយេនឌ័រនៅក្នុងការបង្ហាញបំណិន និងសមត្ថភាពនោះទេ ៖

- ភាពញឹកញាប់ និងភាពលេចធ្លោ ៖ ជារួមតួអង្គប្រុស និងតួអង្គស្រី បានបង្ហាញខ្លួនក្នុងចំនួនស្ទើរតែស្មើគ្នា (ប្រុស ១២ នាក់ ស្រី ១៣ នាក់)។ ការសន្ទនាភាគច្រើនបង្ហាញពីទំនាក់ទំនងចម្រុះយេនឌ័រ (ប្រហែលបីភាគបួន) តែការសន្ទនារវាងយេនឌ័រដូចគ្នាមានតិចតួច។
- ការកំណត់ជំហរយេនឌ័រនៅក្នុងការសន្ទនា ៖ នៅពេលដែលការសន្ទនាផ្តោតលើការបង្ហាញបំណិន សមត្ថភាព ឬអ្វីដែលនរណាម្នាក់អាចធ្វើបាន ចំណុចនេះត្រូវបានបង្ហាញយ៉ាងច្រើនលើសលប់ដោយតួអង្គប្រុស។ តួអង្គស្រីច្រើនតែត្រូវបានដាក់នៅក្នុងតួនាទីអសកម្ម ឬគ្រាន់តែជាអ្នកសង្កេតការណ៍។
- ខ្លឹមសារ និងការរំពឹងទុក ៖ ជាទូទៅកុមារាត្រូវបានបង្ហាញថាមានសមត្ថភាពឯករាជ្យ និងផ្តោតលើសមិទ្ធផល ខណៈដែលកុមារីច្រើនតែត្រូវបានផ្សារភ្ជាប់ទៅនឹងជីវិតរស់នៅប្រចាំថ្ងៃ របស់សម្បត្តិ ឬកង្វល់ក្នុងគ្រួសារ។

អ្នកនិពន្ធបានលើកឡើងថាតួនាទី និងប្រធានបទតាមលំនាំទាំងនេះ បានពង្រឹងផ្នត់គំនិតយេនឌ័រដោយប្រយោលដោយចាត់ថ្នាក់កុមារាជាមនុស្សសកម្ម និងកុមារីជាមនុស្សមិនសូវមានសមត្ថភាព និងផ្តោតលើកិច្ចការផ្ទះសម្បែង។ អ្នកនិពន្ធបានសន្និដ្ឋានថាដំណើរការពិនិត្យសៀវភៅសិក្សាគួរតែពិនិត្យមើលលើសពីការបង្ហាញតែម្យ៉ាង ហើយងាកទៅពិចារណាលើរបៀបពណ៌នាអំពីកុមារី កុមារា បុរស និងស្ត្រី ដើម្បីធានាថាសម្ភារៈសិក្សាបង្ហាញយេនឌ័រទាំងពីរនៅក្នុងតួនាទី សមត្ថភាព និងបំណងប្រាថ្នាយ៉ាងទូលំទូលាយ និងប្រកបដោយ សមធម៌។

ប្រភព ៖ Phorn and Arsyad, 2022

ក្នុងការបង្ហាញបទដ្ឋាន និងផ្នត់គំនិតយេនឌ័រ (ដែលជារឿយៗ ធ្វើឡើងដោយអចេតនា) សម្ភារៈបង្រៀន និងរៀនកំពុងរួមចំណែកដល 'កម្មវិធីសិក្សាបង្កប់'។ តាមរយៈភាសា រូបភាព ឧទាហរណ៍ និងតួអង្គដែលបានបង្ហាញសម្ភារៈបង្រៀន និងរៀនអាចធ្វើឱ្យបទដ្ឋាន និងផ្នត់គំនិតយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹងក្លាយជារឿងធម្មតា សូម្បីតែនៅពេលដែលកម្មវិធីសិក្សាផ្លូវការលើកកម្ពស់សមភាពក៏ដោយ (Marcus et al., 2024) ។

គួរកត់សម្គាល់ថាមានការសិក្សាតិចតួចណាស់ដែលពិនិត្យមើលជាពិសេសទៅលើការបង្ហាញបុរស និងកុមារានៅក្នុងសម្ភារៈបង្រៀន និងរៀន ហើយមិនទាន់មានការសិក្សាណាមួយពីប្រទេសកម្ពុជានៅឡើយទេ។ គម្លាតភស្តុតាងបែបនេះគូសបញ្ជាក់ពីតម្រូវការស្រាវជ្រាវបន្ថែមនៅកម្ពុជា ដើម្បីស្វែងយល់ពីរបៀបដែលភាពជាបុរសត្រូវបានបង្ហាញនៅក្នុងឯកសារនានា និងរបៀបដែលកុមារា និងកុមារីបកស្រាយសារទាំងនេះដើម្បីឱ្យការកែសម្រួលនាពេលអនាគតអាចរួមបញ្ចូលនូវខ្លឹមសារដែលចំគោលដៅ និងផ្អែកតាមបរិបទជាក់លាក់ដែលលើកកម្ពស់ភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព។ ភស្តុតាងពីបរិបទផ្សេងទៀតបង្ហាញថា ខណៈដែលមានវឌ្ឍនភាពខ្លះៗក្នុងការបង្ហាញពីការពង្រីកតួនាទី និងលទ្ធភាពសម្រាប់កុមារី និងស្ត្រី ការពណ៌នាអំពីបុរស និងកុមារាច្រើនតែនៅដដែល ដូច្នេះវាបានពង្រឹងបទដ្ឋាននៃភាពជាបុរសដ៏តូចចង្អៀត និងហួសសម័យ (Huang and Liu, 2024; Jackson and Gee, 2005)។

ការពណ៌នាទាំងនេះនៅតែបន្តលើកកម្ពស់គំនិតដ៏តូចចង្អៀតអំពីអត្ថន័យនៃការធ្វើជាបុរស ឬកុមារា ដោយរឹតត្បិតតួនាទី និងអាកប្បកិរិយាជាច្រើន ដែលគេមើលឃើញថាអាចទទួលយកបាន និងពង្រឹងការដាក់សម្ពាធឱ្យអនុលោមតាមការរំពឹងទុកជាប្រពៃណី។ លំនាំនេះទំនងជារំលេចការងារយេនឌ័រ និងការអប់រំឱ្យកាន់តែសង្កត់ធ្ងន់លើរបៀបដែលបទដ្ឋានយេនឌ័រផ្តល់គុណវិបត្តិដល់កុមារី និងស្ត្រីដោយមានការយកចិត្តទុកដាក់តិចតួចលើរបៀបដែលបទដ្ឋានតឹងរ៉ឹងនៃភាពជាបុរស បង្កគ្រោះថ្នាក់ដល់កុមារា និងបុរសផងដែរ ( UNESCO, 2018a, 2022c)។ ការសង្កត់ធ្ងន់នេះគឺអាចយល់បាន ហើយនៅតែជារឿងចាំបាច់ ពីព្រោះកុមារី និងស្ត្រីនៅតំបន់ជាច្រើនក្នុងពិភពលោក កំពុងជួបប្រទះគុណវិបត្តិដែលបន្តកើតមាន និងច្រើនតែមានសភាពធ្ងន់ធ្ងរនៅក្នុងវិស័យអប់រំ។ ទោះជាយ៉ាងណាក៏ដោយដោយសារមានភស្តុតាងកាន់តែច្រើនដែលបង្ហាញថា ឧត្តមគតិនៃភាពជាបុរសដែលលេចធ្លោ អាចផ្ទុយគ្នានឹងអាកប្បកិរិយា និងឥរិយាបថដែលគាំទ្រដល់ការរៀនសូត្រ និងភាពជោគជ័យក្នុងការសិក្សាក៏ដូចជាភស្តុតាងកាន់តែច្រើនដែលបង្ហាញពីការដកខ្លួនពីការអប់រំរបស់កុមារានៅក្នុងបរិបទជាច្រើនសម្ភារៈបង្រៀន និងរៀន (TLMs) ត្រូវតែផ្តោតការយកចិត្តទុកដាក់ជាចម្បងលើការជេញជោលភាពជាបុរសដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង និងការលើកកម្ពស់ជម្រើសដែលវិជ្ជមាន ប្រកបដោយសុខុមាលភាព និងមានបរិយាបន្ន។

*ចំណុចសំខាន់ៗដែលត្រូវចងចាំ ៖*

- បទដ្ឋានយេនឌ័រត្រូវបានរៀនសូត្រនៅទូទាំងមជ្ឈដ្ឋានជាច្រើនរួមមាន៖ គ្រួសារ សាលារៀន សហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយ។
- សម្ភារៈបង្រៀន និងរៀន(TLMs)គឺជាប្រភពផ្តល់សារដ៏សំខាន់អំពីអ្វីដែលជារឿងធម្មតា និងអ្វីដែលអាចទៅរួចសម្រាប់គ្រប់មនុស្ស និង យេនឌ័រ រួមទាំងកុមារី កុមារា ស្ត្រី និងបុរស។
- សម្ភារៈបង្រៀន និងរៀននៅជុំវិញពិភពលោក ច្រើនតែមិនសូវបង្ហាញពី កុមារី និងស្ត្រី និងពណ៌នាមនុស្សមកពីយេនឌ័រណាមួយក្នុងលក្ខណៈចង្អៀតចង្អល់ និងបង្កប់ដោយផ្នត់គំនិតចាស់កម្រិល។
- ការបង្ហាញទាំងនេះ បង្កើតបានជាផ្នែកមួយនៃកម្មវិធីសិក្សាបង្កប់ ដែលជះឥទ្ធិពលលើបំណងប្រាថ្នារបស់សិស្ស និងការស្គាល់ខ្លួនឯង ពង្រឹងវិសមភាពយេនឌ័រ និងរួមចំណែកធ្វើឱ្យសិស្សដកខ្លួនពីការអប់រំ និងបោះបង់ការសិក្សា។
- សម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រមានគោលបំណងដេញដោលបទដ្ឋានដែលបង្កគ្រោះថ្នាក់ បង្ហាញពីបុគ្គលគំរូដែលមានលក្ខណៈចម្រុះនិងប្រកបដោយបរិយាបន្ន និងគាំទ្រដល់ការឆ្លុះបញ្ចាំងល្អិតល្អន់លើយេនឌ័រ និងអំណាច ហើយក្នុងពេលជាមួយគ្នានោះរំលេចអត្តសញ្ញាណត្រួតគ្នា និងតថភាពរបស់អ្នកសិក្សាទាំងអស់។

# ៣. ការណែនាំជាក់ស្តែង

នៅពេលបញ្ចប់ផ្នែកនេះ អ្នកអាននឹង ៖

- ✓ យល់ច្បាស់អំពីលក្ខណៈពិសេសនៃសម្ភារៈបង្រៀន និងរៀន (TLMs)ដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ។
- ✓ យល់ដឹងពីរបៀបបង្កប់ខ្លឹមសារដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រទៅក្នុងមុខវិជ្ជាផ្សេងៗ។
- ✓ យល់ដឹងពីរបៀបអនុវត្តទស្សនទានយេនឌ័រនៅទូទាំងដំណើរការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន។
- ✓ យល់ច្បាស់ពីយុទ្ធសាស្ត្រ និងឧបករណ៍អនុវត្តន៍ជាក់ស្តែង ដើម្បីកែសម្រួល និងអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនដែលលើកកម្ពស់បទដ្ឋានយេនឌ័រដែលវិជ្ជមាន និងប្រកបដោយសុខុមាលភាព។

## ៣.១ លក្ខណៈពិសេសនៃសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ

ដូចដែលបានឈ្វេងយល់នៅក្នុង ផ្នែកទី ២ សម្ភារៈបង្រៀន និងរៀន (TLMs) ដើរតួនាទីដ៏អស្ចារ្យក្នុងការ ជះឥទ្ធិពលលើផ្នត់គំនិតរបស់អ្នកសិក្សាឱ្យយល់ដឹងអំពីតួនាទី ទំនាក់ទំនង និងអត្តសញ្ញាណយេនឌ័រ។ នៅពេលដែលសម្ភារៈបង្រៀន និងរៀនត្រូវបានរៀបចំឡើងក្នុងគោលបំណងបង្ហាញពីកុមារី កុមារា ស្ត្រី និងបុរស នៅក្នុងតួនាទីយ៉ាងច្រើន និងគ្រប់លក្ខណៈចម្រុះ រួមទាំងតួនាទីដែលជញ្ជោលផ្នត់គំនិតដែលបង្គ្រោះថ្នាក់ និងរឹតត្បិត សម្ភារៈទាំងនោះនឹងអាចបើកកកាយលទ្ធភាពថ្មីៗ និងជួយពង្រីកបំណងប្រាថ្នារបស់កុមារ។

ការស្រាវជ្រាវ និងការណែនាំ គូសបញ្ជាក់ពីលក្ខណៈពិសេសនៃការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀនដូចខាងក្រោម ៖

- ✓ **ដោះស្រាយបញ្ហាយេនឌ័រនៅគ្រប់ផ្នែកទាំងអស់នៃសម្ភារៈបង្រៀន និងរៀន** រួមទាំងអត្ថបទ រូបភាព ឧទាហរណ៍ តួអង្គ និងបុគ្គលគំរូ (Commonwealth of Learning, 2019; RTI International, 2015; UNESCO, 2018b)។
- ✓ **ធានាឱ្យមានការបង្ហាញស្មើគ្នានូវមនុស្សដែលមានយេនឌ័រខុសៗគ្នានៅក្នុងអត្ថបទ និងរូបភាព** ដើម្បីរំលេចភាពចម្រុះនៃយេនឌ័រនៅក្នុងមជ្ឈដ្ឋានជាក់ស្តែង និងបញ្ចៀសការផាត់ក្រុមណាមួយចេញ (Commonwealth of Learning, 2019; RTI International, 2015; UNESCO, 2018b)។ ចំណុចនេះរួមបញ្ចូលទាំងការយកចិត្តទុកដាក់លើតុល្យភាពយេនឌ័រនៅក្នុងតួអង្គ/បុគ្គលប្រឌិត បុគ្គលគំរូដ៏ឆ្នើម និងតួអង្គក្នុងប្រវត្តិសាស្ត្រ។
- ✓ **ប្រើប្រាស់ភាសាបរិយាបន្នដែលប្រកបដោយសមធម៌យេនឌ័រ** ដោយបញ្ចៀសការប្រើប្រាស់ពាក្យដែលផាត់ចេញយេនឌ័រណាមួយ ឬពាក្យដែលចាត់ទុកបុរសជាគោល (ឧទាហរណ៍ ការប្រើពាក្យ 'បុរស-men' ដើម្បីសំដៅលើមនុស្សទាំងអស់ ឬពាក្យដែលមានលក្ខណៈយេនឌ័រ ដូចជា៖ នគរបាលប្រុស-policeman ឬស្ត្រីបោសសម្អាត(cleaning lady)

ដោយជំនួសមកវិញនូវពាក្យដែលមានបរិយាបន្ន ឬអព្យាក្រឹត យេនឌ័រជាងមុន (RTI International, 2015; UNESCO, 2009)។

- ✓ **រួមបញ្ចូលអត្ថបទ និងរូបភាពដែលគាំទ្រដល់សមធម៌ និងបរិវត្តកម្មយេនឌ័រ** ដោយបង្ហាញមនុស្សគ្រប់យេនឌ័រទាំងអស់នៅក្នុងសកម្មភាព តួនាទី និងវិជ្ជាជីវៈយ៉ាងច្រើន អមជាមួយនឹងចរិតលក្ខណៈចម្រុះ។ ចំណុចនេះគួររួមបញ្ចូលឧទាហរណ៍ដែលប្រឆាំងនឹងផ្នត់គំនិតយេនឌ័រ (ឧទាហរណ៍៖ កុមារាកំពុងអានសៀវភៅ បុរសកំពុងបំពេញតួនាទីថែទាំ ឬការងារថ្នៃប្រឌិត កុមារី និងស្ត្រីកំពុងបំពេញតួនាទីជាអ្នកដឹកនាំ និងក្នុងវិស័យ STEM) (Crawfurd et al., 2024; Marcus, 2018; Olsson and Martiny, 2018)។

- ✓ **ដោះស្រាយភាពប្រទាក់ក្រឡាគ្នា (Intersectionality) ដោយបង្ហាញពីរបៀបដែលយេនឌ័រមានទំនាក់ទំនងជាមួយទិដ្ឋភាពផ្សេងទៀតនៃអត្តសញ្ញាណ** ដូចជា ពូជសាសន៍ ស្ថានភាពសេដ្ឋកិច្ចសង្គម សមត្ថភាព និងទីតាំងភូមិសាស្ត្រ ដើម្បីកំណត់អត្តសញ្ញាណ និងបទពិសោធន៍។ គោលដៅគឺដើម្បីឱ្យអ្នកសិក្សាទាំងអស់យល់ថា ពួកគេត្រូវបានមើលឃើញ ផ្តល់តម្លៃ និងរាប់បញ្ចូល (Marcus et al., 2024; RTI International, 2015)។ ចំណុចនេះរួមបញ្ចូលទាំងការខិតខំដេញដោលផ្នត់គំនិតដែលពាក់ព័ន្ធ ឧទាហរណ៍ តាមរយៈការបង្ហាញពីកុមារដែលមានយេនឌ័រផ្សេងៗគ្នា និងមានពិការភាពចូលរួមក្នុងការលេងកីឡា ឬការបង្ហាញពីកុមារដែលមកពីតំបន់ក្រីក្រចូលរួមក្នុងការអប់រំ ។

- ✓ **ផ្តល់ឱកាសដល់អ្នកសិក្សាក្នុងការកត់សម្គាល់ និងចោទសួរអំពីបទដ្ឋានយេនឌ័រ ផ្នត់គំនិត និងឌីណាមិកអំណាច** ឧទាហរណ៍ តាមរយៈសំណួរ សកម្មភាព ឬកិច្ចការឆ្លុះបញ្ចាំងដែលពិចារណាលើរបៀបដែលបទដ្ឋានទាំងនេះត្រូវបានរៀនសូត្រ របៀបដែលវាធ្វើឱ្យប៉ះពាល់ដល់មនុស្ស និងរបៀបដេញដោលបទដ្ឋានទាំងនោះ នៅពេលវាបង្កគ្រោះថ្នាក់ (Cahill et al., 2022; Leite et al., 2025; Marcus, 2018; Mmari et al., 2023; UNGEI, 2023)។ ចំណុចនេះគួររួមបញ្ចូលឱកាសសម្រាប់ឱ្យកុមារា និងយុវជននិយាយដោយបើកចំហអំពីបទដ្ឋានយេនឌ័រ ទំនាក់ទំនងប្រកបដោយសុខុមាលភាព និងភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងឆ្លុះបញ្ចាំងពីរបៀបដែលផ្នត់គំនិត និងអំណាចបានជះឥទ្ធិពលលើអត្តសញ្ញាណ អាកប្បកិរិយា និងទស្សនៈរបស់ពួកគេផ្ទាល់ចំពោះភាពជាបុរស និងភាពជាស្ត្រី (OECD, 2019)។ គម្រោងបំណិនជីវិតសម្រាប់សមភាព (LSEP) របស់អង្គការរូមធូរីដកម្ពុជាផ្តល់ឧទាហរណ៍ជាក់ស្តែងនៃឯកសារដែលត្រូវបានរៀបចំឡើងដើម្បីបង្កើតឱកាសប្រភេទនេះ (**ប្រអប់ទី ១០**)។

- ✓ **អនុវត្តអភិក្រមផ្អែកលើចំណុចខ្លាំង** តាមរយៈការប្រើប្រាស់ឧទាហរណ៍ និងបុគ្គលគំរូវិជ្ជមានដែលលើកកម្ពស់សមភាព ការយល់ចិត្ត និងការគោរព ជាជាងការផ្តោតតែលើបញ្ហា (Lifting Barriers Educators’ Guide)។ ឧទាហរណ៍ ទន្ទឹមនឹងការគូសបញ្ជាក់ពីអាកប្បកិរិយាដែលបង្កគ្រោះថ្នាក់ (ដូចជា ការប្រព្រឹត្តអំពើហិង្សាដោយបុរស) សម្ភារៈបង្រៀន និងរៀនអាចបង្ហាញពីកុមារា និងបុរស ដែលហ៊ាននិយាយប្រឆាំងនឹងអំពើហិង្សា គាំទ្រមិត្តភក្តិ ចែករំលែកការងារថែទាំ និងស្វែងរកជំនួយ ដើម្បីជួយធ្វើឱ្យអាកប្បកិរិយាវិជ្ជមានក្លាយជារឿងធម្មតា និងទទួលបានការសាទរ។

### ប្រអប់ទី ១០. គម្រោងបំណិនជីវិតសម្រាប់សមភាព (LSEP) របស់អង្គការរូមធូរីដកម្ពុជា

គម្រោងបំណិនជីវិតសម្រាប់សមភាព (LSEP) របស់អង្គការរូមធូរីដកម្ពុជា គឺជាគម្រោងសាកល្បងរយៈពេលពីរឆ្នាំដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រ សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី ៧-៨)។ គម្រោងនេះត្រូវបានអនុវត្តនៅតាមសាលារដ្ឋដែលបានជ្រើសរើសក្នុងខេត្តចំនួនពីរ និងធ្វើការជាមួយកុមារា (ដោយមានវគ្គខ្លះត្រូវបានរៀបចំឡើងជាមួយកុមារា និងកុមារីរួមបញ្ចូលគ្នា) ដើម្បីពង្រឹងបំណិនជីវិតសំខាន់ៗ ហើយទន្ទឹមនឹងនោះ ខិតខំដោះស្រាយតួនាទីយេនឌ័រ បទដ្ឋាន និងទំនាក់ទំនងអំណាច។ កម្មវិធីនេះមានគោលបំណងបំពាក់បំប៉នកុមារានូវបំណិនជីវិតចាំបាច់ គាំទ្រដល់អាកប្បកិរិយា និងឥរិយាបថដែលកាន់តែមានសមធម៌យេនឌ័រ និងបង្កើតបរិយាកាសសាលារៀនដែលកាន់តែមានបរិយាបន្ន។

កម្មវិធីសិក្សាមាន ៣៤ វគ្គដែលត្រូវបានរៀបចំជាផ្នែកៗសម្រាប់រយៈពេលពីរឆ្នាំ និងត្រូវបានបង្រៀនពីរដងក្នុងមួយខែដោយលោកគ្រូអ្នកគ្រូផ្ទាល់ និងអ្នកសម្របសម្រួលដែលទទួលបានការបណ្តុះបណ្តាល។ វគ្គទាំងនេះបំពេញបន្ថែមដោយសៀវភៅលំហាត់សិស្ស និងសៀវភៅណែនាំអ្នកសម្របសម្រួល/គ្រូ បូករួមនឹងកញ្ចប់សម្ភារៈបណ្តុះបណ្តាលសម្រាប់គ្រូ និងមាតាបិតាសិស្ស។ ខ្លឹមសារត្រូវបានរៀបចំឡើងក្នុងគោលបំណងគាំទ្រដល់បរិវត្តកម្មយេនឌ័រ ដោយគ្របដណ្តប់លើប្រធានបទនានា ដូចជា តួនាទីយេនឌ័រ និងការបែងចែកការងារ ភាពជាបុរស និងទំនាក់ទំនង ភាពពេញវ័យ សុខភាព និងផ្លូវភេទ ការទប់ស្កាត់ការបៀតបៀន និងជម្លោះ ចំណេះដឹងអំពីផ្លូវចិត្ត និងសុខភាពផ្លូវចិត្ត និងភាពជោគជ័យក្នុងការសិក្សា និងជីវិត។ សកម្មភាពរួមមានលំហាត់ឆ្លុះបញ្ចាំងតាមបែប 'ប្រអប់បុរស' (man box) ការសម្តែងតួ និងការពិភាក្សាជាក្រុម ដែលជួយឱ្យសិស្សបានស្គាល់ និងចោទសួរការរំពឹងទុកដែលបង្កគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងភាពជាបុរស និងភាពជាស្ត្រី និងស្វែងរកជម្រើសដែលវិជ្ជមាន និងមានសមធម៌ជាងមុន។

ឯកសាររបស់គម្រោង LSEP ត្រូវបានអភិវឌ្ឍឡើងតាមរយៈដំណើរការជាដំណាក់កាល ដែលត្រូវបានរៀបចំឡើងដើម្បីបញ្ជ្រាបទស្សនទានយេនឌ័រតាំងពីដើមទី។ ដំណើរការនេះរួមបញ្ចូលទាំងការស្រាវជ្រាវបឋម (formative research) ស្តីពីបទពិសោធន៍របស់កុមារា និងបទដ្ឋាននៃភាពជាបុរសនៅក្នុងមូលដ្ឋាន ការសរសេរព្រាងកម្មវិធីសិក្សា និងការគូសផែនទីលទ្ធផលសិក្សា របៀបវារៈនៃការរៀនសូត្រពីការតាមដាន និងវាយតម្លៃ សិក្ខាសាលាស្តីពីការកំណត់បរិបទ និងការបកប្រែសម្រាប់ប្រទេសកម្ពុជា ការបណ្តុះបណ្តាលបញ្ជ្រាបការយល់ដឹងអំពីយេនឌ័រសម្រាប់អ្នកសម្របសម្រួល និងគ្រូ និងការបណ្តុះបណ្តាលអ្នកសម្របសម្រួល/គ្រូដែលបានធ្វើ តេស្តសាកល្បងនៅតាមមូលដ្ឋាន។ ការងារនេះត្រូវបានសហការរៀបចំជាមួយអង្គការ Equimundo និងអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) និងបន្ទាប់មកត្រូវបានកំណត់បរិបទដោយក្រុមការងារអង្គការរូមធូរីដ។ កម្មវិធីនេះក៏រួមបញ្ចូលនូវក្លឹបបំណិនជីវិតដែលផ្តល់នូវចន្លោះសុវត្ថិភាពសម្រាប់ឱ្យសិស្សអនុវត្តអ្វីដែលពួកគេបានរៀន ការបណ្តុះបណ្តាលគ្រូ(រួមទាំងការគាំទ្រ

ដល់ការបញ្ជ្រាបការយល់ដឹងអំពីយេនឌ័រ និងគុរុកោសល្យ) និងការរៀបចំកិច្ចប្រជុំជាមួយមាតាបិតាសិស្ស ដើម្បីពង្រឹងសារសំខាន់ៗស្តីពីសមភាពយេនឌ័រនៅផ្ទះ។

ការស្រាវជ្រាវរបស់អង្គការរូមធូរីដ បង្ហាញថា គម្រោង LSEP បានបង្ហាញលទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការជំរុញសមភាពយេនឌ័រក្នុងចំណោមភាគីពាក់ព័ន្ធ រួមមានអ្នកចូលរួម មាតាបិតាសិស្ស និងអ្នកសម្របសម្រួល និងការលើកកម្ពស់បំណិនជីវិតក្នុងចំណោមអ្នកចូលរួម។ ការវាយតម្លៃបង្ហាញពីប្រសិទ្ធភាពរបស់កម្មវិធីនេះក្នុងការធ្វើឱ្យប្រសើរឡើងដល់លទ្ធផលសិក្សា និងចិត្តសង្គមសម្រាប់អ្នកចូលរួម ហើយទន្ទឹមនឹងនោះក៏ពង្រឹងសមត្ថភាពរបស់គ្រូ និងមាតាបិតាសិស្សផងដែរ។ ជាមួយនឹងអនុសាសន៍យ៉ាងច្បាស់លាស់សម្រាប់ការពង្រីកបន្ថែមទៀត កម្មវិធីនេះមានជំហររឹងមាំក្នុងការពង្រីកវិសាលភាពរបស់ខ្លួន និងបន្តបង្កើតឱ្យមានផលជះប្រកបដោយអត្ថន័យក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការអប់រំបំណិនជីវិតនៅកម្ពុជា និងនៅប្រទេសផ្សេងទៀត។ កម្មវិធីនេះបង្ហាញថាការច្របាច់បញ្ចូលគ្នានូវសម្ភារៈបង្រៀន និងរៀនដែលត្រូវបានរៀបចំឡើងយ៉ាងយកចិត្តទុកដាក់ គុរុកោសល្យបែបជំរុញការចូលរួម និងការចូលរួមពីច្រើនកម្រិត កំពុងជួយឱ្យកុមារាកសាងចំណេះដឹង និងបំណិន ដើម្បីគាំទ្រដល់សមភាពយេនឌ័រ អនុវត្តសមភាពយេនឌ័រនៅក្នុងទំនាក់ទំនងរបស់ពួកគេ និងមានអារម្មណ៍ជឿជាក់ និងចូលរួមក្នុងការសិក្សាកាន់តែច្រើនហើយទន្ទឹមនឹងនោះក៏គូសបញ្ជាក់ផងដែរពីចំណុចដែលការកែសម្រួល និងការពង្រីកបន្ថែម អាចពង្រឹងការរួមចំណែករបស់កម្មវិធីនេះដល់ការដោះស្រាយបញ្ហានៃការដកខ្លួនចេញពីការអប់រំរបស់កុមារា។




ប្រភព ៖ បទបង្ហាញពីលោកស្រី នាដ ប៊ុណ្ណា មន្ត្រីកម្មវិធីជាន់ខ្ពស់នៃអង្គការរូមធូរីដ; CDRI et al., 2025.

## ៣.២ ការបញ្ជ្រាបខ្លឹមសារដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រនៅក្នុងមុខវិជ្ជានានា

ជាទូទៅ ការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀន (TLMs) ត្រូវបានអភិវឌ្ឍឡើងសម្រាប់មុខវិជ្ជាដែលមានគោលដៅសិក្សាច្បាស់លាស់ទាក់ទងនឹងយេនឌ័រ និងអំណាច ឧទាហរណ៍ ៖ ការអប់រំផ្លូវភេទនៅក្នុង បំណិនជីវិត ការអប់រំអំពីទំនាក់ទំនងប្រកបដោយការគោរព និងគំនិតផ្តួចផ្តើមផ្សេងទៀតដែលមានបំណងដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រ (GBV)។ មានភស្តុតាងច្បាស់លាស់ដែលបញ្ជាក់ថា មុខវិជ្ជាទាំងនេះមានប្រសិទ្ធភាពក្នុងការសម្រេចបានគោលដៅរបស់ខ្លួន (ឧ. អាកប្បកិរិយាប្រកបដោយសមធម៌យេនឌ័រ ការកាត់បន្ថយអំពើហិង្សា សុខភាពផ្លូវភេទជាដើម) លុះត្រាតែមុខវិជ្ជាទាំងនោះខិតខំជួយឱ្យសិស្សបានស្គាល់ និងដេញដោលបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងយល់ដឹងអំពីឥទ្ធិពលនៃអំណាច (Haberland, 2015; Lameiras-Fernández et al., 2021)។

បន្ថែមពីនេះ អភិក្រមគ្រប់ជ្រុងជ្រោយគួរតែមានការបញ្ជ្រាបពីការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀនទៅក្នុងមុខវិជ្ជាទាំងអស់ (UNGEI et al., 2018)។ ខណៈដែលការបញ្ជ្រាបបែបនេះអាចមានភាពស្មុគស្មាញខ្លាំង និងទាមទារការយល់ដឹង និងការគាំទ្រពីអ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកអភិវឌ្ឍន៍ធនធានមកពីផ្នែកកម្មវិធីសិក្សាផ្សេងៗ ការធ្វើដូច្នេះមានសារៈសំខាន់ណាស់ព្រោះមានភស្តុតាងជាច្រើនបង្ហាញថាសម្ភារៈបង្រៀន និងរៀននៅក្នុងមុខវិជ្ជាជាច្រើនមានភាពលម្អៀងយេនឌ័រហើយថែមទាំងពង្រឹងនិងបង្កើតឡើងវិញនូវបទដ្ឋាននិងផ្នត់គំនិតយេនឌ័រដែលបង្កគ្រោះថ្នាក់ទៀតផង (សូមមើល ផ្នែកទី ២)។

ការដាក់បញ្ចូលអភិក្រមបរិវត្តកម្មយេនឌ័រទៅក្នុងកម្មវិធីសិក្សាទាំងមូល នឹងមានន័យថាជាការពង្រឹងតម្លៃ បរិយាបន្ន និងការបង្ហាញយេនឌ័រចម្រុះ នៅក្នុងបទពិសោធន៍រៀនសូត្រទាំងមូល។ ឧទាហរណ៍អំពីរបៀបដែលមុខវិជ្ជាផ្សេងៗអាចលើកឡើងពីយេនឌ័រ មានបង្ហាញក្នុង**តារាងទី ២**។

តារាងទី ២. ឧទាហរណ៍នៃរបៀបដែលមុខវិជ្ជាផ្សេងៗអាចជួយឱ្យអ្នកសិក្សាគិតពិចារណាអំពីយេនឌ័រ

| មុខវិជ្ជា | តើយេនឌ័រមានភាពពាក់ព័ន្ធដោយរបៀបណា? | តើយេនឌ័រអាចត្រូវបានលើកឡើងយ៉ាងជាក់ច្បាស់តាមរបៀបណា? |
|---|---|---|
| អក្ខរកម្ម អក្សរសិល្ប៍ និងភាសា (ឧ. ភាសាខ្មែរ/អង់គ្លេស) | អំណានអាចត្រូវបានគេមើលឃើញថាជាសកម្មភាពរបស់ស្ត្រី ឬ 'មិនសូវមានលក្ខណៈជាបុរស' ដែលបង្កផលវិបាកដល់អក្ខរកម្មរបស់កុមារ(សូមមើល ផ្នែកទី ២)។<br><br>ជារឿយៗ អក្សរសិល្ប៍បែបប្រពៃណីពង្រឹងបទដ្ឋាន និងផ្នត់គំនិតយេនឌ័រតាមរយៈតួអង្គ តួនាទី និងរឿងរ៉ាវ។<br><br>អក្សរសិល្ប៍ក៏អាចបង្អាក់បទដ្ឋាន និងផ្នត់គំនិតយេនឌ័រផងដែរ តាមរយៈការបង្ហាញតួអង្គ/រឿងរ៉ាវ ដែលជេញដោលតួនាទី សកម្មភាព និងគន្លងបែបប្រពៃណី សម្រាប់មនុស្សដែលមានយេនឌ័រខុសៗគ្នា។ | បង្កើតអន្តរាគមន៍នានាដើម្បីលើកទឹកចិត្ត និងអបអរសាទរកុមារដែលអាន/សរសេរ និង/ ឬជំរុញឱ្យអ្នកថែទាំជាបុរសអានសៀវភៅជាមួយកុមារ។<br><br>ស្នើឱ្យសិស្សវិភាគអក្សរសិល្ប៍ប្រជាប្រិយ៍ដើម្បីរកមើលបទដ្ឋាននិងផ្នត់គំនិតយេនឌ័រនិងពិចារណាពីរបៀបដែលវាធ្វើឱ្យប៉ះពាល់ដល់មនុស្សដែលមានយេនឌ័រខុសៗគ្នានិងរបៀបផ្លាស់ប្តូរបទដ្ឋាននិងផ្នត់គំនិតទាំងនោះ។<br><br>ខិតខំស្វែងរក និងបង្ហាញនូវអក្សរសិល្ប៍ដែលជេញដោលបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង ព្រមទាំងយេនឌ័រដែលដូចគ្នា។ ផ្តល់ឱកាសឱ្យសិស្សស្វែងយល់ពីរបៀបដែលការធ្វើបែបនេះជួយពង្រីកលទ្ធភាពសម្រាប់មនុស្សគ្រប់រូប។ |
| គណិតវិទ្យា | បទដ្ឋានយេនឌ័រ អាចធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្ត និងចំណាប់អារម្មណ៍របស់សិស្សលើគណិតវិទ្យា (ឧ. នៅកម្ពុជាកុមារីច្រើនតែរៀនពូកែដូច ឬពូកែជាងកុមារា នៅថ្នាក់ទាបៗ ប៉ុន្តែរៀនខ្សោយជាងកុមារានៅថ្នាក់ខ្ពស់ៗ)។<br><br>សកម្មភាពក្នុងថ្នាក់រៀនអាចផ្តល់ឱកាស ដោយប្រយោលនិងច្រើនជាងមុន ឱ្យកុមារាបានឆ្លើយសំណួរ និងចូលរួម តាមមធ្យោបាយផ្សេងៗ ដែលអាចជួយបង្កើនទំនុកចិត្តកុមារា ធ្វើដូចនេះយូរទៅ ក៏ជួយបង្កើនកម្រិតទំនុកចិត្ត ចំណាប់អារម្មណ៍ និងការចូលរួមរបស់ | ផ្តល់ឱកាសឱ្យសិស្សពិចារណាថា តើហេតុអ្វីបានជាកុមារី និងស្ត្រី អាចស្ទាក់ស្ទើរចិត្តមិនចង់រៀនគណិតវិទ្យាឬដើរតាមគន្លងអាជីពដែលពាក់ព័ន្ធនឹងគណិតវិទ្យានិងវិទ្យាសាស្ត្រ។<br><br>រៀបចំសំណួរដែលរួមបញ្ចូលទិន្នន័យគូសបញ្ជាក់ពីវិសមភាពយេនឌ័រនៅក្នុងពិភពជាក់ស្តែង (ឧ. គម្លាតប្រាក់ឈ្នួលតាមយេនឌ័រ ភាពជាតំណាងនៅក្នុងអាជីពSTEM ភាពជាតំណាងនៅក្នុងតំណែងជាអ្នកដឹកនាំ)។<br><br>បញ្ចូលឧទាហរណ៍របស់ស្ត្រីដែលមានស្នាដៃឆ្នើមផ្នែកគណិតវិទ្យា និងអាជីពពាក់ព័ន្ធ ដើម្បី ផ្តល់ជាគំរូនៃអ្វីដែលអាចទៅរួចនិងពង្រីកបំណងប្រាថ្នារបស់ពួកគេ។ |

| | | |
|---|---|---|
| | កុមារីដែរ ។<br><br>គេច្រើនតែយល់ថា ការសិក្សាឬអាជីពដែលពាក់ព័ន្ធនឹងគណិតវិទ្យា គឺជាវិស័យដែលគ្រប់ដណ្តប់ដោយបុរស។ | |
| ប្រវត្តិវិទ្យា | ប្រវត្តិសាស្ត្រ ច្រើនតែមើលរំលងស្ត្រី ដោយផ្តោតលើនិទានកថា ដែលគ្រប់ដណ្តប់ដោយបុរស ហើយមិនទទួលស្គាល់ ឬចងក្រងពីសមិទ្ធផលរបស់ស្ត្រីឡើយ។<br><br>ប្រវត្តិសាស្ត្រចងក្រងឯកសារអំពីរបៀបដែលបទដ្ឋាន និងការរំពឹងទុកបានប្រែប្រួលទៅតាមពេលវេលា និងបើកឱកាសសម្រាប់មនុស្សផ្សេងៗគ្នា ប៉ុន្តែទន្ទឹមនឹងនោះ នៅបន្តជិះជាន់អ្នកដទៃ។ | ឱ្យសិស្សឆ្លុះបញ្ចាំងល្អិតល្អន់ ថាតើហេតុអ្វីបានជាមនុស្សមួយចំនួនត្រូវបានគេចងក្រងជីវៈប្រវត្តិ និងទទួលបានការលើកតម្កើងនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្រ និងថាតើអ្នកណាខ្លះដែលត្រូវបានមើលរំលង។<br><br>បង្កើតឱកាសឱ្យសិស្សបានសិក្សា អំពីថាតើមានការប្រែប្រួលបទដ្ឋាន អាកប្បកិរិយា និងឱកាសដូចម្តេចខ្លះសម្រាប់កុមារី និងកុមារា បុរស និងស្ត្រី ពីពេលមួយទៅពេលមួយ និងថាតើអ្វីទៅដែលនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។ |

| | | |
|---|---|---|
| សិក្សាសង្គម និងការអភិវឌ្ឍ (រួមទាំងការសិក្សាអំពីសាសនា) | ការសិក្សាអំពីការអភិវឌ្ឍ អាចផ្តល់ឱកាសជាក់លាក់ ដើម្បីស្វែងយល់ពីយេនឌ័រ និងវិសមភាព រួមទាំងថាតើអ្នកណាទទួលបានអត្ថប្រយោជន៍និងអ្នកណាទទួលគុណវិបត្តិ។<br><br>ការបង្រៀនសាសនា និងគំនិតសីលធម៌ដែលលេចធ្លោ អាចជះឥទ្ធិពលលើគំនិតអំពីតួនាទី និងទំនាក់ទំនងយេនឌ័រ។ទាំងនេះអាចពង្រឹងឬប្រឈមនឹងបទដ្ឋាន យេនឌ័រដែលបង្កគ្រោះថ្នាក់។ | រួមបញ្ចូលករណីសិក្សា ដែលវិភាគអំពីវិសមភាពយេនឌ័រនៅក្នុងបរិបទផ្សេងៗ (ឧ. ការអប់រំ ការងារ តួនាទីក្នុងគ្រួសារ ការប្រឡូកក្នុងឆាកនយោបាយ)។<br><br>ប្រើប្រាស់សកម្មភាពក្នុងថ្នាក់ ដែលជំរុញសិស្សឱ្យពិនិត្យមើលរបៀបដែលបទដ្ឋាននិងស្ថាប័នសង្គមពង្រឹងតួនាទីយេនឌ័រ។<br><br>បញ្ចូលស្ថិតិដែលបែងចែកតាមភេទ និងកត្តាប្រទាក់ក្រឡាគ្នាផ្សេងទៀត ដូចជា សមត្ថភាព ស្ថានភាពសេដ្ឋកិច្ចសង្គម ឬទីតាំងភូមិសាស្ត្រ ដើម្បីច្បាមយករបៀប ដែលយេនឌ័រមានទំនាក់ទំនងជាមួយសញ្ញាសម្គាល់អត្តសញ្ញាណ ផ្សេងទៀតដើម្បីចែករំលែកបទពិសោធន៍ និង លទ្ធផល។<br><br>លើកទឹកចិត្តឱ្យសិស្សសិក្សា អំពីផលប៉ះពាល់នៃបទដ្ឋានយេនឌ័រនៅក្នុងជីវិត ឬសហគមន៍របស់ពួកគេផ្ទាល់។<br><br>ស្វែងយល់ពីការបង្រៀន និងតម្លៃសាសនាដែលលើកកម្ពស់សមភាពយេនឌ័រ។<br><br>លើកទឹកចិត្តឱ្យមានការឆ្លុះបញ្ចាំងល្អិតល្អន់ លើរបៀបដែលការបង្រៀនសាសនា ស្តីពីសីលធម៌ទូទៅ អាចគាំទ្រដល់ទំនាក់ទំនងប្រកបដោយការគោរពនិងអាកប្បកិរិយាប្រកបដោយ បរិយាបន្ន។ |
| វិទ្យាសាស្ត្រកម្រិតមូលដ្ឋាន | តាំងពីដើមមក វិស័យវិទ្យាសាស្ត្រ គ្របដណ្តប់ដោយបុរស ហើយទោះបីជាបច្ចុប្បន្ន កុមារីជាច្រើនទទួលបានពិន្ទុខ្ពស់ ក្នុងការវាយតម្លៃវិទ្យាសាស្ត្រក៏ដោយ ក៏ពួកគេនៅតែមានចំនួនតិចនៅក្នុងការសិក្សាជំនាញ STEM និងអាជីពក្រោយពេលរៀនចប់។ | ផ្តល់ឱកាសឱ្យសិស្សពិចារណា ថាតើហេតុអ្វីបានជាកុមារី និងស្ត្រី អាចមានចិត្តស្ទាក់ស្ទើរមិនចង់រៀនវិទ្យាសាស្ត្រ ឬដើរតាមគន្លងអាជីពដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ។<br><br>បញ្ចូលឧទាហរណ៍នៃមនុស្សគ្រប់យេនឌ័រដែលមានស្នាដៃឆ្នើមក្នុងអាជីពវិទ្យាសាស្ត្រ និងអាជីពពាក់ព័ន្ធដើម្បីផ្តល់ជាគំរូនៃអ្វី ដែលអាចទៅរួចនិងពង្រីកបំណងប្រាថ្នារបស់ពួកគេ។ |

| | | |
|---|---|---|
| អប់រំកាយ និងកីឡា | បទដ្ឋានយេនឌ័រ ជះឥទ្ធិពលលើការចូលរួមលេងកីឡា ការរំពឹងទុកលើការអភិវឌ្ឍរាងកាយ និងការយល់ឃើញ ថាតើរូបរាងបែបណាជារូបរាងសមសួន (body image)។ | បញ្ចៀសការពង្រឹងការបែងចែកយេនឌ័រ ឬការចាត់ថ្នាក់កីឡាមួយចំនួនថា ជាកីឡាសម្រាប់តែ 'បុរស' ឬសម្រាប់តែ 'នារី'។<br>បង្ហាញឧទាហរណ៍នៃរូបភាពមនុស្ស មានយេនឌ័រខុសៗគ្នាដែលកំពុងចូលរួមលេងកីឡា ដែលតាមធម្មតា មិនផ្សារភ្ជាប់នឹងយេនឌ័ររបស់ពួកគេ។<br>លើកឡើងពីរបៀប ដែលបទដ្ឋានយេនឌ័រអាចជះឥទ្ធិពលលើការយល់ឃើញថាតើរូបរាងបែបណាជារូបរាងសមសួន (body image) សម្រាប់មនុស្សដែលមានយេនឌ័រខុសៗគ្នា និងឱ្យសិស្សពិចារណា ថាតើគេអាចបង្អាក់ឬកែលម្អបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ដោយរបៀបណា។ |
| ការអប់រំសិល្បៈ | បទដ្ឋានយេនឌ័រ ជះឥទ្ធិពលលើកិច្ចការច្នៃប្រឌិត និងតួនាទីណាដែលគេមើលឃើញថាស័ក្តិសមសម្រាប់កុមារី និងកុមារា (ឧ.គេមើលឃើញថា ទម្រង់សិល្បៈខ្លះ ស័ក្តិសមនឹងបុរសជាង ហើយទម្រង់សិល្បៈខ្លះទៀតស័ក្តិសមនឹងស្ត្រីជាង)។ ខ្លឹមសារសិល្បៈ និងសម្ភារៈក្នុងថ្នាក់រៀន ក៏អាចពង្រឹង ឬដេញដោលផ្នត់គំនិតយេនឌ័រផងដែរ តាមរយៈថាតើរឿងរ៉ាវរបស់នរណា ដែលត្រូវបានបង្ហាញឡើង និងថាតើមនុស្ស/តួអង្គត្រូវបានពណ៌នាដោយរបៀបណា។ | ឱ្យសិស្សវិភាគរូបភាព ចម្រៀង រឿង ការសម្តែង និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីស្វែងរកសារទាក់ទងនឹងយេនឌ័រ (ឧ. ផ្នត់គំនិត អំណាច តួនាទី និងថាតើបាត់ឬខ្វះសំឡេងរបស់នរណាខ្លះ) និងពិភាក្សាពីផលប៉ះពាល់របស់វា។<br>រួមបញ្ចូលសិល្បករចម្រុះ(ភាពចម្រុះនៃយេនឌ័រ និងអត្តសញ្ញាណផ្សេងទៀត)។<br>ជួយដល់សិស្សក្នុងការបង្កើតស្នាដៃសិល្បៈ ឬការបង្ហាញមតិ យោបល់ប្រកបដោយការច្នៃប្រឌិត ដែលលើកកម្ពស់ភាពយុត្តិធម៌ព្រមទាំងបទដ្ឋានយេនឌ័រដែលវិជ្ជមាន និងប្រកបដោយសុខុមាលភាព។ |
| ការអប់រំផ្លូវភេទនៅក្នុងបំណិនជីវិត | យេនឌ័រ ជះឥទ្ធិពលលើលទ្ធផល សុខភាព អាកប្បកិរិយាស្វែងរកជំនួយ និងបទពិសោធន៍នៃការទទួលរងអំពើហិង្សា។ | ផ្តល់ការអប់រំផ្លូវភេទនៅក្នុងបំណិនជីវិតដែលបង្រៀនអំពីបទដ្ឋានយេនឌ័រ របៀបដែលវាប៉ះពាល់ដល់មនុស្សដែលមានយេនឌ័រខុសៗគ្នា របៀបដែលវាផ្សារភ្ជាប់នឹងទំនាក់ទំនង ការយល់ព្រម និងការស្វែងរកជំនួយ និងរបៀបដែលគេអាចដេញដោល និងជំនះបទដ្ឋានយេនឌ័រ នៅពេលវាបង្កគ្រោះថ្នាក់។ |

*ប្រភព ៖* អ្នកនិពន្ធ

បទដ្ឋានយេនឌ័រត្រូវបានបង្ហាញឡើងខុសគ្នានៅក្នុងមុខវិជ្ជាផ្សេងៗ។ ក្នុងមុខវិជ្ជាមនុស្សសាស្ត្រ និងសិល្បៈជារឿយៗ គេអាចមើលឃើញបទដ្ឋានយេនឌ័រនៅក្នុងរឿងរ៉ាវ ភាសា និងភាពជាតំណាង។ ក្នុងគណិតវិទ្យា និងវិទ្យាសាស្ត្រ បទដ្ឋានយេនឌ័រច្រើនតែត្រូវបានបង្កប់ក្នុងលក្ខណៈប្រយោលរួមមានៈការអនុវត្តគរុកោសល្យ បរិបទនៃការសិក្សា និងការរំពឹងទុកចំពោះសមត្ថភាព និងការចូលរួម។

## ៣.៣ គោលការណ៍នៃការអនុវត្តល្អទាក់ទងនឹងដំណើរការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន

ទោះបីជាការកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់ឬការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនថ្មីដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រក៏ដោយ ការស្រាវជ្រាវ និងបទពិសោធន៍ពីបណ្តាប្រទេសនានា បានចង្អុលបង្ហាញគោលការណ៍គន្លឹះនៃការអនុវត្តល្អបំផុតទាក់ទងនឹងដំណើរការនេះ ដូចខាងក្រោមៈ

*មានការចូលរួមពីភាគីពាក់ព័ន្ធចម្រុះ*

ការទាញយកទស្សនៈចម្រុះ ជួយធានាថា គោលបំណងចុងក្រោយគឺសម្ភារៈបង្រៀន និងរៀនតំណាងឱ្យមនុស្ស ដែលមានតួនាទីនិងបទពិសោធន៍យ៉ាងទូលំទូលាយ និងប្រកបដោយបរិយាបន្ន (UNESCO, 2018b)។ ទន្ទឹមនឹងបុគ្គលិកនៃក្រសួងពាក់ព័ន្ធ (ឧ. អ្នកឯកទេសកម្មវិធីសិក្សា) ប្រការដែលល្អបំផុតគួរតែមានរួមបញ្ចូលតំណាងគ្រូបង្រៀន និងសហគមន៍ផងដែរ។ ការខិតខំសម្រេចបានតុល្យភាពយេនឌ័រក្នុងចំណោមអ្នកអភិវឌ្ឍន៍ខ្លឹមសារ វិចិត្រករ អ្នកកែសម្រួល និងអ្នកត្រួត ពិនិត្យគឺជារឿងសំខាន់ព្រោះការស្រាវជ្រាវបានបង្ហាញថា នៅពេលដែលស្ត្រីត្រូវបានផាត់ចេញ សម្ភារៈបង្រៀន និងរៀនទំនងជាបង្កើតឡើងវិញនូវភាពលម្អៀងយេនឌ័រនិងការបង្ហាញដែលបង្កប់ដោយផ្នត់គំនិតចាស់កម្រិល (Denis, 2020; Merawi, 2020)។

*បណ្តុះបណ្តាលអ្នកដែលពាក់ព័ន្ធក្នុងការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន*

អ្នកដែលពាក់ព័ន្ធក្នុងការត្រួតពិនិត្យ ឬអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន (TLMs) រួមទាំងអ្នកនិពន្ធ អ្នកត្រួតពិនិត្យ វិចិត្រករ និងបុគ្គលិកមកពីក្រុមហ៊ុនបោះពុម្ពឯកជននឹងមានកម្រិតការយល់ដឹងខុសៗគ្នាអំពីយេនឌ័រ។ ដូច្នេះការវិនិយោគលើការបណ្តុះបណ្តាលឲ្យយល់ដឹងអំពីយេនឌ័រជាប្រចាំគឺជារឿងចាំបាច់ (Denis, 2020; Merawi, 2020; UNESCO, 2020) ។ ការបណ្តុះបណ្តាលគួរតែពន្យល់ពីមូលហេតុដែលខ្លឹមសារប្រកបដោយបរិវត្តកម្មយេនឌ័រមានសារៈសំខាន់ របៀបដែលវាផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សា និងផ្តល់នូវយុទ្ធសាស្ត្រជាក់ស្តែងសម្រាប់ការអនុវត្តទស្សនទានយេនឌ័រនៅក្នុងដំណើរការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនទាំងមូល ។ ការបណ្តុះបណ្តាលគួររៀបចំឡើងជាផ្នែកមួយនៃដំណើរការជាប្រចាំ និងអាចធ្វើឡើងវិញបាន (មិនមែនដំណើរការធ្វើតែម្តងចប់)ដោយទទួលស្គាល់ថាសមាសភាពនៃក្រុមត្រួត ពិនិត្យនិងអភិវឌ្ឍន៍សម្ភារៈបង្រៀននិងរៀននឹងប្រែប្រួលទៅតាមពេលវេលា ។

*ជំរុញការចូលរួមគាំទ្រពីថ្នាក់ដឹកនាំ (អ្នកមានសិទ្ធអំណាច)*

ការគាំទ្រពីថ្នាក់ដឹកនាំ និងអ្នកធ្វើសេចក្តីសម្រេចចិត្តមានសារៈសំខាន់ណាស់ចំពោះការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀន។ ការប្តេជ្ញាចិត្តផ្នែកគោលនយោបាយចំពោះសមភាពយេនឌ័រ មិនសុទ្ធតែមានន័យថាជាការគាំទ្រពិតប្រាកដនៅក្នុងការអនុវត្តនោះទេ (Denis, 2020)។ ការតស៊ូមតិគួរតែគូសបញ្ជាក់ពីគ្រោះថ្នាក់ដែលបណ្តាលមកពីសម្ភារៈបង្រៀន និងរៀនដែលពង្រឹងផ្នត់គំនិតយេនឌ័រ និងបង្ហាញពីរបៀបដែលអភិក្រមបរិវត្តកម្មយេនឌ័រអាចធ្វើឱ្យប្រសើរឡើងដល់ការរៀនសូត្រ និងលទ្ធផលសិក្សាដ៏ទូលំទូលាយ។

*រក្សាការទទួលខុសត្រូវរបស់អ្នកអភិវឌ្ឍន៍ខ្លឹមសារ*

បញ្ចូលការទទួលខុសត្រូវច្បាស់លាស់លើខ្លឹមសារប្រកបដោយបរិវត្តកម្មយេនឌ័រទៅក្នុងគ្រប់ដំណើរការទាំងអស់នៃការអភិវឌ្ឍនិងការកែសម្រួលសម្ភារៈបង្រៀននិងរៀនរួមទាំងដំណើរការដែលប្រគល់សិទ្ធិទៅឱ្យគ្រឹះស្ថានបោះពុម្ពផ្សាយឯកជនផងដែរ (Denis, 2020; UNESCO, 2020)។ ការទទួលខុសត្រូវនេះអាចរួមបញ្ចូលលក្ខណៈវិនិច្ឆ័យយេនឌ័រជាក់លាក់នៅក្នុងលក្ខខណ្ឌប្រតិបត្តិការ កាតព្វកិច្ចតាមកិច្ចសន្យាចែងពីការងារ និងដំណើរការត្រួតពិនិត្យពីខាងក្រៅឬដោយឯករាជ្យ។

*ដាក់បញ្ចូលទៅក្នុងអភិក្រមបរិវត្តកម្មយេនឌ័រដ៏ទូលំទូលាយ*

ការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀន មានសារៈសំខាន់ប៉ុន្តែវាមិនអាចបង្កើតឱ្យមានការផ្លាស់ប្តូរដោយខ្លួនឯងបានទេ។ សម្ភារៈបង្រៀន និងរៀនបែបនេះមានឥទ្ធិពលកាន់តែខ្លាំងនៅពេលវាស្ថិតនៅក្នុងប្រព័ន្ធអប់រំដ៏ទូលំទូលាយ ដែលគាំទ្រដល់សមភាពយេនឌ័រ និងបរិយាបន្ន (Plan International et al., 2021)។ ការងារនេះទាមទារឱ្យមានសកម្មភាពសម្របសម្រួលនៅទូទាំងចំណុចចាប់ផ្តើមផ្សេងៗគ្នានៅក្នុងសាលារៀន និងនៅកម្រិតប្រព័ន្ធ។ ផ្នែកទី ៤ ផ្តល់នូវឧទាហរណ៍នៃសកម្មភាពដែលអាចគាំទ្រដល់អភិក្រមដ៏ទូលំទូលាយនេះ។

## **៣.៤ ការអនុវត្តទស្សនទានយេនឌ័រចំពោះដំណើរការកែសម្រួល/អភិវឌ្ឍសម្ភារៈបង្រៀន និងរៀន**

គំរូខាងក្រោមបង្ហាញពីជំហានទូទៅនៅក្នុងដំណើរការត្រួតពិនិត្យ ឬអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន (TLMs)។ គំរូនេះគូសបញ្ជាក់ពីផ្នែកដែលគេអាចបញ្ចូលគោលការណ៍បរិវត្តកម្មយេនឌ័រទៅក្នុងដំណាក់កាលនីមួយៗ ដើម្បីឱ្យដំណើរការនិងសម្ភារៈបង្រៀន និងរៀនចុងក្រោយលើកកម្ពស់សមភាពយេនឌ័រ។ **ប្រអប់ទី ១១** ពណ៌នាអំពីដំណើរការបច្ចុប្បន្ននៃការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀននៅកម្ពុជា និងចង្អុលបង្ហាញពីចំណុចចាប់ផ្តើមសម្រាប់ការរួមបញ្ចូលការយកចិត្តទុកដាក់លើយេនឌ័រ។

**កំណត់សម្ភារៈបង្រៀន និងរៀនដែលត្រូវត្រួតពិនិត្យ ឬអភិវឌ្ឍ**

*ផ្ដល់អាទិភាពលើសម្ភារៈបង្រៀន និងរៀនដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដែលមានវិសាលភាពគ្របដណ្ដប់ធំជាងគេជាពិសេសសម្ភារៈដែលត្រូវបានគេដឹង ឬសង្ស័យថាមានបង្កប់ភាពលម្អៀងយេនឌ័រ ។*

**កំណត់អត្តសញ្ញាណ និងបង្កើតក្រុមត្រួតពិនិត្យ ឬអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន**

*ខិតខំសម្រេចឲ្យបានតុល្យភាពយេនឌ័រ*
*ស្វែងរកតុល្យភាពយេនឌ័រ និងជំរុញការចូលរួមពីបុគ្គលដែលមានសាវតារ និងអត្តសញ្ញាណចម្រុះដែលឆ្លុះបញ្ចាំងពីក្រុមអ្នកសិក្សា និងសហគមន៍ដ៏ទូលំទូលាយ។*

**ការបណ្ដុះបណ្ដាលក្រុមត្រួតពិនិត្យ ឬអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន**

*ផ្ដល់ការបណ្ដុះបណ្ដាលដើម្បីឱ្យសមាជិកក្រុមទាំងអស់យល់ពីគោលការណ៍បរិវត្តកម្មយេនឌ័រ និងអាចអនុវត្តគោលការណ៍ទាំងនោះនៅក្នុងការងាររបស់ពួកគេ។*

*ការវិភាគ និងកែសម្រួលសម្ភារៈដែលមានស្រាប់*

**វិភាគសម្ភារៈដែលមានស្រាប់**

*ប្រើប្រាស់ឧបករណ៍វិភាគយេនឌ័រ ដើម្បីពិនិត្យមើលអត្ថបទ រូបភាព និងខ្លឹមសារផ្សេងទៀត ដើម្បីស្វែងរកភាពលម្អៀង ផ្ទត់គំនិត និងការផាត់ចេញពីសង្គម (ឧ. **ឧបករណ៍ទី ១** និង **ឧបករណ៍ទី ២**)។*

**កែសម្រួលខ្លឹមសារ**

*កែសម្រួលឱ្យមានភាសាបរិយាបន្ន ការបង្ហាញដែលផ្ទុយពីផ្នត់គំនិតយេនឌ័រ និងមានលក្ខណៈចម្រុះ(រួមទាំងភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព) និងបន្ថែមឱកាសសម្រាប់ឱ្យអ្នក*

*ការអភិវឌ្ឍសម្ភារៈថ្មី*

**រៀបចំប្លង់សម្ភារៈ**

*ពិចារណាថាតើយេនឌ័រមានភាពពាក់ព័ន្ធយ៉ាងដូចម្ដេច ទៅនឹងមុខវិជ្ជា/ប្រធានបទ និងថាតើខ្លឹមសារ និងការរចនាប្លង់ នឹងរួមបញ្ចូល ការផ្លាស់ប្ដូរពាក់ព័ន្ធនឹងយេនឌ័រទៅក្នុងប្រធានបទមុខវិជ្ជាយ៉ាងដូចម្ដេច (**តារាងទី ២**)។*

**អភិវឌ្ឍខ្លឹមសារ**

*ព្រាងខ្លឹមសារដែលប្រើប្រាស់ភាសាបរិយាបន្ន ការបង្ហាញដែលផ្ទុយពីផ្នត់គំនិតយេនឌ័រ និងមានលក្ខណៈចម្រុះ និងបញ្ចូលសកម្មភាពសម្រាប់ឱ្យអ្នកសិក្សាពិនិត្យមើលបទដ្ឋានយេនឌ័រ។ ប្រសិនបើមានការប្រគល់សិទ្ធិឱ្យអ្នកខាងក្រៅ អភិវឌ្ឍសម្ភារៈបង្រៀន*

*សិក្សាស្វែងយល់បានល្អិតល្អន់អំពីបទដ្ឋានយេនឌ័រ ។*

*និងរៀនត្រូវប្រាកដថាមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់នៅក្នុងលក្ខខណ្ឌប្រតិបត្តិការងារ (ToR) ឬកិច្ចសន្យាការងារដែលតម្រូវឱ្យមានខ្លឹមសារគាំទ្រដល់បរិវត្តកម្មយេនឌ័រ និងរក្សាការទទួលខុសត្រូវរបស់អ្នកអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនលើការបំពេញតាមស្តង់ដារទាំងនេះ។*

### រចនាសម្ភារៈ

*ប្រើប្រាស់រូបភាពដែលបង្ហាញពីសមភាព និងភាពចម្រុះ បញ្ចៀសផ្នត់គំនិតចាស់កម្រិល និងពិចារណាយ៉ាងយកចិត្តទុកដាក់លើទំហំ និងការដាក់រូបភាព។*

### ធ្វើការត្រួតពិនិត្យពីខាងក្រៅ

*ជួលអ្នកត្រួតពិនិត្យពីខាងក្រៅដែលមានជំនាញផ្នែកយេនឌ័រ ដើម្បីវាយតម្លៃថាតើសម្ភារៈបង្រៀន និងរៀនបន្ស៊ីគ្នាបានកម្រិតណាទៅនឹងគោលការណ៍បរិវត្តកម្មយេនឌ័រ។*

### ធ្វើតេស្តសាកល្បងសម្ភារៈថ្មី ឬសម្ភារៈដែលបានកែសម្រួលរួច

*ធ្វើតេស្តសាកល្បងសម្ភារៈបង្រៀន និងរៀន និងស្វែងរកមតិកែលម្អដាក់លាក់លើរបៀបបង្ហាញយេនឌ័រ រួមទាំងសកម្មភាពណាដែលផ្តោតជាចម្បងលើយេនឌ័រ។*

### បញ្ជ្រាបការយល់ដឹងដល់ថ្នាក់ដឹកនាំ និងបណ្តុះបណ្តាលអ្នកអប់រំ

*ពន្យល់ដល់ថ្នាក់ដឹកនាំ និងអ្នកអប់រំពីមូលហេតុដែលខ្លឹមសារដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រមានសារៈសំខាន់ និងរបៀបដែលខ្លឹមសារបែបនេះគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដ៏ទូលំទូលាយដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅក្នុងប្រព័ន្ធអប់រំ (សូមមើល ផ្នែកទី ៤)។ ផ្តល់ការបណ្តុះបណ្តាលជាក់ស្តែងស្តីពីការប្រើប្រាស់សម្ភារៈបង្រៀន និងរៀនដើម្បីលើកកម្ពស់បរិយាបន្ន ដោះស្រាយបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងគាំទ្រដល់ការអនុវត្តក្នុងថ្នាក់រៀនដែលគាំទ្រដល់បរិវត្តកម្មយ៉ាងពិតប្រាកដ។*

*ប្រភព ៖* អ្នកនិពន្ធ

### ប្រអប់ទី១១. ឱកាសដាក់បញ្ចូលទស្សនទានយេនឌ័រទៅក្នុងដំណើរការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀននៅកម្ពុជា

នៅកម្ពុជាទោះបីជាមានការបង្កើតគណៈកម្មការ និងនីតិវិធីពាក់ព័ន្ធនឹងការអភិវឌ្ឍសៀវភៅសិក្សាក៏ដោយក៏បច្ចុប្បន្នមិនទាន់មានដំណើរការជាប្រព័ន្ធពេញលេញមួយសម្រាប់ការអភិវឌ្ឍ ឬកែសម្រួលសម្ភារៈបង្រៀន និងរៀនសម្រាប់សាលារៀននៅឡើយទេ។ ជាទូទៅ ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បង្កើតគណៈកម្មការដែលរួមមាន៖ អនុគណៈកម្មការត្រួតពិនិត្យ/ដឹកនាំ អនុគណៈកម្មការបច្ចេកទេសសម្រាប់អ្នកនិពន្ធ និងក្រុមការងារផ្នែកវិចិត្រករ ។ ការអនុម័តចុងក្រោយធ្វើឡើងដោយរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា(អ.យ.ក) ដែលលោកក៏អាចមានតួនាទីនៅក្នុងគណៈកម្មការគ្រប់គ្រងជាន់ខ្ពស់ ដែលត្រួតពិនិត្យដំណើរការនេះផងដែរ។ ទោះជាយ៉ាងណាក៏ដោយប្រព័ន្ធជារួមមិនទាន់មានក្របខ័ណ្ឌស្តង់ដារ និងគ្រប់ជ្រុងជ្រោយសម្រាប់ណែនាំដល់គ្រប់ដំណាក់កាលនៃការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនឱ្យមានលក្ខណៈស៊ីសង្វាក់គ្នានៅឡើយ។

ក្នុងករណីខ្លះ ការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនថ្មីត្រូវបានផ្តួចផ្តើមឡើងតាមរយៈកម្មវិធីដែលគាំទ្រដោយម្ចាស់ជំនួយ។ ខណៈដែលកម្មវិធីបែបនេះត្រូវបានអនុវត្តក្រោមភាពជាដៃគូជាមួយក្រសួងអប់រំ យុវជន និងកីឡា និងតម្រូវឱ្យមានការអនុម័តពីក្រសួង អ.យ.ក កម្មវិធីទាំងនោះក៏អាចជួយកំណត់ផងដែរថាតើសម្ភារៈបង្រៀន និងរៀនណាខ្លះដែលត្រូវបានអភិវឌ្ឍឡើង និងថាតើខ្លឹមសាររបស់វាផ្តោតលើអ្វីខ្លះ។

តាមធម្មតា ការកែសម្រួលកម្មវិធីសិក្សា និងការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនមានការចូលរួមពីភាគីពាក់ព័ន្ធយ៉ាងទូលំទូលាយ ដែលឆ្លុះបញ្ចាំងពីតម្រូវការជំនាញឯកទេសតាមមុខវិជ្ជា។ ជាទូទៅក្រុមអភិវឌ្ឍន៍សម្ភារៈបង្រៀន និងរៀនប្រើប្រាស់ធនធានពីនាយកដ្ឋានជាច្រើននៅក្រោមក្រសួង អ.យ.ក ហើយក៏អាចរួមបញ្ចូលអ្នកជំនាញផ្នែកសិក្សាធិការ អ្នកឯកទេសផ្នែកឧស្សាហកម្ម និងតំណាងមកពីក្រសួងពាក់ព័ន្ធផ្សេងទៀតផងដែរ។

នៅពេលដែលសម្ភារៈបង្រៀន និងរៀនត្រូវបានអភិវឌ្ឍឡើងតាមរយៈក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នដែលដើរតួនាទីសំខាន់ក្នុងក្រសួង អ.យ.ក គឺនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា (DCD) និងគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ (PDH)។ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា គឺជានាយកដ្ឋានបច្ចេកទេសរបស់ក្រសួង អ.យ.ក ដែលទទួលខុសត្រូវលើផ្នែកគុណភាពកម្មវិធីសិក្សា និងសៀវភៅសិក្សា។ នាយកដ្ឋាននេះកំណត់ ឬធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា បញ្ជាក់ថាតើសៀវភៅសិក្សាអ្វីខ្លះដែលត្រូវការចាំបាច់ និងខ្លឹមសារអ្វីខ្លះដែលត្រូវបញ្ចូលទៅក្នុងសៀវភៅសិក្សាទាំងនោះ និងទទួលខុសត្រូវលើការធានាភាពបន្សុីគ្នាទៅនឹងស្តង់ដាររបស់ក្រសួង។ ចំណែកគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ គឺជាស្ថាប័នបោះពុម្ព និងចែកផ្សាយរបស់រដ្ឋ ដែលចំណុះឱ្យក្រសួង អ.យ.ក។ ស្ថាប័ននេះអភិវឌ្ឍ និងផលិតសៀវភៅសិក្សា គ្រប់គ្រងការបោះពុម្ព និងលទ្ធកម្ម ព្រមទាំងចាត់ចែងការស្តុកទុក និងការចែកចាយសៀវភៅសិក្សាទូទាំងប្រទេស។ ក្នុងការអនុវត្តជាក់ស្តែង នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាផ្តល់ការណែនាំ និងការត្រួតពិនិត្យផ្នែកបច្ចេកទេស ចំណែកឯគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ (PDH) ផលិត និងចែកចាយសៀវភៅហើយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាតាមដានការចែកចាយនិងការអនុលោមតាមបទដ្ឋាន។

ក្នុងពេលបច្ចុប្បន្នមិនទាន់មានយន្តការស្តង់ដារ សម្រាប់ការអនុវត្តទស្សនទានយេនឌ័រនៅទូទាំងដំណើរការអភិវឌ្ឍន៍កម្មវិធីសិក្សា ឬសម្ភារៈបង្រៀន និងរៀននៅឡើយទេ ហើយក៏គ្មានការបណ្តុះបណ្តាលយេនឌ័រដែលមាន

លក្ខណៈស្តង់ដារ និងធ្វើឡើងជាប្រចាំ សម្រាប់ក្រុមអភិវឌ្ឍន៍សម្ភារៈបង្រៀន និងរៀនដែរ។ ជួនកាលយេនឌ័រត្រូវបានបញ្ចូលជាប្រធានបទមួយនៅក្នុងមុខវិជ្ជាជាក់លាក់ ប៉ុន្តែវាមិនត្រូវបានបញ្ជ្រាបឱ្យបានជាប់លាប់ទៅក្នុងដំណើរការនោះទេ។ នៅផ្នែកដែលយេនឌ័រគឺជាចំណុចឬមេរៀនស្នូលនៃមុខវិជ្ជា ឬគំនិតផ្តួចផ្តើមណាមួយជាទូទៅគឺមានការបញ្ចូលតំណាងក្រសួងកិច្ចការនារី (MoWA) ទៅក្នុងក្រុមអភិវឌ្ឍន៍សម្ភារៈបង្រៀន និងរៀន។ ការអនុវត្តបែបនេះផ្តល់នូវមូលដ្ឋានគ្រឹះជាក់ស្តែង សម្រាប់ការរួមបញ្ចូលយេនឌ័រក្នុងលក្ខណៈជាប្រព័ន្ធជាងមុនទៅក្នុងការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀននាពេលអនាគត។

អ្នកចូលរួមក៏បានកត់សម្គាល់ផងដែរអំពីសារៈសំខាន់នៃការរក្សាតួនាទីឱ្យបានច្បាស់លាស់ និងមានការសម្របសម្រួលនៅក្នុងវដ្តនៃការអភិវឌ្ឍកម្មវិធីសិក្សា និងសម្ភារៈបង្រៀន និងរៀនទាំងមូល។ ចំណុចនេះរួមបញ្ចូលទាំងភាពច្បាស់លាស់ទាក់ទងនឹងការទទួលខុសត្រូវជារួមរបស់ស្ថាប័នពាក់ព័ន្ធលើដំណើរការត្រួតពិនិត្យ ដំណើរការចាត់តាំង និងដំណើរការអនុម័ត ក៏ដូចជាការកំណត់អាណត្តិសម្រាប់គណៈកម្មកាតាមមុខវិជ្ជា (subject panel) អ្នកបោះពុម្ពផ្សាយ និងអ្នកត្រួតពិនិត្យ។ ការពង្រឹងភាពច្បាស់លាស់នេះ ត្រូវបានមើលឃើញថាជាគន្លឹះក្នុងការរក្សាបាននូវការធានាគុណភាពយ៉ាងស៊ីសង្វាក់គ្នា និងការបញ្ជ្រាបគោលការណ៍បរិវត្តកម្មយេនឌ័រជាប្រព័ន្ធទៅគ្រប់កម្រិតទាំងអស់នៃប្រព័ន្ធអប់រំ។

*ប្រភព ៖* អ្នកនិពន្ធ

## ៣.៥ ឧបករណ៍អនុវត្តន៍ជាក់ស្តែងដើម្បីគាំទ្រដល់ការកែសម្រួល និងការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន

ឧបករណ៍ខាងក្រោមបំប្លែងកស្តុតាងស្តីពីការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀន (TLMs) ទៅជាការណែនាំជាក់ស្តែងជាជំហានៗសម្រាប់ក្រុមការងារដែលកំពុងធ្វើការជាមួយផលិតផលជាក់ស្តែង។ ឧបករណ៍ទាំងនេះត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់ការវិភាគ និងការកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់ និងការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនថ្មី ដើម្បីធានាការរួមបញ្ចូលការពិចារណាលើបញ្ហាយេនឌ័រយ៉ាងសមស្រប។

ឧបករណ៍នីមួយៗត្រូវបានរៀបចំឡើងដើម្បីជំរុញការឆ្លុះបញ្ចាំងយ៉ាងល្អិតល្អន់ គាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ និងណែនាំដល់ការកែសម្រួលជាក់ស្តែង ដែលធ្វើឱ្យប្រសើរឡើងដល់ការបង្ហាញបរិយាបន្ន និងផលជះផ្នែកគរុកោសល្យ។ ការពិចារណាមួយចំនួនសម្រាប់ការកែសម្រួល និងការអនុវត្តឧបករណ៍ទាំងនេះមានបង្ហាញក្នុង**ប្រអប់ទី ១២**។

### ឧបករណ៍ទី ១. ឧបករណ៍សម្រាប់ណែនាំដល់ការវិភាគ និងការកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់

ឧបករណ៍ទី ១ ណែនាំអំពីការវិភាគ និងការកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់ដោយផ្អែកលើលក្ខណៈពិសេសៗនៃសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រ។ ឧបករណ៍នេះជួយឱ្យអ្នកប្រើប្រាស់កំណត់រកផ្នែកដែលសម្ភារៈបង្រៀន និងរៀនពង្រឹង ឬដោះស្រាយបទដ្ឋាន

យេនឌ័រ ផ្នែកដែលមិនមានតំណាងនិងបង្ហាញពីសំឡេង ឬអត្តសញ្ញាណ និងផ្នែកដែលចាំបាច់ត្រូវកែធ្វើការកែសម្រួល។

## ឧបករណ៍ទី ២. ឧបករណ៍សម្រាប់ណែនាំដល់ការវិភាគ និងការកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់សម្រាប់ភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព

ឧបករណ៍ទី ២ ណែនាំអំពីការវិភាគ និងការកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់ដោយផ្តោតជាពិសេសទៅលើភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព។ ឧបករណ៍នេះឆ្លើយតបទៅនឹងភស្តុតាងកាន់តែច្រើនឡើងដែលបង្ហាញថា ការពណ៌នាអំពីកុមារី និងស្ត្រី កាន់តែមានភាពចម្រុះនៅក្នុងបរិបទមួយចំនួន ខណៈដែលការពណ៌នាអំពីកុមារា និងបុរស នៅតែមានលក្ខណៈតូចចង្អៀត និងពោរពេញដោយផ្នត់គំនិតចាស់កម្រិល។ ក្នុងបរិបទនេះ សម្ភារៈបង្រៀន និងរៀនមួយចំនួនប្រហែលជាកំពុងដេញដោលបទដ្ឋានយេនឌ័រដែលផ្តល់គុណវិបត្តិដល់កុមារី និងស្ត្រីរួចទៅហើយ ប៉ុន្តែនៅតែបន្តពង្រឹងភាពជាបុរសដែលតឹងរ៉ឹង និងបង្កគ្រោះថ្នាក់ ដែលធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្ត ការចូលរួម និងការរៀនសូត្ររបស់កុមារា (សូមមើល ផ្នែកទី២)។ ឧបករណ៍នេះជួយកំណត់រកលំនាំទាំងនោះ និងផ្តល់នូវសំណួរណែនាំ ដើម្បីគាំទ្រដល់អភិក្រមដែលកាន់តែគាំទ្រដល់បរិយាបន្ន និងការធ្វើបរិវត្តកម្មយេនឌ័រអំពីភាពជាបុរស។ ឧបករណ៍នេះផ្តល់ប្រយោជន៍ច្រើនបំផុតនៅពេលប្រើប្រាស់ជាមួយសម្ភារៈបង្រៀន និងរៀនដែលបានលើកឡើងរួចមកហើយអំពីការបង្កើនភាពអង់អាចដល់កុមារី។

## ឧបករណ៍ទី ៣. ឧបករណ៍សម្រាប់ណែនាំដល់ការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនថ្មីដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ

ឧបករណ៍ទី ៣ ត្រូវបានរៀបចំឡើងដើម្បីណែនាំដល់ដំណើរការអភិវឌ្ឍន៍សម្ភារៈបង្រៀន និងរៀនថ្មី។ ឧបករណ៍នេះត្រូវបានរៀបចំឱ្យផ្តោតលើដំណាក់កាលសំខាន់ៗនៃដំណើរការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនដូចជា ៖ ការរៀបចំផែនការ ការសរសេរ ការរចនា និងការត្រួតពិនិត្យ។ ឧបករណ៍នេះគូសបញ្ជាក់ពីសកម្មភាពដែលអាចធ្វើឡើងនៅដំណាក់កាលនីមួយៗ ដើម្បីធានាថាផលិតផលចុងក្រោយពិតជាគាំទ្រដល់បរិវត្តកម្មយេនឌ័រ។

### ប្រអប់ទី ១២. ចំណុចត្រូវពិចារណានៅពេលប្រើប្រាស់ឧបករណ៍ទាំងនេះ

ឧបករណ៍ទាំងនេះគឺសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែន។ ក្រុមការងារអាចផ្តោតលើផ្នែក ឬសំណួរមួយចំនួន អាស្រ័យលើអាទិភាពរបស់ពួកគេ ប្រភេទសម្ភារៈបង្រៀន និងរៀន និងធនធានដែលមានស្រាប់។ គោលបំណងគឺមិនមែនដើម្បីធ្វើការវិភាគឱ្យគ្រប់ជ្រុងជ្រោយឬបំពេញតាមកូតានោះទេប៉ុន្តែគឺដើម្បីធានាថាជារួមសម្ភារៈបង្រៀននិងរៀនរំលេចភាពចម្រុះ បញ្ចៀសផ្នត់គំនិតចាស់កម្រិល និងលើកកម្ពស់បទដ្ឋានដែលប្រកបដោយបរិយាបន្ន និងសមធម៌។

*ភាពអាចអនុវត្តបាន និងភាពពាក់ព័ន្ធនៃផ្នែកមួយចំនួន ៖* មិនមែនផ្នែកទាំងអស់នៃឧបករណ៍ទាំងនេះសុទ្ធតែ

មានភាពពាក់ព័ន្ធសម្រាប់សម្ភារៈបង្រៀន និងរៀនគ្រប់ប្រភេទនោះទេ។ ឧទាហរណ៍ ប្រសិនបើសម្ភារៈបង្រៀន និងរៀនមិនមានបញ្ចូលរូបថត ឬរូបភាពផ្សេងទៀតទេ សំណួរទាក់ទងនឹងរូបភាពអាចគូសចំណាំថា '**មិនពាក់ព័ន្ធ**'។ ទោះជាយ៉ាងណាក៏ដោយ គួរប្រើប្រាស់ជម្រើស '**មិនពាក់ព័ន្ធ**' ដោយប្រុងប្រយ័ត្ន។ កុំប្រើប្រាស់ជម្រើសនេះ ដើម្បីរំលងបញ្ហាដែលអាចដោះស្រាយប្រកបដោយអត្ថន័យ ហើយនៅពេលមានមន្ទិលសង្ស័យ ត្រូវពិភាក្សាថាតើការផ្លាស់ប្តូរនៅតែអាចកែលម្អបរិយាបន្ន ការបង្ហាញ និងបរិវត្តកម្មជាវិជ្ជមានឬទេ។

*ការកែសម្រួលទៅតាមក្រុមអាយុផ្សេងៗ ៖* នៅពេលអភិវឌ្ឍសម្ភារៈបង្រៀ និងរៀនសម្រាប់កម្រិតអាយុផ្សេងៗគ្នាគេចាំបាច់ត្រូវពិចារណាលើអ្វីដែលសមស្របនឹងវ័យ និងការអភិវឌ្ឍរបស់អ្នកសិក្សា។ កិច្ចខិតខំប្រឹងប្រែងដោះស្រាយបទដ្ឋាន និងផ្តត់គំនិតដែលបង្គ្រោះថ្នាក់ រួមទាំងឱកាសសម្រាប់ឱ្យអ្នកសិក្សាគិតពិចារណាអំពីបញ្ហាទាំងនេះនឹងមានទម្រង់ខុសគ្នានៅក្នុងសម្ភារៈបង្រៀន និងរៀនសម្រាប់កុមារតូច បើប្រៀបធៀបនឹងសម្ភារៈបង្រៀន និងរៀនសម្រាប់ក្មេងជំទង់ ឬមនុស្សពេញវ័យ។

*រយៈពេលដែលត្រូវការចាំបាច់ ៖* រយៈពេលដែលត្រូវការចាំបាច់ នឹងប្រែប្រួលទៅតាមប្រវែង និងភាពស្មុគស្មាញនៃសម្ភារៈបង្រៀន និងរៀន។ ការត្រួតពិនិត្យ ឬអភិវឌ្ឍសៀវភៅសិក្សាដែលគ្រប់ជ្រុងជ្រោយ ត្រូវចំណាយពេលយូរជាងការត្រួតពិនិត្យ ឬអភិវឌ្ឍសៀវភៅរឿងខ្លី ឬសន្លឹកកិច្ចការតែមួយទំព័រ។ ក្រុមការងារគួរលៃលកពេលគ្រប់គ្រាន់សម្រាប់ការឆ្លុះបញ្ចាំង និងការពិភាក្សាជាពិសេសលើប្រធានបទស្មុគស្មាញ ឬប្រធានបទរសើប។

## ឧបករណ៍ទី ១. ឧបករណ៍សម្រាប់ណែនាំដល់ការវិភាគ និងការកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់

| | |
|---|---|
| កាលបរិច្ឆេទ ៖ | កម្រិតថ្នាក់ ៖ |
| ប្រភេទសម្ភារៈ ៖ | មុខវិជ្ជា ៖ |
| ចំណងជើងសម្ភារៈ ៖ | អ្នកនិពន្ធ/អ្នករៀបរៀងដើមដំបូង ៖ |
| | កាលបរិច្ឆេទដើមនៃការអភិវឌ្ឍ/ការបោះពុម្ពផ្សាយ ៖ |

| ប្រភេទ | សំណួរ | ចម្លើយ | ការកែសម្រួលដែលបានស្នើឡើង (ប្រសិនបើចាំបាច់) |
|---|---|---|---|
| **ភាពញឹកញាប់នៃការបង្ហាញនៅក្នុងអត្ថបទ** | តើ**អត្ថបទ** (អត្ថបទនិទាន/រឿងរ៉ាវ/ករណីសិក្សា/ឧទាហរណ៍/គំរូ។ល។) មានបញ្ចូលការសំដៅដល់មនុស្ស ដែលមានយេនឌ័រខុសៗគ្នា ក្នុងចំនួនប្រហាក់ប្រហែលគ្នាដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែម ឬកែសម្រួលអត្ថបទ ដើម្បីធានាឱ្យមានការបង្ហាញដោយស្មើភាពគ្នា រវាងកុមារី/កុមារ/ស្ត្រី/បុរស នៅក្នុងអត្ថបទទាំងមូល។ |

| | | | |
|---|---|---|---|
| | តើ**មនុស្ស**ដែលមានយេនឌ័រខុសៗគ្នា ត្រូវបានបង្ហាញនៅក្នុង**អត្ថបទ** ក្នុងលក្ខណៈដែលផ្តល់តម្លៃស្មើគ្នាដែរ ឬទេ?<br>ឧទាហរណ៍ តើមនុស្សដែលមានយេនឌ័រខុសៗគ្នា ត្រូវបានបង្ហាញដោយស្មើភាពគ្នា តាមរបៀបដែលគូសបញ្ជាក់ពីគុណសម្បត្តិ និងសមិទ្ធផលចម្រុះដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែម ឬកែសម្រួលការពណ៌នានៅក្នុងអត្ថបទ ដើម្បីធ្វើឱ្យមានតុល្យភាពនៃការបង្ហាញកុមារី/កុមារា/ស្ត្រី/បុរស ដែលត្រូវបានផ្តល់តម្លៃលើគុណសម្បត្តិ និងសមិទ្ធផលផ្សេងៗគ្នា (ឧ. នវានុវត្តន៍ ការច្នៃប្រឌិត សមិទ្ធផលសិក្សា)។<br>ចំណុចនេះអាចទាមទារឱ្យមានការស្រាវជ្រាវ ដើម្បីស្វែងរកឧទាហរណ៍ថ្មីៗ។ |
| **ភាពញឹកញាប់នៃការបង្ហាញនៅក្នុងរូបភាព** | តើ**រូបភាព** (រូបថត និងរូបភាពផ្សេងៗទៀត ដែលបង្ហាញពីមនុស្ស/តួអង្គ) បង្ហាញមនុស្សដែលមានយេនឌ័រខុសៗគ្នា ក្នុងចំនួនប្រហាក់ប្រហែលគ្នាដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែម កែសម្រួល ឬជំនួសរូបភាព ដើម្បីធានាឱ្យមានការបង្ហាញយេនឌ័រ ប្រកបដោយតុល្យភាព។ ខិតខំធ្វើឱ្យមានយុគភាពយេនឌ័រប្រហាក់ប្រហែលគ្នា នៃចំនួនកុមារី និងកុមារា បុរស និងស្ត្រីដែលត្រូវបានបង្ហាញឡើង។ |
| | តើ**រូបភាព**ដែលតំណាងឱ្យមនុស្ស ដែលមានយេនឌ័រខុសៗគ្នា មានទំហំប៉ុនគ្នាដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | កែតម្រូវទំហំ/ការដាក់ទីតាំងរូបភាព ដើម្បីឱ្យមនុស្សគ្រប់យេនឌ័រត្រូវបានបង្ហាញឡើងក្នុងទំហំ និងភាពលេចធ្លោប្រហាក់ប្រហែលគ្នា។ |

| | | | |
|---|---|---|---|
| | តើ**មនុស្ស** ដែលមានយេនឌ័រខុសៗគ្នា បង្ហាញវត្តមាននៅក្នុងទីធ្លាខាងក្នុង និងទីធ្លាខាងក្រៅ (ឧ. ក្នុងផ្ទះ ក្នុងទីប្រជុំជន ក្នុងថ្នាក់រៀន និងសាលារៀន)ញឹកញាប់ប្រហាក់ប្រហែលគ្នានៅក្នុងរូបភាពដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែម កែសម្រួល ឬជំនួសរូបភាព ដើម្បីធានាថា តួអង្គគ្រប់យេនឌ័រ (កុមារ និងមនុស្សពេញវ័យ) ត្រូវបានពណ៌នានៅក្នុងទីតាំង និងបរិស្ថានចម្រុះ។ |
| | តើ**មនុស្ស**ដែលមានយេនឌ័រខុសៗគ្នា បានចូលរួមក្នុងសកម្មភាពផ្សេងៗគ្នា (ឧ. កីឡា ការថែទាំ ការងារមានប្រាក់កម្រៃ) និងមានភាពញឹកញាប់ប្រហាក់ប្រហែលគ្នា នៅក្នុងរូបភាពដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | ធ្វើបច្ចុប្បន្នភាព ជំនួស ឬបន្ថែមរូបភាព ដើម្បីធានាថារូបភាពទាំងនោះ ពណ៌នាពីមនុស្សគ្រប់យេនឌ័រចូលរួមក្នុងសកម្មភាពផ្សេងៗ។ ធានាថា កុមារី/ស្ត្រី និងកុមារា/បុរស ត្រូវបានបង្ហាញឡើងទាំងនៅក្នុងសកម្មភាពតាមទម្លាប់ និងសកម្មភាពខុសទម្លាប់ (ឧទាហរណ៍៖ កុមារីលេងបាល់ទាត់ កុមារាចម្អិនអាហារ ឬធ្វើកិច្ចការថែទាំ)។ |
| **ភាសាប្រកបដោយសមធម៌យេនឌ័រ និងមានបរិយាបន្ន** | តើ**អត្ថបទ**បញ្ចៀសការប្រើប្រាស់ពាក្យ ឬស្លាកដាក់លាក់តាមយេនឌ័រដែរ ឬទេ (ឧ. ការប្រើតែសព្វនាម 'គាត់ (he)' ពាក្យ 'បុរស(men)' ដើម្បីសំដៅលើមនុស្សទាំងអស់ ឬពាក្យដែលមានលក្ខណៈសម្គាល់យេនឌ័រ ដូចជា នគរបាលប្រុស ឬស្ត្រីបោសសម្អាត)? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | ជំនួសពាក្យដាក់លាក់តាមយេនឌ័រ ដោយពាក្យដែលមានអព្យាក្រឹតយេនឌ័រ ឬបរិយាបន្ន។<br><br>គួរកត់សម្គាល់ថា ទម្រង់អព្យាក្រឹតនៃងារ និងមុខងារគួរតែប្រើប្រាស់នៅពេលអាចធ្វើទៅបាន (ឧ. ពាក្យ "ប្រធានអង្គប្រជុំ" ដែលសរសេរជា chairperson ជាជាងពាក្យ "ប្រធានអង្គប្រជុំ ជាបុរស"ដែលសរសេរជា chairman)។<br><br>ប្រសិនបើមិនអាចធ្វើទៅបានទេ អាចប្រើទម្រង់សមស្រប |

| | | | |
|---|---|---|---|
| | | | នៃតួនាទីជាបុរស និងតួនាទីស្ត្រី (ឧ. កីឡាករ កីឡាការិនី បុរសរត់សំបុត្រ ស្ត្រីរត់សំបុត្រ)។ |
| | តើសំនៀងនៃភាសា និងការពណ៌នាអំពី **មនុស្ស/តួអង្គ**មានភាពខុសគ្នាតាមយេនឌ័រ ក្នុងលក្ខណៈដែលពង្រឹងផ្នត់គំនិត ឬភាពលម្អៀង (ឧ. ការពណ៌នាតែស្ត្រីថាជាមនុស្សស្តាប់បង្គាប់ ឬការពណ៌នាតែបុរសថាជាមនុស្សម៉ឺងម៉ាត់ ឬរឹងមាំ) ឬពណ៌នាយេនឌ័រមួយចំនួនក្នុងលក្ខណៈអវិជ្ជមាន ឬបង្គ្រោះថ្នាក់រហូតដែរ ឬទេ (ឧ. សន្មតថាបុរសទាំងអស់សុទ្ធតែប្រើហឹង្សា)? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | ពិនិត្យ និងកែសម្រួលអត្ថបទ ដើម្បីធានាថា ទឹកដមសំនៀងដែលគេប្រើ ដើម្បីពណ៌នាមនុស្សដែលមានយេនឌ័រខុសៗគ្នា មានតុល្យភាព មិនពង្រឹងផ្នត់គំនិត និងមិនពណ៌នាយេនឌ័រជាក់លាក់ណាមួយក្នុងលក្ខណៈអវិជ្ជមាន ឬបង្គ្រោះថ្នាក់ឡើយ។ |
| | នៅពេលនិយាយអំពីក្រុមចម្រុះយេនឌ័រតើមានការប្រើប្រាស់ពាក្យអព្យាក្រឹតដែរ ឬទេ (ឧ. 'កម្មករ' ជាជាង 'កម្មករជាបុរស' ឬ 'នគរបាល' ជាជាង 'នគរបាលប្រុស', 'អ្នកសិក្សា' ជាជាង 'កុមារា និងកុមារី')? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | កែសម្រួលពាក្យពណ៌នាក្រុម ដោយប្រើប្រាស់ពាក្យជារួមដែលប្រកបដោយបរិយាបន្ន ជាជាងពាក្យដែលមានលក្ខណៈផ្អែកតាមយេនឌ័រ។ |

| | | | |
|---|---|---|---|
| | ប្រសិនបើ**មនុស្ស/តួអង្គ** ដែលមានយេនឌ័រខុសៗគ្នា លេចឡើងក្នុងអត្ថបទតែមួយ តើវាបញ្ចៀស ការចាប់ផ្តើមឡើងដោយស្វ័យប្រវត្តិពីតួអង្គប្រុសដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | កែសម្រួលឃ្លាប្រយោគ ដើម្បីផ្លាស់ប្តូរ និង/ ឬធ្វើឱ្យមានលំដាប់លំដោយឆ្លាស់គ្នា នៅក្នុងអត្ថបទទាំងមូល។ |
| **អត្ថបទ និងរូបភាពដែលគាំទ្រដល់សមធម៌ និង បរិវត្តកម្មយេនឌ័រ** | តើ**អត្ថបទ** និង/ **ឬរូបភាព**បង្ហាញមនុស្សដែលមានយេនឌ័រខុសៗគ្នា នៅក្នុងកិច្ចការផ្ទះសម្បែង (ឧ. ធ្វើការងារផ្ទះ និង/ ឬថែទាំកូន) ក្នុងចំនួនប្រហាក់ប្រហែលគ្នាដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែម ឬកែសម្រួលអត្ថបទ/រូបភាព ដើម្បីធានាថាមានឧទាហរណ៍នៃបុរស និងកុមារាដែលបំពេញតួនាទីធ្វើកិច្ចការផ្ទះ និងតួនាទីថែទាំ។ ព្យាយាមធានាឱ្យមានការបង្ហាញស្មើគ្នា។ |
| | តើ**អត្ថបទ និង/ ឬរូបភាព**បង្ហាញមនុស្សដែលមានយេនឌ័រខុសៗគ្នា នៅក្នុងផ្នែកវិជ្ជាជីវៈ (ឧ. នៅក្នុងវិជ្ជាជីវៈ ដែលមានប្រាក់ឈ្នួលច្រើន) ក្នុងចំនួនប្រហាក់ប្រហែលគ្នាដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែម ឬកែសម្រួលអត្ថបទ/រូបភាព ដើម្បីធានាឱ្យមានការបង្ហាញយេនឌ័រប្រកបដោយតុល្យភាពនៅក្នុងវិជ្ជាជីវៈចម្រុះឬមានប្រាក់ឈ្នួលច្រើន។ |
| | តើ**អត្ថបទ និង/ ឬរូបភាព**បង្ហាញមនុស្សដែលមានយេនឌ័រខុសៗគ្នា នៅក្នុងតួនាទីជាអ្នកដឹកនាំ (ឧ. អ្នកដឹកនាំនយោបាយ នាយកប្រតិបត្តិ) ក្នុងចំនួនប្រហាក់ប្រហែលគ្នាដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែម ឬកែសម្រួលអត្ថបទ/រូបភាព ដើម្បីធានាការបង្ហាញយេនឌ័រប្រកបដោយតុល្យភាព ក្នុងចំណោមមនុស្ស/តួអង្គ ដែលកាន់តួនាទីជាអ្នកដឹកនាំ។ |

| | | | |
|---|---|---|---|
| | តើ**អត្ថបទ និង/ ឬរូបភាព**បង្ហាញមនុស្សដែលមានយេនឌ័រខុសៗគ្នា នៅក្នុងការទទួលបាន និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងចំនួនប្រហាក់ប្រហែលគ្នាដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែម ឬកែសម្រួលអត្ថបទ/រូបភាព ដើម្បីធានាថាមានឧទាហរណ៍នៃស្ត្រី ដែលប្រើប្រាស់ឧបករណ៍ឌីជីថល។ |
| | តើ**អត្ថបទ និង/ ឬរូបភាព**បញ្ចៀសការពណ៌នាអំពីលក្ខណៈចិត្តសាស្ត្រ ឬគុណសម្បត្តិសីលធម៌ ដែលបង្កប់ផ្នត់គំនិតយេនឌ័រ (ឧ. មានតែកុមារីទេដែលយំ មានតែកុមារាទេដែលក្លាហាន ឬមានអាកប្បកិរិយាមិនល្អ) ដែរឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | រៀបចំឡើងវិញនូវការពណ៌នា អំពីរូបភាពមនុស្ស/តួអង្គ ដើម្បីកុំឱ្យបង្ហាញតែអារម្មណ៍ សីលធម៌ និងចិត្តសាស្ត្រ ដែលបង្កប់ផ្នត់គំនិតយេនឌ័រ។ រិះរកវិធីពណ៌នា/បង្ហាញដោយចេតនានូវមនុស្ស ដែលមានយេនឌ័រខុសៗគ្នា តាមរបៀបផ្ទុយពីផ្នត់គំនិតយេនឌ័រ ដូចជា ការបង្ហាញថា កុមារី/ស្ត្រីក្លាហាន និងក្រមិចក្រមើម និងការបង្ហាញថា កុមារា/បុរសចិត្តល្អ ចេះបង្ហាញអារម្មណ៍ ចេះជួយទុក្ខធុរៈ និងចេះយល់ចិត្ត។ |
| | តើ**អត្ថបទ និង/ ឬរូបភាព**បង្ហាញមនុស្សដែលមានយេនឌ័រខុសៗគ្នា នៅក្នុងសកម្មភាព និងតួនាទី ដែលផ្ទុយពីផ្នត់គំនិតយេនឌ័រយ៉ាងពិតប្រាកដ (ឧ. បុរសជាអ្នកថែទាំកូនចម្បង ឬជាគិលានុបដ្ឋាកា ហើយស្ត្រីជាអ្នកបើកបរឡានដឹកទំនិញ ឬជាមេដឹកនាំនយោបាយ) ដែរឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | រិះរកឱកាសបង្ហាញដោយចេតនា នូវសកម្មភាពនិងតួនាទីដែលផ្ទុយពីផ្នត់គំនិតយេនឌ័របែបប្រពៃណីសម្រាប់ កុមារា កុមារី បុរស និងស្ត្រី។<br>ធានាថា ពួកគេត្រូវបានពណ៌នាក្នុងន័យវិជ្ជមាន។ |

| | | | |
|---|---|---|---|
| | តើ**បុគ្គល**គំរូវិជ្ជមាន ត្រូវបានបង្ហាញឡើងសម្រាប់កុមារី និងកុមារា (ឧ. តួអង្គប្រវត្តិសាស្ត្រ ផ្ទើម កីឡាករ អ្នកដឹកនាំ) ក្នុងចំនួនប្រហាក់ប្រហែលគ្នាដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | កែសម្រួល ឬបន្ថែមអត្ថបទ/រូបភាពដើម្បីបញ្ចូលបុគ្គលគំរូគ្រប់យេនឌ័រ។ ផ្តោតលើអាយុ និងសមិទ្ធផលចម្រុះ។ |
| | តើទំនាក់ទំនងរវាង**មនុស្ស**ដែលមានយេនឌ័រខុសៗគ្នា ត្រូវបានពណ៌នាតាមរបៀបដែលឆ្លុះបញ្ចាំងពីការគោរពនិងឥទ្ធិពលអំណាចប្រកបដោយតុល្យភាពដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | កែសម្រួលអត្ថបទ/រូបភាពដើម្បីពណ៌នាពីទំនាក់ទំនងរវាងមនុស្សដែលមានយេនឌ័រខុសៗគ្នា ដែលប្រឈមឋានានុក្រមបែបប្រពៃណី និងទំនាក់ទំនងអំណាចមិនស្មើគ្នា។<br><br>ផ្តោតលើការពណ៌នា ដែលឆ្លុះបញ្ចាំងពីការគោរពគ្នាទៅវិញទៅមក កិច្ចសហការ និងសមភាពយេនឌ័រនៅក្នុងទំនាក់ទំនងគ្រប់ទម្រង់។ |
| **ការយកចិត្តទុកដាក់លើភាពប្រទាក់ក្រឡាគ្នានៅក្នុង អត្ថបទ និងរូបភាព** | តើ**មនុស្ស/តួអង្គ** ដែលតំណាងឱ្យក្រុមបន្ទាប់បន្សំផ្សេងៗគ្នានៅក្នុងសង្គម លេចឡើងនៅទូទាំងអត្ថបទ និង/ឬរូបភាពដែរ ឬទេ (ទន្ទឹមនឹងយេនឌ័រ សូមពិចារណាលើសមត្ថភាព ភាសា ពូជសាសន៍/ជាតិពន្ធុ។ល។)? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែម ឬកែសម្រួលអត្ថបទ/រូបភាព ដើម្បីតំណាងឱ្យមនុស្ស/តួអង្គដែលមានសាវតារ និងអត្តសញ្ញាណចម្រុះ។<br><br>ធានាថា ការបង្ហាញ ឆ្លុះបញ្ចាំងពីបរិបទក្នុងមូលដ្ឋាន និងបញ្ចៀសការបង្ហាញបែបបង្គ្រប់កិច្ច។ |

| | | | |
|---|---|---|---|
| | **តើមនុស្ស/តួអង្គ** ដែលតំណាងឱ្យក្រុមបន្ទាប់បន្សំផ្សេងៗគ្នាក្នុងសង្គម លេចឡើងនៅទូទាំងអត្ថបទ និង/ ឬរូបភាព នៅក្នុងសកម្មភាពទូទៅទាំងអស់ (ឧ. កីឡា សកម្មភាពកម្សាន្ត) ដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែម ឬកែសម្រួលអត្ថបទ/រូបភាព ដើម្បីតំណាងឱ្យមនុស្ស/តួអង្គមកពីក្រុមចម្រុះ ដែលចូលរួមក្នុងសកម្មភាពគ្រប់បែបយ៉ាងទាំងអស់។ |
| | **តើមនុស្ស/តួអង្គ** ដែលតំណាងឱ្យក្រុមបន្ទាប់បន្សំផ្សេងៗគ្នាក្នុងសង្គម លេចឡើងនៅទូទាំងអត្ថបទ និង/ ឬរូបភាព ដោយត្រូវបានពណ៌នា នៅក្នុងតួនាទីជាអ្នកដឹកនាំ និងអ្នកគាំទ្រដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | ខិតខំរិះរកវិធីបង្ហាញមនុស្ស/តួអង្គ មកពីក្រុមដែលធ្លាប់តែមានតំណាងតិចតួច ឬក្រុមដែលត្រូវបានផាត់ចេញពីសង្គម នៅក្នុងតួនាទីជាអ្នកដឹកនាំ និងអ្នកគាំទ្រ។ |
| **ខ្លឹមសារដែលលើកឡើងដោយផ្ទាល់អំពីយេនឌ័រ និងសមភាពយេនឌ័រ** | តើ**កម្មវិធីសិក្សា** និង/ ឬ**កម្មវិធីសិក្សាលម្អិត** ទទួលស្គាល់ភាពពាក់ព័ន្ធរបស់យេនឌ័រទៅនឹងខ្លឹមសារក្នុងមុខវិជ្ជាដែរ ឬទេ? (ឧ. កម្មវិធីសិក្សាលម្អិតសម្រាប់មុខវិជ្ជាប្រវត្តិវិទ្យា មានរួមបញ្ចូលមេរៀន ស្ដីពីការផាត់ស្ត្រីចេញពីការចូលរួមក្នុងសង្គមស៊ីវិលកាលពីអតីតកាល។ កម្មវិធីសិក្សាលម្អិតសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ លើកឡើងពីការដោះស្រាយបញ្ហាចំនួនស្ត្រីមានតំណាងតិចតួចនៅក្នុងវិជ្ជាជីវៈ STEM)។ | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | ឆ្លុះបញ្ចាំងពីរបៀបដែលការពិចារណាលើយេនឌ័រមានភាពពាក់ព័ន្ធនឹងខ្លឹមសារក្នុងមុខវិជ្ជា និងបញ្ជាក់ឱ្យបានច្បាស់នៅក្នុងកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងគោលបំណងសិក្សា។ |

| | | | |
|---|---|---|---|
| | តើ**សម្ភារៈបង្រៀន និងរៀន**បានទទួលស្គាល់ ឬលើកឡើងយ៉ាងច្បាស់អំពីរបៀប ដែលយេនឌ័រមានភាពពាក់ព័ន្ធនឹងខ្លឹមសារ ក្នុងមុខវិជ្ជាដែរឬទេ? (ឧ. សៀវភៅពុម្ពសុខភាពដែលពិភាក្សាអំពីរបៀបដែលបទដ្ឋាននៃភាពជាបុរស មិនលើកទឹកចិត្តឱ្យកុមារស្វែងរកការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត។) | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | ឆ្លុះបញ្ចាំងពីរបៀប ដែលការពិចារណាលើយេនឌ័រមានភាពពាក់ព័ន្ធនឹងខ្លឹមសារក្នុងមុខវិជ្ជា (សូមមើលតារាងទី ២) និងរិះរកវិធីដើម្បីដោះស្រាយបញ្ហាទាំងនេះនៅក្នុងសម្ភារៈបង្រៀននិងរៀន។ |
| | តើ**សម្ភារៈបង្រៀន និងរៀន**ផ្តល់នូវសកម្មភាពរៀនសូត្រ ឬឱកាសផ្សេងៗទៀតសម្រាប់ឱ្យអ្នកសិក្សា ឆ្លុះបញ្ចាំងអំពីបទដ្ឋានយេនឌ័រ ផលប៉ះពាល់របស់វា និងរបៀបផ្លាស់ប្តូរបទដ្ឋានយេនឌ័រនៅពេលវាបង្កគ្រោះថ្នាក់ ឬមានការរឹតត្បិតដែរឬទេ? (ឧ. ផ្ញាយតម្លៃមុខវិជ្ជាសីលធម៌ ពលរដ្ឋវិជ្ជា ស្នើឱ្យអ្នកសិក្សា ឆ្លុះបញ្ចាំងពីវិសមភាពយេនឌ័រក្នុងការដឹកនាំនយោបាយនៅប្រទេសរបស់ពួកគេ និងពិចារណាថា តើហេតុអ្វីបានជាមានបញ្ហាទាំងនេះកើតឡើងនិងរបៀបផ្លាស់ប្តូរ)។ | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែមសំណួរជំរុញឱ្យមានការឆ្លុះបញ្ចាំងកិច្ចការពិភាក្សា ឬកិច្ចការស្រាវជ្រាវ ដែលផ្តោតលើការស្វែងយល់អំពីបទដ្ឋានយេនឌ័រ ផលប៉ះពាល់របស់វា និងសកម្មភាពសម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាន។ |

| | | | |
|---|---|---|---|
| | តើមានការផ្តល់ស្ថិតិ ឬតួលេខណាមួយដែលបែងចែកតាមភេទ និងតាមកត្តាប្រទាក់ក្រឡាគ្នាផ្សេងទៀត ដូចជា សមត្ថភាព ស្ថានភាពសេដ្ឋកិច្ចសង្គម ឬទីតាំងភូមិសាស្ត្រដើម្បីទទួលយករបៀបដែលយេនឌ័រ មានទំនាក់ទំនងជាមួយទម្រង់វិសមភាពផ្សេងទៀតដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | ពិនិត្យខ្លឹមសារស្ថិតិទាំងអស់ និងកែសម្រួល ដើម្បីបញ្ចូលទិន្នន័យបែងចែកតាមភេទ និងកត្តាប្រទាក់ក្រឡាគ្នាផ្សេងទៀត នៅពេលអាចធ្វើទៅបាន។<br>បន្ថែមអត្ថបទពណ៌នា ឬកិច្ចការឆ្លុះបញ្ចាំង ដើម្បីលើកទឹកចិត្តអ្នកសិក្សាឱ្យពិចារណា និងបកស្រាយអំពីភាពខុសគ្នាផ្អែកលើយេនឌ័រ និង/ ឬកត្តាប្រទាក់ក្រឡាគ្នាផ្សេងទៀត។ |

*ប្រភព ៖* អ្នកនិពន្ធ។ ប្រភេទ និងសំណួរមួយចំនួនត្រូវបានកែសម្រួលពី Commonwealth of Learning, 2019; RTI International, 2015; UNESCO, 2018b.

## ឧបករណ៍ទី ២. ឧបករណ៍សម្រាប់ណែនាំដល់ការវិភាគ និងការកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់សម្រាប់ភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព

| | |
|---|---|
| កាលបរិច្ឆេទ ៖ | កម្រិតថ្នាក់ ៖ |
| ប្រភេទសម្ភារៈ ៖ | មុខវិជ្ជា ៖ |
| ចំណងជើងសម្ភារៈ ៖ | អ្នកនិពន្ធ/អ្នករៀបរៀងដើមដំបូង ៖ |
| | កាលបរិច្ឆេទដើមនៃការអភិវឌ្ឍ/ការបោះពុម្ពផ្សាយ ៖ |

| ប្រភេទ | សំណួរ | ចម្លើយ | ការកែសម្រួលដែលបានស្នើឡើង (ប្រសិនបើចាំបាច់) |
|---|---|---|---|
| **អត្ថបទ និងរូបភាពដែលគាំទ្រដល់សមធម៌ និងបរិវត្តកម្មយេនឌ័រ** | តើ**អត្ថបទ** (អត្ថបទនិទាន/រឿងរ៉ាវ/ករណីសិក្សា/ឧទាហរណ៍/គំរូ។ល។) និង/ **ឬរូបភាព** (រូបថត និងរូបភាពផ្សេងៗទៀតដែលបង្ហាញពីមនុស្ស/តួអង្គ) បង្ហាញមនុស្ស/តួអង្គជាបុរស ដែលមានបុគ្គលិកលក្ខណៈ ចំណាប់អារម្មណ៍ និងសាវតារចម្រុះដែរឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បង្ហាញដោយចេតនា នូវឧទាហរណ៍នៃកុមារា/បុរសដែលមានបុគ្គលិកលក្ខណៈ ចំណាប់អារម្មណ៍ និងសាវតារចម្រុះ។ |
| | តើ**អត្ថបទ** និង/**ឬរូបភាព**បង្ហាញពីការស្តែងឡើងនៃភាពជាបុរសក្នុងលក្ខណៈវិជ្ជមានដែរឬទេ (ឧ.បុរស/កុមារាដែលមិនប្រើហិង្សា មានបរិយាបន្ន ចេះយល់ចិត្ត ចេះបារម្ភ មានការសហការល្អ ឬមានសមធម៌)? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិន | បង្ហាញដោយចេតនា នូវឧទាហរណ៍នៃកុមារា/បុរសដែលចូលរួមក្នុងការប្រាស្រ័យទាក់ទងប្រកបដោយការគោរព មានអាកប្បកិរិយាចេះយល់ចិត្ត ចេះជួយមើលថែទាំ មានការសហការ អាកប្បកិរិយាបែប |

| | | | |
|---|---|---|---|
| | | ពាក់ព័ន្ធ | វិជ្ជមានក្នុងនាមជាអ្នកនៅជិតហេតុការណ៍ (positive bystander behaviour) និងការតស៊ូមតិ ដើម្បីសមភាពយេនឌ័រ។ |
| | **តើអត្ថបទ** និង/ **ឬរូបភាព**បង្ហាញកុមារា និងបុរស ដែលស្តែងអារម្មណ៍គ្រប់បែបយ៉ាង រួមទាំងភាពទន់ខ្សោយ ការភ័យខ្លាច ឬក្តីស្រឡាញ់ ដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បង្ហាញដោយចេតនា នូវឧទាហរណ៍នៃកុមារា/បុរស ដែលស្តែងអារម្មណ៍ដោយបើកចំហ ដូចជា ការភ័យខ្លាច ភាពសោកសៅ ឬក្តីស្រឡាញ់ ដោយគ្មានការខ្មាសអៀន ឬការចំអក។ |
| | **តើអត្ថបទ** និង/ **ឬរូបភាព**បង្ហាញមនុស្ស/តួអង្គជាបុរស ដែលបដិសេធអំពើហិង្សា ឬសម្ពាធពីមិត្តភក្តិ ដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បង្ហាញដោយចេតនា នូវឧទាហរណ៍នៃកុមារា/បុរស ដែលខិតខំបដិសេធអំពើហិង្សា ប្រឆាំងនឹងសម្ពាធពីមិត្តភក្តិ ឬដេញដោលក្រុមដែលបង្កគ្រោះថ្នាក់។ |
| | **តើអត្ថបទ** និង/ **ឬរូបភាព**បង្ហាញកុមារា និងបុរស ដែលចូលរួមក្នុងទំនាក់ទំនងប្រកបដោយការគោរព ដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បង្ហាញដោយចេតនា នូវឧទាហរណ៍នៃកុមារា/បុរស ដែលចូលរួមក្នុងទំនាក់ទំនងប្រកបដោយការគោរព ដែលពោរពេញដោយក្តីស្រឡាញ់ ការយល់ចិត្ត និងការយល់ព្រម។ |

| | | | |
|---|---|---|---|
| | តើ**អត្ថបទ** និង/ ឬ**រូបភាព**បង្ហាញមនុស្ស/តួអង្គជាបុរស ដែលស្វែងរកការគាំទ្រ (ឧ. ជំនួយពីមិត្តភក្តិ សេវាសុខភាព សេវាសុខភាពផ្លូវចិត្ត) ដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បង្ហាញដោយចេតនា នូវឧទាហរណ៍នៃកុមារា/បុរសដែលស្នើសុំជំនួយ ឬស្វែងរកការគាំទ្រ (ឧ. ការប្រឹក្សាយោបល់ ការថែទាំវេជ្ជសាស្ត្រ ឬដំបូន្មានផ្នែកអារម្មណ៍)។ |
| | តើ**អត្ថបទ** និង/ ឬ**រូបភាព**បង្ហាញមនុស្ស/តួអង្គជាបុរស ដែលថែទាំអ្នកដទៃ និងធ្វើការងារផ្ទះ ដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បង្ហាញដោយចេតនា នូវឧទាហរណ៍នៃកុមារា/បុរសដែលបំពេញតួនាទីថែទាំ (ឧ. ការថែទាំកូន បងប្អូន ឬសាច់ញាតិចាស់ជរា) និងចែករំលែកកិច្ចការផ្ទះសម្បែង។ |
| | តើ**អត្ថបទ** និង/ ឬ**រូបភាព**បង្ហាញមនុស្ស/តួអង្គជាបុរសដែលមានរូបរាងកាយ មាឌ និងរបៀបផ្ទាល់ខ្លួនខុសៗគ្នា ដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បង្ហាញឧទាហរណ៍នៃកុមារា/បុរស ដែលឆ្លុះបញ្ចាំងពីរូបរាងកាយ ស្ទីល(របៀបរៀបចំខ្លួន) និងការស្តែងឡើងខុសៗគ្នា។ បញ្ចៀសខ្លឹមសារដែលពង្រឹងគំនិតតួចបង្អៀតនៃភាពទាក់ទាញ ឬធ្វើឱ្យអាម៉ាស់ដល់អ្នក ដែលមិនស្របតាមឧត្តមគតិទាំងនោះ (ឧ. កុមារាដែលមិនខ្ពស់ មិនមានសាច់ដុំ ឬមិនស្លៀកពាក់តាមទម្លាប់មនុស្សប្រុស)។ |

| | | | |
|---|---|---|---|
| | តើ**សម្ភារៈបង្រៀន និងរៀន**មានបញ្ចូលឧទាហរណ៍ ដែលបង្កើនភាពអង់អាចដល់មនុស្សគ្រប់យេនឌ័រ ដើម្បីពង្រីកតួនាទី អត្តសញ្ញាណ និងជម្រើសរបស់ពួកគេ ដែរ ឬទេ? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែម ឬកែសម្រួលខ្លឹមសារ ដើម្បីបញ្ចូលឧទាហរណ៍នៃការផ្តល់ភាពអង់អាចដល់មនុស្សគ្រប់យេនឌ័រ ដែលប្រឆាំងនឹងបទដ្ឋានតឹងរ៉ឹង និងអាច រីកចម្រើននៅក្នុងតួនាទីចម្រុះ។ ចំណុចនេះអាចរួមបញ្ចូលទាំងស្ត្រីកាន់តំណែងជាអ្នកដឹកនាំ ឬប្រឡូកក្នុងវិស័យបច្ចេកទេស និងបុរសនៅក្នុងវិជ្ជាជីវៈថែទាំ។ |
| **ខ្លឹមសារដែលលើកឡើងដោយផ្ទាល់នូវបទដ្ឋានយេនឌ័រជុំវិញភាពជាបុរស** | តើ**កម្មវិធីសិក្សា ឬកម្មវិធីសិក្សាលម្អិត** បានទទួលស្គាល់ ឬលើកឡើងពីបញ្ហាណាមួយ ដែលទាក់ទងជាពិសេសនឹងបទដ្ឋានយេនឌ័រជុំវិញភាពជាបុរស ដែលអាចពាក់ព័ន្ធនឹងខ្លឹមសារក្នុងមុខវិជ្ជាដែរឬទេ? (ឧ. កម្មវិធីសិក្សាលម្អិតសម្រាប់មុខវិជ្ជាអក្សរសិល្ប៍ ដែលជំរុញឱ្យផ្តោតលើរបៀបដែលតួអង្គប្រុសត្រូវបានពណ៌នាក្នុងលក្ខណៈដែលមានអំណាចត្រួតត្រា)។ | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | ឆ្លុះបញ្ចាំងពីរបៀប ដែលបទដ្ឋានយេនឌ័រជុំវិញភាពជាបុរស មានភាពពាក់ព័ន្ធនឹងខ្លឹមសារក្នុងមុខវិជ្ជា និងលើកឡើងពីចំណុចទាំងនេះនៅក្នុងកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងគោលបំណងសិក្សា។ |
| | តើ**សម្ភារៈបង្រៀន និងរៀន**បានទទួលស្គាល់ ឬលើកឡើង យ៉ាងច្បាស់អំពីបញ្ហាណាមួយ ដែលទាក់ទងជាពិសេសនឹងបទដ្ឋានយេនឌ័រជុំវិញភាពជាបុរស ដែលពាក់ព័ន្ធនឹងខ្លឹមសារក្នុងមុខវិជ្ជាដែរ ឬទេ (ឧ. សៀវភៅពុម្ពសុខភាពដែលពិភាក្សាអំពីរបៀបដែលបទដ្ឋាននៃភាពជាបុរស អាចជះឥទ្ធិពលលើអាកប្បកិរិយាប្រថុយប្រថាន)? | ☐ បាទ/ចាស<br>☐ ទេ<br>☐ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | ឆ្លុះបញ្ចាំងពីរបៀប ដែលបទដ្ឋានយេនឌ័រជុំវិញភាពជាបុរស មានភាពពាក់ព័ន្ធនឹងខ្លឹមសារក្នុងមុខវិជ្ជា និងរិះរកវិធីលើកឡើងពីចំណុចទាំងនេះនៅក្នុងសម្ភារៈបង្រៀន និងរៀន។ |

| | | | |
|---|---|---|---|
| | **តើសម្ភារៈបង្រៀន និងរៀន** ផ្តល់នូវសកម្មភាពសិក្សា ឬឱកាសផ្សេងៗទៀតសម្រាប់ឱ្យអ្នកសិក្សា ឆ្លុះបញ្ចាំងអំពីបទដ្ឋានយេនឌ័ររបស់បុរស ផលប៉ះពាល់របស់វា និងរបៀបផ្លាស់ប្តូរបទដ្ឋានយេនឌ័រដែរ ឬទេ? (ឧ. សៀវភៅសិក្សាអក្សរសិល្ប៍ដែលមានសំណួរឆ្លុះបញ្ចាំង លើកទឹកចិត្តឱ្យអ្នកសិក្សាពិចារណាពីរបៀបដែល តួអង្គប្រុស ត្រូវបានពណ៌នាក្នុងលក្ខណៈដែលមានអំណាចត្រួតត្រា របៀបដែលការពណ៌នាទាំងនេះពង្រឹងគំនិតតួចចង្អៀតនៃភាពជាបុរស និងផលប៉ះពាល់ដែលអាចកើតមានឡើង)? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បន្ថែមសំណួរជំរុញការឆ្លុះបញ្ចាំង កិច្ចការពិភាក្សា និង/ ឬកិច្ចការស្រាវជ្រាវ ដែលលើកកម្ពស់ការយល់ដឹងល្អិតល្អន់ អំពីភាពជាបុរសបែបត្រួតត្រា (hegemonic masculinity) ផលប៉ះពាល់ដោយបទដ្ឋាននៃភាពជាបុរសដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង និងសកម្មភាពដែលអាចធ្វើទៅបាន ដើម្បីលើកកម្ពស់ភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព។ |
| **ឱកាសសម្រាប់ឱ្យអ្នកសិក្សាកត់សម្គាល់ និងគិតពិចារណាអំពីបទដ្ឋានយេនឌ័រ ផ្នត់គំនិត និងអំណាច** | **តើសម្ភារៈបង្រៀន និងរៀន** ខិតខំទាញការយកចិត្តទុកដាក់លើភាពស្រដៀងគ្នារវាងកុមារី/កុមារា ស្ត្រី/បុរស ដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | រួមបញ្ចូលខ្លឹមសារ ដែលគូសបញ្ជាក់ពីអារម្មណ៍ បទពិសោធន៍ឬបំណងប្រាថ្នារួមគ្នាក្នុងចំណោមមនុស្សគ្រប់យេនឌ័រ (ឧ. បង្ហាញតួអង្គប្រុស និងតួអង្គស្រីដែលមានចិត្តចំណូលចិត្ត ឬលេងកីឡាដូចគ្នា ឬប្រឈមមុខនឹងបញ្ហាស្រដៀងគ្នា)។ |
| | **តើសម្ភារៈបង្រៀន និងរៀន** ជំរុញឱ្យមានការគិតពិចារណាលើឯកសិទ្ធិរបស់បុរស ការទទួលបានអំណាច និងរបៀបដែលអំណាចត្រូវបានប្រើប្រាស់ ឬត្រូវបានចាត់ទុកជារឿងធម្មតា (taken for granted) ដែរ ឬទេ? | □ បាទ/ចាស<br>□ ទេ<br>□ មិនអាចអនុវត្តបាន/មិនពាក់ព័ន្ធ | បញ្ចូលឧទាហរណ៍ ករណីសិក្សា ឬអត្ថបទ ដែលបង្ហាញពីអំណាច ផ្អែកតាមយេនឌ័រ (ឧ. វិសមភាពនៃការដឹកនាំនៅក្នុងវិជ្ជាជីវៈមួយចំនួន វិសមភាពក្នុងប្រាក់ឈ្នួលឬសេរីភាពនៃការដើរហើរ)។ |

| | | | |
|---|---|---|---|
| | | | ផ្ដល់ឱកាសឱ្យអ្នកសិក្សាវិភាគលំនាំទាំងនោះ និងពិចារណាពីរបៀបដែលបទដ្ឋានយេនឌ័រជះឥទ្ធិពលលើលំនាំទាំងនោះ។ លើកទឹកចិត្តអ្នកសិក្សាឱ្យស្វែងយល់ពីរបៀបដែលអំណាច/ឯកសិទ្ធិអាចត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាវិជ្ជមានដើម្បីជំរុញសមភាព។ |

ប្រភព ៖ អ្នកនិពន្ធ ដោយមានសំណួរមួយចំនួនត្រូវបានកែសម្រួល ឬដកស្រង់ពី Commonwealth of Learning, 2019; Heilman et al., 2017; RTI International, 2015; UNESCO, 2018b.

## ឧបករណ៍ទី ៣. ឧបករណ៍សម្រាប់ណែនាំដល់ការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រ

| | |
|---|---|
| កាលបរិច្ឆេទ ៖ | មុខវិជ្ជា ៖ |
| ប្រភេទសម្ភារៈ ៖ | អ្នកនិពន្ធ/អ្នកអភិវឌ្ឍន៍ ៖ |
| ចំណងជើងសម្ភារៈ ៖ | ភេទរបស់អ្នកនិពន្ធ/អ្នករៀបរៀង/អ្នកអភិវឌ្ឍន៍ ៖ |
| កម្រិតថ្នាក់ ៖ | |

| **ដំណាក់កាល** | **ឱកាស** | **បញ្ជីកិច្ចការដែលត្រូវត្រួតពិនិត្យ** |
|---|---|---|
| **ការរៀបចំប្លង់សម្ភារៈបង្រៀន និងរៀន** | ធានាថាក្រុមអភិវឌ្ឍន៍ សម្ភារៈបង្រៀន និងរៀនមានសមាសភាពចម្រុះ។ | □ អញ្ជើញមនុស្សជាច្រើនឱ្យចូលរួមក្នុងក្រុមអភិវឌ្ឍន៍សម្ភារៈបង្រៀន និងរៀន(អ្នកនិពន្ធ អ្នកអភិវឌ្ឍន៍ និងអ្នករចនា)។ ខិតខំធានាឱ្យមានភាពចម្រុះនៃយេនឌ័រ និងរួមបញ្ចូលអ្នកជំនាញយេនឌ័រ នៅពេលដែលអាចធ្វើទៅបាន។ |
| | ធានាថា ក្រុមអភិវឌ្ឍន៍សម្ភារៈបង្រៀន និងរៀន យល់ដឹងអំពីសារៈសំខាន់នៃការធានាថា ធនធាននេះ គាំទ្រដល់បរិវត្តកម្មយេនឌ័រនិងយុទ្ធសាស្ត្រចាំបាច់ដើម្បីសម្រេចគោលដៅនេះ។ | □ ផ្តល់ការបណ្តុះបណ្តាលដល់អ្នកនិពន្ធ អ្នកអភិវឌ្ឍន៍ អ្នករចនា និងអ្នកផ្សេងទៀតដែលពាក់ព័ន្ធក្នុងដំណើរការអភិវឌ្ឍន៍សម្ភារៈបង្រៀន និងរៀន ស្តីពីរបៀបអនុវត្តទស្សនទានបរិវត្តកម្មយេនឌ័រនៅក្នុងការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន។ |

| | | |
|---|---|---|
| | ពិចារណាថា តើយេនឌ័រមានភាពពាក់ព័ន្ធដូចម្តេចនឹងមុខវិជ្ជា ឬប្រធានបទតាំងពីដើមដំបូង និងរិះរកវិធីដោះស្រាយបញ្ហាយេនឌ័រ។ | □ រិះរកវិធីធ្វើយ៉ាងណាឱ្យយេនឌ័រមានភាពពាក់ព័ន្ធនឹងគោលដៅសិក្សានៃមុខវិជ្ជា/ប្រធានបទ (សម្រាប់ឧទាហរណ៍ សូមមើល តារាងទី ២)។<br>□ កំណត់រកកត្តាផ្សេងទៀតដែលមានទំនាក់ទំនងជាមួយយេនឌ័រ ដែលគួរលើកមកពិចារណា (ឧ. ស្ថានភាពសេដ្ឋកិច្ចសង្គម សាសនា សមត្ថភាព ទីតាំងភូមិសាស្ត្រ។ល។)។ |
| | ប្រើប្រាស់ប្លង់លម្អិតនៃសម្ភារៈបង្រៀន និងរៀន ដែលកំពុងត្រូវបានអភិវឌ្ឍឡើង(ឧ.បញ្ជីនៃផ្នែកឬជំពូកសំខាន់ៗ)ដើម្បីរៀបចំប្លង់ថាតើត្រង់ផ្នែកណាដែលនឹងមានកិច្ចខិតខំប្រឹងប្រែងដាក់បញ្ចូលខ្លឹមសារ និងលំហាត់ដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រ *(ឧ. ក្នុងសេចក្តីផ្តើម/ជំពូកទី៣/សំណួរទី១០/ឧទាហរណ៍ទី ៨។ល។)* | □ កំណត់ថាតើត្រង់ផ្នែកណាខ្លះ ដែលគេអាចលើកឡើងបានច្បាស់អំពីយេនឌ័រនៅក្នុងសម្ភារៈបង្រៀន និងរៀនទាំងមូល។<br>□ កំណត់រកឱកាសទាក់ទាញអ្នកសិក្សាឱ្យចូលរួមគិតពិចារណាអំពីបទដ្ឋានយេនឌ័រដែលពាក់ព័ន្ធ និងផលប៉ះពាល់របស់វា (ឧ. ប្រអប់ឆ្លុះបញ្ចាំងនៅក្នុងសៀវភៅប្រវត្តិវិទ្យា សំណួរគណិតវិទ្យាដែលទាក់ទងនឹងប្រាក់ឈ្នួលមិនស្មើគ្នា។ល។)។<br>□ កំណត់រកឱកាសទាក់ទាញអ្នកសិក្សាឱ្យចូលរួមពិចារណាអំពីរបៀបផ្លាស់ប្តូរ និងដោះស្រាយបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង។<br>□ កំណត់រកឱកាសឆ្លុះបញ្ចាំងពីរបៀប ដែលយេនឌ័រមានទំនាក់ទំនងជាមួយទិដ្ឋភាពផ្សេងទៀតនៃអត្តសញ្ញាណដែលពាក់ព័ន្ធនឹងខ្លឹមសារក្នុងមុខវិជ្ជា (ឧ. ស្ថានភាពសេដ្ឋកិច្ចសង្គម ជាតិពន្ធុ ពិការភាព ភាសា ឬសាសនា)។<br>□ បញ្ចូលខ្លឹមសារដែលជួយឱ្យអ្នកសិក្សាស្វែងយល់ពីភាពប្រទាក់ក្រឡាគ្នាទាំងនេះ និងផលប៉ះពាល់របស់វា។ |

| | | |
|---|---|---|
| **ការសរសេរ និងការអភិវឌ្ឍខ្លឹមសារ** | ផ្តោតលើ ការបង្ហាញញឹកញាប់ដូចគ្នា អំពីមនុស្ស/តួអង្គ ដែលមានយេនឌ័រខុសៗគ្នានៅក្នុងអត្ថបទ | ☐ ប្រើប្រាស់អត្ថបទ រឿងរ៉ាវ ករណីសិក្សា ឧទាហរណ៍ និងបុគ្គលគំរូ ដែលបង្ហាញកុមារី/ស្ត្រី និងកុមារា/បុរស ក្នុងចំនួនប្រហាក់ប្រហែលគ្នា។<br>☐ បង្ហាញមនុស្សគ្រប់យេនឌ័រដែលត្រូវបានផ្តល់តម្លៃចំពោះគុណសម្បត្តិ និងសមិទ្ធផលផ្សេងៗគ្នា (ឧ. នវានុវត្តន៍ការច្នៃប្រឌិត សមិទ្ធផលឬលទ្ធផលសិក្សា)។<br>☐ បញ្ចូលឧទាហរណ៍ និងរឿងរ៉ាវវិជ្ជមានដែលឆ្លុះបញ្ចាំងពីភាពចម្រុះនៃយេនឌ័រ។ ជានាថា ចំណុចទាំងនេះត្រូវបានពណ៌នាក្នុងន័យវិជ្ជមាន និងប្រកបដោយការគោរព និងបញ្ចៀសការបង្ហាញបែបបង្កប់ផ្នត់គំនិតចាស់គម្រិល។ |
| | ប្រើប្រាស់ភាសាដែលគាំទ្រដល់សមធម៌យេនឌ័រ និងបរិយាបន្ន | ☐ ប្រើប្រាស់ពាក្យអព្យាក្រឹតយេនឌ័រ (ឧ. 'មនុស្ស' ជាជាង 'បុរស និងស្ត្រី') និងពាក្យប្រកបដោយបរិយាបន្ន (ឧ. មន្ត្រីនគរបាល ប្រធានអង្គប្រជុំ-chairperson ឬអ្នកសម្អាត-cleaner) ហើយក្នុងពេលជាមួយគ្នានោះបញ្ចៀសការប្រើពាក្យដែលចាត់ទុកបុរសជាគោល (ឧ. ការប្រើតែសព្វនាម 'គាត់[he]' ប្រើពាក្យ 'បុរស [men]' ដើម្បីសំដៅលើមនុស្សទាំងអស់) ឬពាក្យដែលមានលក្ខណៈសម្គាល់យេនឌ័រ (ឧ. នគរបាលប្រុស-policeman ប្រធានអង្គប្រជុំ-chairman ឬស្ត្រីបោសសម្អាត)។<br>☐ ប្រើប្រាស់ពាក្យជារួមដែលប្រកបដោយបរិយាបន្ន (ឧ. 'អ្នកសិក្សា' ជាជាង 'កុមារា និងកុមារី')។<br>☐ ជានាថា សំនៀងទឹកដមដែលគេប្រើដើម្បីពណ៌នាមនុស្សដែលមានយេនឌ័រខុសៗគ្នា មានតុល្យភាព មិនពង្រឹងផ្នត់គំនិត និងមិនពណ៌នាយេនឌ័រមួយចំនួនមួយក្នុងលក្ខណៈអវិជ្ជមាន ឬបង្គ្រោះថ្នាក់ឡើយ។<br>☐ ប្រសិនបើមនុស្ស/តួអង្គទាំងពីរភេទលេចឡើងក្នុងអត្ថបទតែមួយ ត្រូវផ្លាស់ប្តូរលំដាប់លំដោយឆ្លាស់គ្នានៅក្នុងអត្ថបទទាំងមូល។ |

| | | |
|---|---|---|
| | អត្ថបទដែលគាំទ្រដល់សមធម៌ និងបរិវត្តកម្មយេនឌ័រ | □ ធានាឱ្យមានការបង្ហាញយេនឌ័រប្រកបដោយតុល្យភាព ពាក់ព័ន្ធនឹងអ្នកដែលបំពេញកិច្ចការផ្ទះសម្បែង និង កិច្ចការជាអ្នកថែទាំ។<br>□ ធានាឱ្យមានការបង្ហាញយេនឌ័រប្រកបដោយតុល្យភាពនៅក្នុងវិជ្ជាជីវៈចម្រុះ។<br>□ ធានាឱ្យមានការបង្ហាញយេនឌ័រប្រកបដោយតុល្យភាពនៅក្នុងតួនាទីជាអ្នកដឹកនាំ និងអ្នកគាំទ្រ។<br>□ បញ្ចូលការបង្ហាញអំពីកុមារី កុមារា ស្ត្រី និងបុរស ដែលប្រើប្រាស់ឧបករណ៍ឌីជីថល។<br>□ រិះរកឱកាសបង្ហាញដោយចេតនានូវមនុស្ស/តួអង្គដែលចូលរួមក្នុងសកម្មភាព និងតួនាទីដែលផ្ទុយពីផ្នត់គំនិតយេនឌ័រ (ឧ. បុរសជាអ្នកថែទាំកូនជាចម្បង ឬបុរសជាគិលានុបដ្ឋាក ហើយស្ត្រីជាអ្នកបើកបរឡានដឹកទំនិញ ឬជាមេដឹកនាំនយោបាយ)។ ធានាថា ពួកគេត្រូវបានពណ៌នាក្នុងន័យវិជ្ជមាន។<br>□ រិះរកឱកាសបង្ហាញដោយចេតនានូវមនុស្ស/តួអង្គ ដែលមានលក្ខណៈចិត្តសាស្ត្រផ្ទុយពីផ្នត់គំនិតយេនឌ័រ (ឧ. ពណ៌នាកុមារី/ស្ត្រីថាក្លាហាន និងក្រមិចក្រមើម និងពណ៌នាកុមារា/បុរសថាចិត្តល្អ ចេះបង្ហាញអារម្មណ៍ និង ចេះយល់ចិត្ត)។<br>□ ខិតខំពណ៌នាទំនាក់ទំនងរវាងមនុស្សដែលមានយេនឌ័រខុសៗគ្នា ដែលឆ្លុះបញ្ចាំងពីការគោរពគ្នាទៅវិញទៅមក កិច្ចសហការ និងដេញដោលឋានានុក្រមបែបប្រពៃណី និងទំនាក់ទំនងអំណាចមិនស្មើគ្នា។<br>□ បញ្ចូលបុគ្គលគំរូជាបុរស និងស្ត្រី។ ខិតខំបង្ហាញពីវ័យ និងសមិទ្ធផលចម្រុះ។ |
| | ការយកចិត្តទុកដាក់លើភាពប្រទាក់ក្រឡាគ្នា (Intersectionality) | □ រួមបញ្ចូលមនុស្ស/តួអង្គដែលមានសាវតារ និងអត្តសញ្ញាណចម្រុះ (ពិចារណាពីសមត្ថភាព ភាសា ពូជសាសន៍/ជាតិពន្ធុ ទំនោរផ្លូវភេទ។ល។)។<br>□ បង្ហាញមនុស្ស/តួអង្គមកពីក្រុមដែលធ្លាប់តែមានតំណាងតិចតួច ឬក្រុមដែលត្រូវគេផាត់ចេញពីសង្គម នៅក្នុងតួនាទីជាអ្នកដឹកនាំ និងអ្នកគាំទ្រ។ |

| | | |
|---|---|---|
| | | □ បង្ហាញពីមនុស្ស/តួអង្គពហុវិមាត្រដែលមានអត្តសញ្ញាណចំរុះនិងប្រទ្បាក់ក្រទ្បាគ្នា (ឧ. ម្តាយដែលជាវេជ្ជបណ្ឌិត និងជាជនជាតិភាគតិច ឪពុកដែលជាអ្នកវិទ្យាសាស្ត្រ និងមានពិការភាព)។ |
| | ឱកាសសម្រាប់ឱ្យអ្នកសិក្សាកត់សម្គាល់ និងគិតពិចារណាល្អិតល្អន់ អំពីបទដ្ឋានយេនឌ័រ ផ្នត់គំនិត និងឌីណាមិកអំណាច | □ បន្ថែមចំណុចជំរុញការឆ្លុះបញ្ចាំង សំណួរ កិច្ចការពិភាក្សា ឬកិច្ចការស្រាវជ្រាវ ដែលស្វែងយល់យ៉ាងច្បាស់លាស់អំពីបទដ្ឋានយេនឌ័រ ផលប៉ះពាល់របស់វា និងសកម្មភាពដែលអាចធ្វើទៅបានដើម្បីការផ្លាស់ប្តូរជាវិជ្ជមាន។<br>□ បញ្ចូលបញ្ហា និងទស្សនៈវិស័យចម្រុះទាក់ទងនឹងយេនឌ័រ រួមទាំងបញ្ហា និងទស្សនៈវិស័យដែលប៉ះពាល់ដល់កុមារា និងកុមារី។<br>□ ក្នុងផ្នែកដែលមានការបង្ហាញទិន្នន័យ ត្រូវធានាថា ទិន្នន័យទាំងនោះត្រូវបានបំបែកតាមភេទ និងកត្តាប្រទាក់ក្រទ្បាគ្នាផ្សេងទៀត ដូចជា សមត្ថភាព ស្ថានភាពសេដ្ឋកិច្ចសង្គម ឬទីតាំងភូមិសាស្ត្រ ដើម្បីទាញយករបៀបដែលយេនឌ័រមានទំនាក់ទំនងជាមួយទម្រង់វិសមភាពផ្សេងទៀត (ក្នុងករណីដែលមានទិន្នន័យបែបនេះ)។ |

| | | |
|---|---|---|
| | ការបង្ហាញពីភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព | ◻ បង្ហាញដោយចេតនានូវឧទាហរណ៍នៃកុមារា/បុរស ដែលមានបុគ្គលិកលក្ខណៈ ចំណាប់អារម្មណ៍ និងសាវតារចម្រុះ។<br>◻ បង្ហាញដោយចេតនានូវឧទាហរណ៍នៃកុមារា/បុរស ដែលចូលរួមក្នុងការប្រាស្រ័យទាក់ទងប្រកបដោយការគោរព អាកប្បកិរិយាយល់ចិត្ត ការថែទាំ ការសហការ អាកប្បកិរិយាវិជ្ជមានក្នុងនាមជាអ្នកនៅជិត ហេតុការណ៍ និងការតស៊ូមតិដើម្បីសមភាពយេនឌ័រ។<br>◻ បង្ហាញដោយចេតនានូវឧទាហរណ៍នៃកុមារា/បុរស ដែលស្តែងអារម្មណ៍ដោយបើកចំហ ដូចជា ការភ័យខ្លាច ភាពសោកសៅ ឬក្តីស្រឡាញ់ ដោយគ្មានការខ្មាសអៀន ឬការចំអក។<br>◻ បង្ហាញដោយចេតនានូវឧទាហរណ៍នៃកុមារា/បុរស ដែលខិតខំបដិសេធអំពើហិង្សា ប្រឆាំងនឹងសម្ពាធពីមិត្តភក្តិ ឬចេះដោះស្រាយបញ្ហាប្រឈមនៃឥទ្ធិពលពីក្រុមដែលបង្កគ្រោះថ្នាក់។<br>◻ បង្ហាញដោយចេតនានូវឧទាហរណ៍នៃកុមារា/បុរស ដែលចូលរួមក្នុងទំនាក់ទំនងប្រកបដោយការគោរព ដែលពោរពេញដោយក្តីស្រឡាញ់ ការយល់ចិត្ត និងការយល់ព្រម។<br>◻ បង្ហាញដោយចេតនានូវឧទាហរណ៍នៃកុមារា/បុរសដែលស្នើសុំជំនួយ ឬស្វែងរកការគាំទ្រ (ឧ. ការប្រឹក្សាយោបល់ ការថែទាំវេជ្ជសាស្ត្រ ឬជំរុញផ្នែកអារម្មណ៍)។ |

| | | |
|---|---|---|
| | | □ បង្ហាញដោយចេតនានូវឧទាហរណ៍នៃកុមារ/បុរសដែលបំពេញតួនាទីថែទាំ (ឧ. ការថែទាំបងប្អូន សាច់ញាតិចាស់ជរា និងចែករំលែកកិច្ចការផ្ទះសម្បែង)។<br>□ បង្ហាញដោយចេតនានូវឧទាហរណ៍នៃកុមារ/បុរសដែលឆ្លុះបញ្ចាំងពីរូបរាងកាយ ស្ទីល(របៀបតុបតែងខ្លួន) និងការស្តែងឡើងខុសៗគ្នា។ បញ្ចៀសខ្លឹមសារដែលពង្រឹងឧត្តមគតិតូចចង្អៀតនៃភាពទាក់ទាញ ឬធ្វើឱ្យអាម៉ាស់ដល់អ្នកដែលមិនស្របតាមឧត្តមគតិទាំងនោះ (ឧ. កុមារដែលមិនខ្ពស់ មិនមានសាច់ដុំ ឬមិនស្លៀកពាក់តាមទម្លាប់របស់មនុស្សប្រុសជាដើម)។<br>□ ការបង្ហាញរូបភាព សំណួរ និងឧទាហរណ៍ ដែលដេញដោលផ្នត់គំនិតចង្អៀតចង្អល់នៃភាពជាបុរស។<br>□ ឆ្លុះបញ្ចាំងពីរបៀបដែលបទដ្ឋានយេនឌ័រជុំវិញភាពជាបុរស មានភាពពាក់ព័ន្ធនឹងខ្លឹមសារក្នុងមុខវិជ្ជា ហើយលើកឡើងចំណុចទាំងនេះនៅក្នុងកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងគោលបំណងសិក្សា។<br>□ ឆ្លុះបញ្ចាំងពីរបៀបដែលបទដ្ឋានយេនឌ័រជុំវិញភាពជាបុរស មានភាពពាក់ព័ន្ធនឹងខ្លឹមសារក្នុងមុខវិជ្ជា និងរិះរកវិធីបង្ហាញចំណុចទាំងនេះនៅក្នុងសម្ភារៈបង្រៀន និងរៀន។<br>□ បន្ថែមសំណួរជំរុញការឆ្លុះបញ្ចាំង កិច្ចការពិភាក្សា ឬកិច្ចការស្រាវជ្រាវ ដែលស្វែងយល់អំពីបទដ្ឋានយេនឌ័រសម្រាប់បុរស ផលប៉ះពាល់របស់វា និងសកម្មភាពសម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាន។ |
| **ការរចនារូបភាព និងប្លង់** | ភាពញឹកញាប់នៃការបង្ហាញនៅក្នុងរូបភាព | □ ជ្រើសរើស ឬរចនារូបភាពដែលបង្ហាញកុមារី/កុមារា និងស្ត្រី/បុរស ក្នុងចំនួនប្រហាក់ប្រហែលគ្នា។<br>□ ជ្រើសរើស ឬរចនារូបភាពបែបវិជ្ជមាន ដែលមិនបង្ហាញច្បាស់អំពីយេនឌ័រ។<br>□ ធានាថា កុមារី/កុមារា/ស្ត្រី/បុរស ត្រូវបានបង្ហាញវត្តមានទាំងនៅក្នុងទីធ្លាខាងក្នុង និងខាងក្រៅ (ឧ. នៅក្នុងផ្ទះ ក្នុងទីប្រជុំជន សាលា និងក្នុងថ្នាក់រៀន) ញឹកញាប់ប្រហាក់ប្រហែលគ្នា។<br>□ ធានាថា កុមារី/កុមារា/ស្ត្រី/បុរស បង្ហាញវត្តមានចូលរួមក្នុងសកម្មភាពផ្សេងៗ (ឧ. កីឡា កិច្ចការថែទាំ ការងារមាន |

| | | |
|---|---|---|
| | | ប្រាក់ឈ្នួល) ញឹកញាប់ប្រហាក់ប្រហែលគ្នា។<br>□ ជានាថា រូបថត និងរូបភាពផ្សេងៗទៀតនៃតួអង្គ/មនុស្សដែលតំណាងឱ្យយេនឌ័រខុសៗគ្នា មានទំហំ និងភាពលេចធ្លោប៉ុនគ្នា។ |
| | រូបភាពដែលគាំទ្រដល់សមធម៌ និងបរិវត្តកម្មយេនឌ័រ | □ ធានាឱ្យមានការបង្ហាញយេនឌ័រប្រកបដោយតុល្យភាព ពាក់ព័ន្ធនឹងអ្នកដែលបំពេញតួនាទីធ្វើកិច្ចការផ្ទះ និងតួនាទីថែទាំ។<br>□ ធានាឱ្យមានការបង្ហាញយេនឌ័រប្រកបដោយតុល្យភាពនៅក្នុងវិជ្ជាជីវៈចម្រុះ។<br>□ ធានាឱ្យមានការបង្ហាញយេនឌ័រប្រកបដោយតុល្យភាពនៅក្នុងតួនាទីជាអ្នកដឹកនាំ និងអ្នកគាំទ្រ។<br>□ បញ្ចូលការបង្ហាញអំពីកុមារី/កុមារា/ស្ត្រី/បុរស ដែលប្រើប្រាស់ឧបករណ៍ឌីជីថល។<br>□ រិះរកឱកាសបង្ហាញដោយចេតនានូវមនុស្ស/តួអង្គដែលចូលរួមក្នុងសកម្មភាព និងតួនាទីដែលផ្ទុយពីផ្នត់គំនិតយេនឌ័របែបប្រពៃណី (ឧ. បុរសជាអ្នកថែទាំកូនចម្បង ឬជាគិលានុបដ្ឋាក ហើយស្ត្រីជាអ្នកបើកបរឡានដឹកទំនិញ ឬជាមេដឹកនាំនយោបាយ)។ ធានាថា ពួកគេត្រូវបានពណ៌នាក្នុងន័យវិជ្ជមាន។ |
| **ការត្រួតពិនិត្យពីខាងក្រៅ** | វិភាគសេចក្ដីព្រាងចុងក្រោយ ដើម្បីរកមើលភាពញឹកញាប់នៃការបង្ហាញ និងខ្លឹមសារដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រ | □ ប្រើប្រាស់ឧបករណ៍វិភាគដែលមានរចនាសម្ព័ន្ធច្បាស់លាស់ (ឧ. ឧបករណ៍ទី ១) ដើម្បីវាយតម្លៃថាតើសេចក្ដីព្រាងនេះគាំទ្រដល់បរិវត្តកម្មយេនឌ័រខ្លាំងប៉ុណ្ណា និងចំណុចណាខ្លះដែលអាចកែលម្អបាន។ |
| | ស្នើឱ្យមានការត្រួតពិនិត្យ និងមតិកែលម្អ | □ ជួលអ្នកជំនាញយេនឌ័រឱ្យពិនិត្យសម្ភារៈបង្រៀន និងរៀន និងផ្ដល់មតិកែលម្អបែបស្ថាបនា។<br>□ ស្នើសុំមតិកែលម្អពីគ្រូបង្រៀន អ្នកសិក្សា និងតំណាងសហគមន៍ដែលមានសាវតារផ្សេងៗគ្នា (រួមទាំងអ្នកដែល |

| | | |
|---|---|---|
| | | តែងត្រូវបានគេផាត់ចេញពីសង្គម ឬមិនសូវមានតំណាង)។ |
| | ធ្វើតេស្តសាកល្បងសម្ភារៈបង្រៀន និងរៀន | □ ធ្វើតេស្តសាកល្បងសម្ភារៈបង្រៀន និងរៀននៅក្នុងថ្នាក់រៀន និង/ ឬស្នើសុំឱ្យអ្នកសិក្សា និងគ្រូពិនិត្យមើល និងផ្តល់មតិកែលម្អ។ |
| | បញ្ចប់ជាស្ថាពរ | □ ប្រើប្រាស់មតិកែលម្អពីអ្នកជំនាញ និងការសាកល្បង ដើម្បីបញ្ចប់សម្ភារៈបង្រៀន និងរៀនជាស្ថាពរ។ |

*ប្រភព ៖* អ្នកនិពន្ធ ដោយមានសំណួរមួយចំនួនត្រូវបានកែសម្រួល ឬដកស្រង់ពី *Commonwealth of Learning, 2019; Heilman et al., 2017; RTI International, 2015; UNESCO, 2018b.*

## ៣.៦ ការអនុវត្តទស្សនទានបរិវត្តកម្មយេនឌ័រនៅពេលបង្រៀន ដោយប្រើប្រាស់សម្ភារៈបង្រៀន និងរៀនដែលមានស្រាប់

ជាការល្អគួរផ្តល់ការណែនាំច្បាស់លាស់ដល់អ្នកអប់រំអំពីរបៀបអនុវត្តអភិក្រមបរិវត្តកម្មយេនឌ័រ នៅពេលបង្រៀន ដោយប្រើប្រាស់សម្ភារៈបង្រៀន និងរៀនដែលមានស្រាប់ ព្រោះថាសូម្បីតែក្នុងករណីដែលសៀវភៅសិក្សា និងធនធានផ្សេងទៀតមិនទាន់ត្រូវបានកែសម្រួលក៏ដោយ ក៏លោកគ្រូអ្នកគ្រូអាចដើរតួនាទីយ៉ាងមានឥទ្ធិពលក្នុងការដេញដោលបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង និងជំរុញឱ្យមានបទដ្ឋានដែលវិជ្ជមាន និងប្រកបដោយសុខុមាលភាព។

ឧបករណ៍ទី ៤ ផ្តល់នូវបញ្ជីត្រួតពិនិត្យដ៏សាមញ្ញមួយ ដែលអ្នកអប់រំអាចប្រើប្រាស់ដើម្បីអនុវត្តទស្សនទានបរិវត្តកម្មយេនឌ័រ នៅពេលរៀបចំ និងអនុវត្តការបង្រៀន។ បន្ថែមពីនេះ លោកគ្រូអ្នកគ្រូ និងអ្នកអប់រំផ្សេងទៀត អាចរៀនអនុវត្តគរុកោសល្យដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រ នៅក្នុងការបង្រៀន និងទំនាក់ទំនងប្រចាំថ្ងៃរបស់ពួកគាត់ជាមួយអ្នកសិក្សា (FAWE, 2018; UNESCO, 2020d, សៀវភៅណែនាំសម្រាប់អ្នកអប់រំស្តីពីការលើកបាំចេញ)។ នេះមានន័យថាជាការបង្កើតបរិយាកាសរៀនសូត្រ ដែលអ្នកសិក្សាទាំងអស់ត្រូវបានគោរព និងផ្តល់តម្លៃ ហើយបច្ចេកទេសនិងយុទ្ធសាស្ត្របង្រៀនខិតខំដោះស្រាយបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់និងតឹងរ៉ឹង គាំទ្រដល់អ្នកសិក្សាគ្រប់លក្ខណៈចម្រុះ និងលើកកម្ពស់សមភាព។ ចំណុចនេះត្រូវបានស្វែងយល់បន្ថែមនៅក្នុងផ្នែកទី ៤។

| *ឧបករណ៍ទី ៤. បញ្ជីត្រួតពិនិត្យសម្រាប់អ្នកអប់រំក្នុងការប្រើប្រាស់ទស្សនទានបរិវត្តកម្មយេនឌ័ររួមជាមួយនឹងសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់* | |
|---|---|
| **យុទ្ធសាស្ត្រ** | **សំណួរឆ្លុះបញ្ចាំង** |
| ពិនិត្យ និងកែសម្រួលសម្ភារៈបង្រៀន និងរៀន | □ រកមើលបទដ្ឋាន និងផ្នត់គំនិតយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង ដែលអាចលើកមកជជែក ឬកែសម្រួលឡើងវិញ។<br>□ កែសម្រួល ឬបន្ថែមឧទាហរណ៍ ដើម្បីបង្ហាញពីតួនាទី និងអត្តសញ្ញាណយេនឌ័រដ៏ទូលំទូលាយ។<br>□ កែសម្រួល ឬបន្ថែមឧទាហរណ៍ដើម្បីផ្តល់ការបង្ហាញអំពីកុមារី/ស្ត្រី និងកុមារា/បុរសក្នុងលក្ខណៈដែលផ្ទុយពីផ្នត់គំនិតយេនឌ័រ។ |

| | |
|---|---|
| ឱ្យសិស្សគិតពិចារណាល្អិតល្អន់អំពីយេនឌ័រ | □ បង្កើតឱកាសឱ្យអ្នកសិក្សាវិភាគលើរបៀប ដែលយេនឌ័រត្រូវបានពណ៌នានៅក្នុងសម្ភារៈបង្រៀន និងរៀន (ចំណុចនេះអាចពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍វិភាគ)។<br>□ ឆ្លុះបញ្ចាំងពីផលប៉ះពាល់នៃការពណ៌នាអំពីយេនឌ័រ មកលើកុមារី កុមារា ស្ត្រី និងបុរស។<br>□ ពិភាក្សាថា តើការដាក់សម្ពាធឱ្យអនុលោមតាមគំនិតលេចធ្លោនៃភាពជាបុរសអាចធ្វើឱ្យប៉ះពាល់ដូចម្តេចដល់ការចូលរួមក្នុងការសិក្សារបស់កុមារា និងរបៀបផ្លាស់ប្តូរការអនុវត្តបែបនេះ។<br>□ ពិចារណាអំពីរបៀប ដែលយេនឌ័រមានទំនាក់ទំនងជាមួយទិដ្ឋភាពផ្សេងទៀតនៃអត្តសញ្ញាណ ដូចជា សមត្ថភាព ស្ថានភាពសេដ្ឋកិច្ចសង្គមឬទីតាំងភូមិសាស្ត្រ និងថាតើទំនាក់ទំនងទាំងនេះជះឥទ្ធិពលដូចម្តេចលើការបង្ហាញ បរិយាបន្ន និងការពង្រឹង ឬការដោះស្រាយបទដ្ឋាន និងផ្នត់គំនិត។<br>□ សម្របសម្រួលការពិភាក្សាអំពីការបង្ហាញ សំឡេង និងអំណាច។<br>□ បង្កើតឱកាសសម្រាប់ការឆ្លុះបញ្ចាំងជាពិសេសអំពីរបៀប ដែលភាពជាបុរសត្រូវបានបង្ហាញឡើង និងថាតើវាមានលក្ខណៈរឹតត្បិតដែរ ឬទេ។<br>□ ឱ្យសិស្សពិចារណាអំពីរបៀបផ្លាស់ប្តូរសម្ភារៈបង្រៀននិងរៀនឱ្យបង្ហាញ និងសាទរចំពោះលទ្ធភាព និងរបៀបរស់នៅចម្រុះសម្រាប់កុមារី កុមារា ស្ត្រីនិងបុរស។ |
| ជ្រើសរើស និងប្រើប្រាស់ធនធានបន្ថែមទៀតដែលគាំទ្រដល់ បរិវត្តកម្មយេនឌ័រ ទន្ទឹមនឹងសម្ភារៈបង្រៀន និងរៀនដែលបានកំណត់ | □ ស្វែងរក និងប្រើប្រាស់សម្ភារៈបង្រៀន និងរៀនដែលបង្ហាញពីមនុស្សគ្រប់អត្តសញ្ញាណយេនឌ័រ និងដោះស្រាយបទដ្ឋាន និងផ្នត់គំនិតយេនឌ័រដែលបង្កគ្រោះថ្នាក់។<br>□ ប្រើប្រាស់រឿងរ៉ាវ រូបភាព ឬវីដេអូ ដែលបង្ហាញកុមារី កុមារា ស្ត្រី និងបុរស នៅក្នុងសកម្មភាព និងតួនាទី យ៉ាងទូលំទូលាយ។<br>□ បញ្ចូលសម្ភារៈបង្រៀន និងរៀន ដែលបង្ហាញកុមារា និងបុរសចូលរួមយ៉ាងសកម្មក្នុងការរៀនសូត្រ ការងារថែទាំ និងការបង្ហាញអារម្មណ៍ ដើម្បីពង្រីកគំនិតអំពីភាពជាបុរស។<br>□ ជ្រើសរើសសម្ភារៈបង្រៀន និងរៀនដែលមានបញ្ចូលបុរសគំរូ ដែលបង្ហាញការយល់ចិត្ត ការថែទាំ ភាពថ្លៃថ្នូរប្រកបដោយ ឬការគោរពចំពោះអ្នកដទៃ។<br>□ ជ្រើសរើសសម្ភារៈបង្រៀន និងរៀន ដែលមានបញ្ចូលស្ត្រីគំរូ ដែលបង្ហាញភាព |

| | |
|---|---|
| | ជោគជ័យក្នុងការដឹកនាំ និងនៅក្នុងសកម្មភាព និងវិជ្ជាជីវៈដែលធ្លាប់តែគ្របដណ្ដប់ដោយបុរស។ |
| តាំងបង្ហាញសម្ភារៈបង្រៀននិងរៀនដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រនៅក្នុងថ្នាក់រៀន និងមជ្ឈដ្ឋានអប់រំទាំងមូល | ◻ តាំងបង្ហាញផ្ទាំងបដា រូបភាព ឬស្នាដៃរបស់សិស្សនៅក្នុងថ្នាក់រៀន និងមជ្ឈដ្ឋានសាលារៀនទាំងមូល ដើម្បីលើកកម្ពស់បរិយាបន្នយេនឌ័រ។<br>◻ ស្វែងរក និងតាំងបង្ហាញសម្ភារៈបង្រៀន និងរៀន (ឧ. ផ្ទាំងបដា) ដែលបង្ហាញកុមារា កុមារី បុរស និងស្ត្រីនៅក្នុងសកម្មភាព និងតួនាទីយ៉ាងទូលំទូលាយ។ |

*ប្រភព ៖* អ្នកនិពន្ធ

***ចំណុចសំខាន់ៗដែលត្រូវចងចាំ ៖***

- ការអភិវឌ្ឍន៍សម្ភារៈបង្រៀន និងរៀន(TLMs)ដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រធានាបាននូវ ការបង្ហាញពីកញ្ចប់ដូចគ្នានូវមនុស្សដែលមានយេនឌ័រខុសៗគ្នាហើយទន្ទឹមនឹងនោះខិតខំដោះស្រាយបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងតឹងរ៉ឹង ព្រមទាំងលើកកម្ពស់បទដ្ឋានដែលវិជ្ជមាន។
- ខ្លឹមសារដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រ អាចបញ្ចូលទៅក្នុងមុខវិជ្ជាទាំងអស់។
- មានយុទ្ធសាស្ត្រជាច្រើនដើម្បីអនុវត្តទស្សនទានយេនឌ័រ នៅក្នុងដំណើរការត្រួតពិនិត្យ ឬការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន។
- ក្រុមការងារដែលមានតួនាទីវិភាគ កែសម្រួល ឬអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន អាចកែសម្រួល និងប្រើប្រាស់ឧបករណ៍ដែលបានផ្ដល់ជូន ដើម្បីជួយដល់ការវិភាគ ការកែសម្រួល និងការអភិវឌ្ឍ ដើម្បីឱ្យផលិតផលចុងក្រោយគាំទ្រដល់បរិវត្តកម្មយេនឌ័រ។
- ទោះបីជាគ្មានការកែទម្រង់កម្មវិធីសិក្សាពេញលេញក៏ដោយ ក៏អ្នកអប់រំអាចកែសម្រួល និងប្រើប្រាស់ សម្ភារៈបង្រៀន និងរៀនដែលមានស្រាប់ តាមរបៀបការជជែកដេញដោលបទដ្ឋានដែលបង្កគ្រោះថ្នាក់ និងជំរុញឱ្យមានសមភាព និងបរិយាបន្ន។

# ៤. ការដាក់បញ្ចូលសម្ភារៈបង្រៀន និងរៀននៅក្នុងអភិក្រមបរិវត្តកម្មយេនឌ័រដ៏ទូលំទូលាយ

នៅពេលបញ្ចប់ផ្នែកនេះ អ្នកអាននឹង ៖

- ✓ យល់ដឹងថា ការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀន (TLMs) មានប្រសិទ្ធភាពបំផុតនៅពេលដាក់បញ្ចូលទៅក្នុងសាលារៀន និងប្រព័ន្ធអប់រំដ៏ទូលំទូលាយ ដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រ។
- ✓ យល់ច្បាស់អំពីចំណុចចាប់ផ្តើមជាច្រើននៅក្នុងប្រព័ន្ធអប់រំទាំងមូលដែលអាចយកមកប្រើប្រាស់ដើម្បីគាំទ្រ និងពង្រឹងការផ្លាស់ប្តូរដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រ។
- ✓ ទទួលស្គាល់សារៈសំខាន់នៃការលើកកម្ពស់ភាពជាបុរសដែលមានលក្ខណៈចម្រុះ វិជ្ជមាននិងប្រកបដោយសុខុមាលភាពក្នុងនាមជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជំរុញសមភាពយេនឌ័រនៅក្នុង និងតាម រយៈការអប់រំ។

## ៤.១ ហេតុអ្វីបានជាអភិក្រមដ៏ទូលំទូលាយមានសារៈសំខាន់?

ការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀន គឺជាឧបករណ៍ដ៏មានអនុភាព ប៉ុន្តែសម្ភារៈទាំងនោះមិនអាចសម្រេចបានសក្តានុពលពេញលេញដោយឯកឯងបានទេ។ ប្រសិនបើសិស្សបានរៀនខ្លឹមសារដែលប្រកបដោយសមធម៌យេនឌ័រនៅក្នុងមេរៀនមួយ ប៉ុន្តែបែរជាជួបប្រទះការផាត់ចេញពីសង្គម អំពើហិង្សា ឬផ្នត់គំនិតដែលផ្អែកលើយេនឌ័រ នៅកន្លែងផ្សេងទៀតក្នុងបរិស្ថានអប់រំ វានឹងធ្វើឱ្យអន្តរាយដល់ឱកាសធ្វើការផ្លាស់ប្តូរ។ ស្រដៀងគ្នានេះដែរ ប្រសិនបើអ្នកអប់រំត្រូវបានគេរំពឹងថានឹងបង្រៀនដោយប្រើប្រាស់សម្ភារៈបង្រៀន និងរៀនថ្មី ដោយគ្មានការគាំទ្រ គ្មានការបណ្តុះបណ្តាល ឬការតម្រង់ទិសនៅកម្រិតប្រព័ន្ធទេ នោះការអនុវត្តប្រាកដជានឹងចុះខ្សោយ (Marcus et al., 2024)។

ដូច្នេះ ការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀន នឹងមានប្រសិទ្ធភាពកាន់តែខ្លាំង នៅពេលដែលដាក់បញ្ចូលទៅក្នុងប្រព័ន្ធអប់រំដ៏ទូលំទូលាយ ដែលជួយគាំទ្រ និងពង្រឹងសមភាពយេនឌ័រ។ នេះមានន័យថាជាការទាញយកប្រយោជន៍ពីគ្រប់ផ្នែកទាំងអស់នៃប្រព័ន្ធអប់រំ និងគ្រប់ផ្នែកទាំងអស់នៃសាលារៀន (ដែលពេលខ្លះ ត្រូវបានគេហៅថា អភិក្រមទូទាំងសាលារៀន ឬ whole-school approach ) ដើម្បីដោះស្រាយបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ លើកកម្ពស់បទដ្ឋានដែលវិជ្ជមាន និងបញ្ជ្រាបការគោរព បរិយាបន្ន និងសមភាពយេនឌ័រ (Plan International et al., 2021)។ សម្ភារៈបង្រៀន និងរៀន គឺជាធាតុផ្សំគន្លឹះមួយនៃការងារនេះ ប៉ុន្តែគួរតែជាផ្នែកមួយនៃប្រព័ន្ធអេកូឡូស៊ីដ៏ទូលំទូលាយដែលប្តេជ្ញាសម្រេចបានបរិវត្តកម្ម។

## ៤.២ ចំណុចចាប់ផ្តើមសម្រាប់ការផ្លាស់ប្តូរបទដ្ឋានយេនឌ័រនៅក្នុង និងតាមរយៈការអប់រំ

តាមរយៈការទទួលស្គាល់សារៈសំខាន់នៃអភិក្រមគ្រប់ជ្រុងជ្រោយ គេចាំបាច់ត្រូវកំណត់រកចំណុចចាប់ផ្តើមជាច្រើនសម្រាប់ការដោះស្រាយបទដ្ឋានយេនឌ័រ និងការប្រតិបត្តិជាក់ស្តែងនូវការអនុវត្តដែលកាន់តែមានសមធម៌ និងបរិយាបន្ន។ ចំណុចចាប់ផ្តើមទាំងនោះរួមមានរបៀបដែលគោលនយោបាយ និងផែនការត្រូវបានតាក់តែងឡើង និងផ្តល់ហិរញ្ញប្បទាន របៀបដែលកម្មវិធីសិក្សាកំណត់ទម្រង់យេនឌ័រ និងអំណាច របៀបដែលគ្រូបង្រៀនត្រូវបានជ្រើសរើស ធ្វើការបណ្តុះបណ្តាល និងគាំទ្រ គរុកោសល្យដែលគ្រូអនុវត្តនៅក្នុងថ្នាក់រៀន ក៏ដូចជាខ្លឹមសារ និងរូបភាពដែលបង្ហាញនៅក្នុងសម្ភារៈបង្រៀន និងរៀន។ ការដឹកនាំ បទបញ្ជាផ្ទៃក្នុងសាលារៀន និងក្រមសីលធម៌ ប្រព័ន្ធទិន្នន័យ និងការតាមដាន និងវិធានការជំរុញការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍ ក៏ផ្តល់នូវចំណុចចាប់ផ្តើមជាក់ស្តែងផងដែរសម្រាប់ការផ្លាស់ប្តូរបទដ្ឋានយេនឌ័រទាំងឡាយរួមទាំងបទដ្ឋានយេនឌ័រដែលរឹតត្បិត អាកប្បកិរិយា និងអត្តសញ្ញាណរបស់កុមារា និងបុរស។

ជារួម ចំណុចចាប់ផ្តើមទាំងនេះអាចឱ្យតួអង្គអប់រំធ្វើសកម្មភាពនៅច្រើនកម្រិត ចាប់ពីការប្តេជ្ញាចិត្ត និងបែងចែកថវិកាពីកម្រិតខ្ពស់រហូតដល់ការអនុវត្តប្រចាំថ្ងៃនៅក្នុងថ្នាក់រៀន។នេះគឺមិនមែនដើម្បីបង្កើតគម្រោងយេនឌ័រដាច់ដោយឡែកផ្សេងទៀតនោះទេ ប៉ុន្តែជាការប្រេបាច់បញ្ចូលអភិក្រមបរិវត្តកម្មយេនឌ័រទៅក្នុងគោលនយោបាយ និងការអនុវត្តដែលមានស្រាប់។

**តារាងទី ៣** សង្ខេបឧទាហរណ៍នៃសកម្មភាពជាក់ស្តែងដែលក្រសួងពាក់ព័ន្ធ សាលារៀន និងដៃគូអាចអនុវត្តបាននៅចំណុចចាប់ផ្តើមផ្សេងៗ។ ចំណុចចាប់ផ្តើម និងសកម្មភាពដែលអមមកជាមួយ ទទួលបានព័ត៌មានដ៏មានប្រយោជន៍ពីការស្រាវជ្រាវស្តីពីការដកខ្លួនចេញពីការអប់រំរបស់កុមារានៅកម្ពុជា។ ការស្រាវជ្រាវនេះបានគូសបញ្ជាក់ពីកម្រងអនុសាសន៍នៅកម្រិតប្រព័ន្ធអប់រំ រួមមានការពង្រឹងអក្ខរកម្ម និងគណិតវិទ្យាថ្នាក់ដំបូងសម្រាប់កុមារា និងការរៀនសូត្រផ្នែកចិត្តសង្គម និងការជួយឱ្យពួកគេឆ្លងភូមិសិក្សាទៅកម្រិតមធ្យមសិក្សាបឋមភូមិការធានាថាគោលនយោបាយ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) និងប្រព័ន្ធតាមដាន ខិតខំតាមដាន និងឆ្លើយតបទៅនឹងភាពងាយរងគ្រោះថ្មីៗរបស់កុមារា ការពង្រីកថ្នាក់រៀនបំប៉ន ការណែនាំ និងរបៀបសិក្សាដែលមានភាពបត់បែន ការវិនិយោគលើអនុវិទ្យាល័យឱ្យមានបរិយាបន្ន និងផ្តល់ធនធានគ្រប់គ្រាន់ និងការជំរុញឱ្យចូលរួមក្នុងសកម្មភាពក្រៅកម្មវិធីសិក្សា ការផ្តល់ការប្រឹក្សា និងកម្មវិធីដែលលើកកម្ពស់ភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព ការសហការជាមួយឪពុក គ្រួសារ និងសហគមន៍ ដើម្បីដេញដោលបទដ្ឋានដែលបង្កគ្រោះថ្នាក់ ការអនុវត្តច្បាប់ស្តីពីការអប់រំជាកាតព្វកិច្ច និងពលកម្មកុមារ និងការពង្រីកគន្លងរៀនសូត្របែបបត់បែន និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលគួរឱ្យទុកចិត្ត ដើម្បីដាក់បញ្ចូលការគាំទ្រដល់កុមារាទៅក្នុងអភិក្រមបរិវត្តកម្មយេនឌ័រដ៏ទូលំទូលាយ ដែលផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សាគ្រប់រូប (UNESCO, 2026)។

*តារាងទី ៣. ឧទាហរណ៍នៃសកម្មភាពគាំទ្រដល់បរិវត្តកម្មយេនឌ័រ ដែលអាចអនុវត្តនៅចំណុចចាប់ផ្តើមផ្សេងៗក្នុងប្រព័ន្ធអប់រំ*

| ចំណុចចាប់ផ្តើម | ឧទាហរណ៍សកម្មភាព |
|---|---|
| គោលនយោបាយ ផែនការថវិកា | • ការអនុម័តគោលនយោបាយបរិយាបន្នដែលអនុញ្ញាត និងលើកទឹកចិត្តឱ្យសិស្សទាំងអស់ស្វែងយល់ពីមុខវិជ្ជា/សកម្មភាពទាំងអស់ ដោយមិនគិតពីយេនឌ័រ។<br>• ការដាក់បញ្ចូល ឬពង្រឹងគោលនយោបាយចូលរៀនឡើងវិញសម្រាប់សិស្ស ដែលមានផ្ទៃពោះ និងមានកូន និងគោលនយោបាយដែលការពារសិស្សពីការរៀបអាពាហ៍ពិពាហ៍វ័យក្មេង និងអំពើហិង្សាផ្អែកលើយេនឌ័រ (GBV)។<br>• ការប្រើប្រាស់ដំណើរការរៀបចំផែនការ និងថវិកាឆ្លើយតបយេនឌ័រដើម្បីបែងចែកធនធានប្រកបដោយសមធម៌ (ឧ. បង្គន់អនាម័យ មធ្យោបាយធ្វើដំណើរ អាហារូបករណ៍)។<br>• ការប្រមូល ការវិភាគ និងការប្រើប្រាស់ទិន្នន័យបែងចែកតាមភេទ ( និងកត្តាផ្សេងទៀត ប្រសិនបើអាច) ជាប្រព័ន្ធ ដើម្បីផ្តល់ព័ត៌មានដល់ការធ្វើផែនការ និងគណនេយ្យភាព។ |
| ការបណ្តុះបណ្តាលគ្រូ និងការគាំទ្រជាប្រចាំ | • ការជួយឱ្យគ្រូឆ្លុះបញ្ចាំងពីភាពលម្អៀងផ្ទាល់ខ្លួនរបស់គាត់ និងអភិវឌ្ឍវិធីសាស្ត្របង្រៀនដែលប្រកបដោយបរិយាបន្ន និងបរិវត្តកម្មយេនឌ័រ។<br>• ការដាក់បញ្ចូលគរុកោសល្យ និងខ្លឹមសារដែលគាំទ្រដល់បរិវត្តកម្មយេនឌ័រទៅក្នុងកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូមុនពេលចេញបង្រៀន។<br>• ការផ្តល់ការបណ្តុះបណ្តាលគ្រូក្នុងពេលកំពុងបង្រៀន(ធ្វើវិក្រិតការ)ការណែនាំ និងការជួយតាមដានបន្តជាប្រចាំ ដោយផ្តោតលើសមភាពយេនឌ័រ រួមទាំងភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព។<br>• ការបំពាក់បំប៉នគ្រូបង្រៀននូវឧបករណ៍អនុវត្តន៍ជាក់ស្តែង (ឧ. បញ្ជីត្រួតពិនិត្យ កិច្ចតែងការបង្រៀន សំណួរឆ្លុះបញ្ចាំង) ដើម្បីអនុវត្តអភិក្រមបរិវត្តកម្មយេនឌ័រនៅក្នុងការបង្រៀនប្រចាំថ្ងៃ។ |

| | |
|---|---|
| **គរុកោសល្យ** | • គ្រូបង្រៀនដែលប្រើប្រាស់យុទ្ធសាស្ត្របង្រៀនប្រកបដោយបរិយាបន្ន ដែលលើកទឹកចិត្ត និងអនុញ្ញាតឱ្យសិស្សទាំងអស់ចូលរួមដោយស្មើភាពគ្នា ហើយទន្ទឹមនឹងនោះជជែកដេញដោលការសន្មតផ្អែកលើយេនឌ័រចំពោះសមត្ថភាព ឬអាកប្បកិរិយា។<br>• ការផ្លាស់តួនាទី និងការទទួលខុសត្រូវក្នុងថ្នាក់រៀន (ឧ. ប្រធានក្រុម អ្នករាយការណ៍ អ្នកគ្រប់គ្រងសម្ភារៈ) ក្នុងចំណោមយេនឌ័រផ្សេងៗ ដើម្បីបញ្ចៀសកិច្ចការដែលជាផ្នត់គំនិតចាស់កម្រិល។<br>• ការរួមបញ្ចូលសកម្មភាពដែលមានចេតនាសម្ព័ន្ធច្បាស់លាស់ ដែលជួយសិស្សឱ្យយល់ដឹង ស្គាល់ និងដេញដោលបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់។ |
| **កម្មវិធីសិក្សា** | • ការបញ្ជ្រាបគោលបំណងសិក្សាឆ្លងកម្មវិធីសិក្សា ដែលស្របតាមវិស័យស្ដីពីសមភាពយេនឌ័រ និងភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយ សុខុមាលភាព នៅក្នុងមុខវិជ្ជានានា។<br>• ការរួមបញ្ចូលឱកាសដែលមានចេតនាសម្ព័ន្ធច្បាស់លាស់ សម្រាប់ឱ្យអ្នកសិក្សាវិភាគ និងពិភាក្សាអំពីបទដ្ឋានយេនឌ័រ អំណាច និងទំនាក់ទំនង។<br>• ខ្លឹមសារកម្មវិធីសិក្សាជាក់លាក់ ដែលរំលេចសមត្ថភាពស្មើគ្នា និងតួនាទីចម្រុះរបស់កុមារី និងកុមារា។<br>• ការកែសម្រួលក្របខ័ណ្ឌវាយតម្លៃ ដើម្បីផ្ដល់តម្លៃលើបំណិន និងឥរិយាបថដែលទាក់ទងនឹងសមភាព និងការគោរព។ |
| **សម្ភារៈបង្រៀន និងរៀន (TLMs)**<br>(សូមមើល ផ្នែកទី ៣) | • ការកំណត់សៀវភៅសិក្សា ដែលបង្ហាញកុមារា កុមារី បុរស និងស្ត្រី នៅក្នុងតួនាទី និងសកម្មភាពយ៉ាងទូលំទូលាយ។<br>• ការពិនិត្យ និងកែសម្រួលសម្ភារៈបង្រៀន និងរៀនដែលមានស្រាប់ ដើម្បីលុបបំបាត់ផ្នត់គំនិតយេនឌ័រ និងផ្ដល់ការបង្ហាញដែលផ្ទុយពីផ្នត់គំនិតយេនឌ័រ (ឧ. អ្នកវិទ្យាសាស្ត្រជាស្ត្រី អ្នកថែទាំជាបុរស)។<br>• ការបញ្ចូលរឿងរ៉ាវ រូបភាព និងឧទាហរណ៍ ដែលឆ្លុះបញ្ចាំងពីអត្តសញ្ញាណ និងតថភាពចម្រុះ (ឧ. ជនបទ/ទីប្រជុំជន ពិការភាព ទ្រព្យសម្បត្តិ) និងដេញដោលបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់។<br>• ការបញ្ចូលលំហាត់ ដែលជំរុញឱ្យសិស្សពិនិត្យមើលល្អិតល្អន់លើបទដ្ឋានយេនឌ័រ និងផលប៉ះពាល់របស់វា។ |

| | |
|---|---|
| ថ្នាក់ដឹកនាំ | • ការលើកកម្ពស់តុល្យភាពយេនឌ័រនៅក្នុងតំណែងអ្នកដឹកនាំ តួនាទីបុគ្គលិកជាន់ខ្ពស់ និងនៅក្នុងកម្លាំងពលកម្មទូទៅ។<br>• ការកំណត់ និងការតាមដានចំណុចដៅសម្រាប់ភាពជាតំណាងរបស់ស្ត្រីនៅក្នុងថ្នាក់ដឹកនាំកម្រិតសាលារៀននិងកម្រិតប្រព័ន្ធនិងការដោះស្រាយរបាំងរារាំងវឌ្ឍនភាពរបស់ស្ត្រី។<br>• ការធានាថា ថ្នាក់ដឹកនាំធ្វើជាគំរូសម្រាប់អាកប្បកិរិយាប្រកបដោយសមធម៌យេនឌ័រ និងបង្ហាញការមិនអត់ឱនដាច់ខាតចំពោះការរើសអើង និងអំពើហិង្សា។ |
| បរិយាកាសរៀនសូត្រ | • ការជំរុញវប្បធម៌សាលារៀនដែលសាទរភាពចម្រុះហើយសិស្សទាំងអស់មានអារម្មណ៍ថា ពួកគេជាផ្នែកមួយនៃសាលារៀន។<br>• ការកែទម្រង់គោលការណ៍វិន័យ ដើម្បីធានាការអនុវត្តវិន័យប្រកបដោយយុត្តិធម៌ និងសមធម៌ចំពោះមនុស្សគ្រប់យេនឌ័រ និងលុបបំបាត់ការដាក់ទណ្ឌកម្មលើរាងកាយ។<br>• ការពិនិត្យបទបញ្ជាផ្ទៃក្នុងសាលារៀន (ឧទាហរណ៍ ឯកសណ្ឋាន សក់ ការចូលរួមសកម្មភាពក្រៅកម្មវិធីសិក្សា) ដើម្បីធានាថា បទបញ្ជាទាំងនោះមិនពង្រឹងបទដ្ឋានយេនឌ័រដែលមានលក្ខណៈតឹងរ៉ឹងនិងរិតត្បិត។<br>• ការបង្កើត និងអនុវត្តតាមយន្តការរាយការណ៍ និងឆ្លើយតបយ៉ាងច្បាស់លាស់ និងរក្សាការសម្ងាត់ ចំពោះអំពើហិង្សាផ្អែកលើយេនឌ័រ និងការរកើងរំខាន។ |
| ការចូលរួមរបស់សហគមន៍ និងអ្នកថែទាំ | • ការលើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកថែទាំទាំងអស់ រួមទាំងឪពុក និងអាណាព្យាបាលជាបុរស នៅក្នុងកិច្ចប្រជុំអំពីការរៀនសូត្រ និងសុខុមាលភាពរបស់សិស្ស។<br>• ការរៀបចំកិច្ចសន្ទនាសហគមន៍ វេទិកាសាលារៀន-សហគមន៍ ឬវគ្គចូលរួមដោយមាតាបិតាសិស្សស្តីពីបទដ្ឋានយេនឌ័រ ការទប់ស្កាត់អំពើហិង្សា និងតម្លៃនៃការអប់រំរបស់កុមារី និងការអប់រំរបស់កុមារា។<br>• ការចាប់ដៃគូសហការជាមួយអ្នកដឹកនាំសាសនា អ្នកដឹកនាំប្រពៃណី ក្រុមយុវជន និងអង្គការសង្គមស៊ីវិល(CSOs) ដើម្បីលើកកម្ពស់បទដ្ឋានដែលវិជ្ជមាន និងប្រកបដោយសមធម៌យេនឌ័រនៅក្នុងសហគមន៍។<br>• ការប្រើប្រាស់ព្រឹត្តិការណ៍សាលារៀន វិទ្យុ បណ្តាញសង្គម ឬព្រឹត្តិបត្រព័ត៌មាន ដើម្បីចែករំលែករឿងរ៉ាវវិជ្ជមាន និងសារស្តីពីសមត្ថភាព និងសិទ្ធិស្មើគ្នារបស់កុមារី និងកុមារា។ |

| | |
|---|---|
| **ការតាមដាន ការវាយតម្លៃ និងការរៀនសូត្រ** | • ការប្រមូល ការវិភាគ និងការប្រើប្រាស់ទិន្នន័យបែងចែកតាមភេទ (ឧ. ការចុះឈ្មោះចូលរៀន វត្តមាន ការបញ្ចប់ការសិក្សា លទ្ធផលសិក្សា) ជាប្រព័ន្ធហើយក្នុងករណីដែលអាចធ្វើទៅបាន ត្រូវបែងចែកបន្ថែមទៀតទៅតាមកត្តាផ្សេងៗទៀត (ឧ. ទីតាំងភូមិសាស្ត្រ ពិការភាព និងស្ថានភាពសេដ្ឋកិច្ចសង្គម) ដើម្បីស្វែងយល់ថាតើសិស្សណាខ្លះដែលកំពុងត្រូវបានគេទុកចោល។<br>• ការកំណត់កម្រងសូចនាករបរិវត្តកម្មយេនឌ័រ (ឧ. អាកប្បកិរិយារបស់សិស្សចំពោះតួនាទីយេនឌ័រ និងអំពើហិង្សាផ្អែកលើយេនឌ័រ អារម្មណ៍យល់ថាមានសុវត្ថិភាព និងទទួលបានការយកចិត្តទុកដាក់ និងការចូលរួមប្រកបដោយសមធម៌នៅក្នុងថ្នាក់) និងដាក់បញ្ចូលសូចនាករទាំងនេះទៅក្នុងការតាមដានជាប្រចាំ (ឧ. ប្រព័ន្ធ EMIS) និងការរាយការណ៍របស់សាលារៀន។<br>• ការចាត់តាំង ឬគាំទ្រដល់ការស្រាវជ្រាវ ការតាមដាន និងការវាយតម្លៃចំគោលដៅដើម្បីប៉ាន់ប្រមាណប្រសិទ្ធភាពនៃអន្តរាគមន៍នានា និងពង្រឹងមូលដ្ឋានភស្តុតាងនៃចំណុចដែលដំណើរការល្អនៅក្នុងបរិបទប្រទេសកម្ពុជា រួមទាំងកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យសម្ភារៈបង្រៀន និងរៀនគាំទ្រដល់បរិវត្តកម្មយេនឌ័រ។ |

*ប្រភព ៖* អ្នកនិពន្ធ (យុទ្ធសាស្ត្រដែលទទួលបានព័ត៌មានពី FAWE, 2020; Plan International, 2018; UNGEI and Global Partnership for Education, 2020)

ប្រអប់ទី ១៣. ឯកសារធនធានសម្រាប់គម្រោង "ការលើករបាំងចេញ"

ធនធានជាសកលស្តីពីការលើករបាំងចេញដើម្បីគាំទ្រដល់ការចូលរួមក្នុងការអប់រំរបស់កុមារា ត្រូវបានអភិវឌ្ឍឡើងដោយអង្គការ Equimundo ក្រោមភាពជាដៃគូជាមួយអង្គការយូណេស្កូ និងសាកលវិទ្យាល័យ East Anglia ដើម្បីផ្តល់ជូនសាលារៀន គ្រូបង្រៀន និងសហគមន៍នូវមូលដ្ឋានគ្រឹះជាក់ស្តែងសម្រាប់ជំរុញការចូលរួមរបស់ក្រុមគ្រួសារ និងសិស្សានុសិស្សនៅក្នុងការងារដែលគាំទ្រដល់ភាពជោគជ័យក្នុងការសិក្សារបស់កុមារា ហើយទន្ទឹមនឹងនោះជំរុញគោលដៅសមភាពយេនឌ័រដ៏ទូលំទូលាយផងដែរ។ ឯកសារធនធានចំនួន**បួន**ត្រូវបានអភិវឌ្ឍ និងរៀបចំឡើងសម្រាប់ប្រើប្រាស់រួមគ្នា ដើម្បីបង្កើនផលជះជាអតិបរមា ៖

- **សៀវភៅណែនាំសម្រាប់ក្លឹបកុមារា** ៖ ធនធានដើម្បីគាំទ្រដល់អ្នកសម្របសម្រួលក្នុងការបង្កើត និងថែរក្សាក្លឹបកុមារា ជាចន្លោះសុវត្ថិភាព និងជំរុញការចូលរួម ដែលកុមារាអាចស្វែងយល់ពីភាពជាបុរសក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយសុខុមាលភាព កសាងបំណិនចិត្តសង្គម និងរួមចំណែកដល់សមភាពយេនឌ័រ និងភាពជោគជ័យក្នុងការសិក្សារបស់ពួកគេផ្ទាល់។
- **សៀវភៅណែនាំសម្រាប់អ្នកអប់រំ** ៖ ធនធានដើម្បីលើកកម្ពស់គរុកោសល្យដែលគាំទ្រដល់បរិវត្តកម្ម យេនឌ័រ និងបរិយាបន្ន ដោយបំពាក់បំប៉នអ្នកអប់រំនូវយុទ្ធសាស្ត្របង្កើតបរិស្ថានរៀនសូត្រប្រកបដោយសមធម៌ យេនឌ័រ ដែលគាំទ្រដល់ការរីកចម្រើន និងភាពជោគជ័យក្នុងការសិក្សារបស់កុមារា ព្រមទាំងសមភាព

យេនឌ័រ។

- **សៀវភៅណែនាំស្តីពីម៉ូឌុលក្នុងថ្នាក់រៀនសម្រាប់គ្រូបង្រៀន (In-Classroom Modules for Teachers) ៖** កិច្ចតែងការបង្រៀន និងសកម្មភាពដែលជួយដល់គ្រូក្នុងការណែនាំប្រធានបទសមភាពយេនឌ័រនៅក្នុងថ្នាក់រៀន ការលើកកម្ពស់ការយល់ដឹងរបស់សិស្ស ជាពិសេសសិស្សប្រុសអំពីវិសមភាពយេនឌ័រក្នុងសង្គម និងរបៀបដែលបញ្ហាទាំងនេះជះឥទ្ធិពលលើជីវិត និងជម្រើសរបស់ពួកគេ។
- **សៀវភៅណែនាំស្តីពីវគ្គចូលរួមដោយមាតាបិតាសិស្ស** ៖ សៀវភៅណែនាំសម្រាប់សាលារៀន និងភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញឱ្យមាតាបិតាចូលរួមក្នុងការពិភាក្សាអំពីតម្លៃនៃការអប់រំរបស់កុមារា និងរបៀបដែលសមភាពយេនឌ័រជះឥទ្ធិពលជាវិជ្ជមានលើសុខុមាលភាពរបស់ពួកគេ។

***ចំណុចសំខាន់ៗដែលត្រូវចងចាំ ៖***

- ការធ្វើបរិវត្តកម្មយេនឌ័រលើសម្ភារៈបង្រៀន និងរៀន (TLMs)មានប្រសិទ្ធភាពបំផុត នៅពេលដាក់បញ្ចូលទៅក្នុងការប្តេជ្ញាចិត្តដ៏ទូលំទូលាយចំពោះសមភាពយេនឌ័រនៅទូទាំងសាលារៀននិងក្នុងប្រព័ន្ធទាំងមូល។
- អភិក្រមបរិវត្តកម្មយេនឌ័រចំពោះការអប់រំតម្រូវឱ្យមានសកម្មភាពនៅទូទាំងចំណុចចាប់ផ្តើមជាច្រើននៅក្នុងប្រព័ន្ធអប់រំ (ឧទាហរណ៍៖ គោលនយោបាយ គរុកោសល្យ ការដឹកនាំ បរិយាកាសសាលារៀន និងប្រព័ន្ធទិន្នន័យ)។

# ឯកសារយោង


Bo, C., Kim, D., Khieu, C., Souk, S., Seang, L., Meng, H. and Rano, K. 2023. *Diagnostic tools for improving education policy planning. A case study on dropouts in early secondary schools in Cambodia*. London, KIX GPE EAP HUB.

Brussino, O. and McBrien, J. 2022. *Gender stereotypes in education: Policies and practices to address gender stereotyping across OECD education systems*. Paris, OECD Publishing.

Cahill, H., Dadvand, B., Suryani, A. and Farrelly, A. 2022. *Analysis of experience and outcomes of Connect with Respect violence prevention programme. A five country study*. Harare, UNESCO.

Cambodian Center for Human Rights. 2015. *LGBT bullying in Cambodia's schools*. Phnom Penh, Cambodian Center for Human Rights.

CDRI, UNESCO, University of East Anglia and Equimundo. 2025. *Study Report. Effectiveness of the Life Skills for Equality Project (LSEP)*. Phnom Penh, Cambodia Development Resource Institute.

Cheryan, S., Lombard, E.J., Hailu, F., Pham, L.N. H. and Weltzien, K. 2025. Global patterns of gender disparities in STEM and explanations for their persistence. *Nature Reviews Psychology*, Vol. 4, No. 1, pp. 6-19.

Commonwealth of Learning. 2019. *Guide to gender responsive learning materials development*. British Columbia, Commonwealth of Learning.

Connell, R.W. 2020. *Masculinities*. 2nd Edition. London, Routledge.

Cookson, T., Fuentes, L., Clara Kuss, M. and Bitterly, J. 2023. *Discussion Paper. Social norms, gender and development: A review of research and practice*. New York, UN Women.

Crawfurd, L., Saintis-Miller, C. and Todd, R. 2024. Sexist textbooks: Automated analysis of gender bias in 1,255 books from 34 countries. *PLOS ONE*, Vol. 19, No. 10, pp. e0310366.

Crenshaw, K. 2019. *On Intersectionality: Essential Writings*. New Press.

Denis, B. 2020. *Étude sur les manuels d'enseignement et d'apprentissage dans l'Union des Comores (1995-2020) [Study on teaching and learning materials in the Union of the Comoros (1995-2020)]. Paper commissioned for the 2020 GEM Report Gender Report, A New Generation: 25 years of efforts for gender equality in education*. Paris, UNESCO.

Dom, V. and Yi, G. 2018. Gender and subject choice: An empirical study on undergraduate students'

majors in Phnom Penh. *Asian Journal of Social Sciences & Humanities*, Vol. 7, No. 1, pp. 40-47.

Eck, M., Hencke, J., Kennedy, A., Meinck, S. and Sass, J. 2024. *Why boys may need more support in building their reading motivation, confidence, and engagement*. Paris, UNESCO.

FAWE. 2020. *Gender responsive pedagogy. A toolkit for teachers and schools*. Nairobi, Forum for African Women Educationalists.

Flynn, R.A. 2003. *Exploring the use of children's literature to affect the gender role expectations of fifth-grade students*. Masters Thesis, University of Southern Mississippi.

Global Partnership for Education. 2023. *Going further together: A partnership approach to gender equality*. Washington D.C., Global Partnership for Education.

Good, J.J., Woodzicka, J.A. and Wingfield, L. C. 2010. The effects of gender stereotypic and counter- stereotypic textbook images on science performance. *The Journal of Social Psychology*, Vol. 150, No. 2, pp. 132-147.

Haberland, N. 2015. The case for addressing gender and power in sexuality and HIV Education: A comprehensive review of evaluation studies. *International Perspectives on Sexual and Reproductive Health*, Vol. 41, No. 1, pp. 31.

Hawkins, I., Ratan, R., Blair, D. and Fordham, J. 2019. The effects of gender role stereotypes in digital learning games on motivation for STEM achievement. *Journal of Science Education and Technology*, Vol. 28, pp. 628-637.

Heilman, B., Barker, G. and Harrison, A. 2017. *The Man Box: A study on being a young man in the US, UK, and Mexico*. Washington D.C. and London, Equimundo and Unilever.

Huang, P. and Liu, X. 2024. Challenging gender stereotypes: Representations of gender through social interactions in English learning textbooks. *Humanities and Social Sciences Communications*, Vol. 11, No. 1, pp. 819.

Islam, K. and Asadullah, M.N. 2018. Gender stereotypes and education: A comparative content analysis of Malaysian, Indonesian, Pakistani and Bangladeshi school textbooks. *PLOS ONE*, Vol. 13, No. 1, pp. e0190807.

Jackson, S. and Gee, S. 2005. 'Look Janet', 'No you look John': Constructions of gender in early school reader illustrations across 50 years. *Gender and Education*, Vol. 17, No. 2, pp. 115-128.

Kennedy, E., Binder, G., Humphries-Waa, K., Tidhar, T., Cini, K., Comrie-Thomson, L., Vaughan, C., Francis, K., Scott, N., Wulan, N., Patton, G. and Azzopardi, P. 2020. Gender inequalities in health and wellbeing across the first two decades of life: An analysis of 40 low-income and middle-income countries in the Asia-Pacific region. *The Lancet Global Health*, Vol. 8, No. 12, pp. e1473-e1488.

Lameiras-Fernández, M., Martínez-Román, R., Carrera-Fernández, M.V. and Rodríguez-Castro, Y. 2021. Sex education in the spotlight: What is working? Systematic Review. *International Journal of Environmental Research and Public Health*, Vol. 18, No. 5, pp. 2555.

Leite, L., Yates, R., Strigelli, G.C., Han, J. Y., Chen-Charles, J., Rotaru, M. and Toska, E. 2025. Scoping review of social norms interventions to reduce violence and improve SRHR outcomes among adolescents and young people in sub-Saharan Africa. *Frontiers in Reproductive Health*, Vol. 7, pp. 1592696.

Makarova, E., Aeschlimann, B. and Herzog, W. 2019. The gender gap in STEM fields: The impact of the gender stereotype of math and science on secondary students' career aspirations. *Frontiers in Education*, Vol. 4.

Marcus, R. 2018. *Education and gender norm change*. London, ALiGN.

Marcus, R., D'Angelo, S. and Michalko, J. 2024. *Nurturing gender-equitable masculinities. Lessons for transforming norms through education systems*. London, ALiGN.

Merawi, T.M. 2020. *Technology for inclusion: Gender responsive teaching and learning materials development and revision in Ethiopia. Paper commissioned for the 2020 GEM Report Gender Report, A New Generation: 25 years of efforts for gender equality in education*. Paris, UNESCO.

Mmari, K., Gayles, J., Lundgren, R., Barker, K., Austrian, K., Levtov, R., Kato-Wallace, J., Van Reeuwijk, M., Richardson, L., Green, J., Kågestan, A. E. and Ramaiya, A. 2023. Implementing interventions to address gender and power inequalities in early adolescence: Utilizing a theory of change to assess conditions for success. *Journal of Adolescent Health*, Vol. 73, No. 1, pp. S5-S14.

Ministry of Education, Youth and Sports (MoEYS). 2026. *Khmer Grade 1*. Phnom Penh, Publishing and Distribution House.

______. 2025a. *Education Statistics and Indicators Pre-school and General Education for Public School 2024-2025*. Phnom Penh, Ministry of Education, Youth and Sport.

______. 2025b. *Education Strategic Plan 2024-2028. Second Edition*. Phnom Penh, Ministry of Education, Youth and Sport.

______. 2025c. Gender Mainstreaming Strategic Plan in Education 2025-2029. Phnom Penh, Ministry of Education, Youth and Sport.

______. 2025d. *Khmer Grade 2*. Phnom Penh, Publishing and Distribution House.

______. 2025e. *Mathematics Grade 2.* Phnom Penh, Publishing and Distribution House.

______. 2025f. *Mathematics Grade 1*. Phnom Penh, Publishing and Distribution House.

______. 2025g. *The education, youth and sport performance in the academic year 2023-2024 and goals for the academic year 2024-2025*. Phnom Penh, Ministry of Education, Youth and Sport.

______. 2022. *National Action Plan on School Health 2021-2030.* Phnom Penh, Ministry of Education, Youth and Sport.

______. 2019. *National Policy on School Health.* Phnom Penh, Ministry of Education, Youth and Sport.

______. 2018a. *National Policy on Inclusive Education*. Phnom Penh, Ministry of Education, Youth and Sport.

______. 2018b. *National Policy on Lifelong Learning*. Phnom Penh, Ministry of Education, Youth and Sport.

______. 2000. *Khmer Grade 5*. Phnom Penh, Publishing and Distribution House. Ministry of Women's Affair (MoWA).2006. Gender Terminology, Phnom Penh, Ministry of Women's

Affairs.

______. 2024. *Neary Rattanak Vi. Five-year strategic plan for promoting gender equality and empowering women and girls 2024-2028*. Phnom Penh, Ministry of Women's Affairs.

National Institute of Statistics. 2020. *Report of Cambodia Socio-Economic Survey 2019/20*. Phnom Penh, National Institute of Statistics, Ministry of Planning.

National Youth Development Council. 2022. *National Action Plan on Cambodia Youth Development (NAP-CYD) 2022-2026*. Phnom Penh. National Youth Development Council.

NGO Education Partnership. 2024. *Achieving Gender Equality in and through Education in Cambodia: Unpacking the Disparity in Learning Outcomes between Urban and Rural Girl Students*. Phnom Penh, NGO Education Partnership.

OECD. 2022. *PISA 2022 Results Factsheets Cambodia*. Paris, OECD.

______. 2019. Engaging with men and masculinities in fragile and conflict-affected settings. *OECD Development Policy Papers*, No. 17. Paris, OECD.

Olavarría, J., Celedón, R., Cervantes, J.C., Chávez, S., Contreras, S., Reveco, O. and Rojas, A. 2015. *Estudio de buenas prácticas en la reducción de las brechas de género en resultados SIMCE lectura iiº medio. [Study of best practices in reducing gender gaps in SIMCE results reading, 2nd year high school].* Santiago, Agencia de Calidad de la Educación, Universidad Academia de Humanismo Cristiano [Agency for Quality in Education, Academy of Christian Humanism University].

Olsson, M. and Martiny, S.E. 2018. Does exposure to counterstereotypical role models influence girls' and women's gender stereotypes and career choices? A review of social psychological research.

*Frontiers in Psychology*, Vol. 9, pp. 2264.

Oxfam. 2023. *Inclusive Language Guide*. Oxford, Oxfam International.

Phal, C., Davut, N., Sathya, C., and B. Chankoulika. 2024. *The reversal of gender gap in learning: why boys are falling behind in upper secondary schools*. Phnom Penh, Cambodia Development Resource Institute.

Phal, C., Muytieng, T. and Sorsesekha, N. 2023. *Gender gap reversal in learning and gender-responsive teaching in Cambodia*. CDRI working paper series, no. 141. Phnom Penh, CDRI, Cambodia Development Resource Institute.

Phorn, C. and Arsyad, S. 2022. Female and male Character Representation in English Textbooks of Cambodian Secondary Schools: A Sociolinguistic Analysis. *JET ADI BUANA*, Vol. 7, No. 02, pp. 143-155.

Plan International. 2018. *Gender Responsive Pedagogy Teacher Training Pack*. Toronto, Plan International Canada.

Plan International, Transform Education, UNGEI and UNICEF. 2021. *Gender Transformative Education*. New York, UNICEF.

Ragonese, C., Shand, T. and Barker, G. 2019. *Masculine norms and men's health. Making the*

*connections*. Washington D.C., Promundo-US.

Rainbow Community Kampuchea Organisation, Reproductive Health Association of Cambodia and Cambodian Center for Human Rights. 2022. *Sexual Orientation, Gender Identity and Expression and Sex Characteristics (SOGIESC) Rights and Sexual Reproductive Health and Rights (SRHR) in Cambodia*. Cambodian Center for Human Rights.

Royal Government of Cambodia. 2023. *Pentagonal Strategy Phase 1 for Growth, Employment, Equity, Efficiency and Sustainability: Building the Foundation Towards Realizing the Cambodia Vision 2050*.

Phnom Penh, Royal Government of Cambodia.

Royal Government of Cambodia. 2011. *National Policy on Youth Development*. Phnom Penh, Royal Government of Cambodia.

RTI International. 2015. *A guide for strengthening gender equality and inclusiveness in teaching and learning materials*. USAID.

Schmidthaler, E., Schmollmüller, M., Wimmer-Furian, P., Hörmann, C., Rottenhofer, M. and Sabitzer,

B. 2023. Exploring Gender Stereotypes and Sexism in Learning Apps: Insights from Austrian Secondary School Students. *American Journal of Applied Psychology*.

Serra, D. 2025. Role models in developing countries. In: Dasgupta, U. and Maitra, P. (eds), *Handbook of Experimental Development Economics.* Elgaronline, pp. 123-135.

Skipper, Y. and Fox, C. 2022. Boys will be boys: Young people's perceptions and experiences of

gender within education. *Pastoral Care in Education*, Vol. 40, No. 4, pp. 391-409.

Spinner, A., Tenenbaum, H.R. and Cameron, A.W. 2021. A school-based intervention to reduce gender-stereotyping. *School Psychology International*, Vol. 42, No. 4, pp. 422-449.

Stavropoulou, M. 2019. *Gender norms, health and wellbeing*. ALiGN, London.

Stromquist, N. 2007. *The Gender Socialization Process in Schools: A Cross-National Comparison. Background paper prepared for the Education for All Global Monitoring Report 2008 Education for All by 2015: will we make it?* Paris, UNESCO.

The Men's Project and Flood, M. 2024. *The Man Box 2024 Re-examining what it means to be a man in Australia*. Jesuit Social Services.

UN Women. n.d. *Gender Equality Glossary*. New York, UN Women. Accessed December 2025.

______. 2016. *Compendium of good-practices in training for gender equality*. New York, UN Women.

UN Women and UNPRPD. 2022. *Intersectionality Resource Guide and Toolkit. An intersectionality approach to leave no one behind*. New York, UN Women.

UNESCO. 2026. *Leave no child behind: boys' disengagement from education: Cambodia case study*. Paris, UNESCO.

______. 2022a. *Global education monitoring report 2022: gender report, deepening the debate on those still left behind*. Paris, UNESCO.

______. 2022b. *Glossary: Understanding concepts around gender equality and inclusion in education, tool 1*. Paris, UNESCO.

______. 2022c. *Leave no child behind: global report on boys' disengagement from education*. Paris, UNESCO.

______. 2022d. *#HerEducationOurFuture #BreakTheBias: Challenging gender bias and stereotypes in and through education; the latest facts on gender equality in education*. Paris, UNESCO.

______. 2020. *Global education monitoring report 2020: gender report, A new generation: 25 years of efforts for gender equality in education*. UNESCO.

______. 2019a. *Behind the numbers: Ending school violence and bullying*. Paris, UNESCO.

______. 2019b. *From access to empowerment: UNESCO strategy for gender equality in and through education 2019-2025*. UNESCO.

______. 2018a. *Achieving gender equality in education: Don't forget the boys*. Paris, UNESCO.

______. 2018b. *Mainstreaming gender equality in curricula and Teaching and Learning Materials*. Bangkok, UNESCO.

______. 2017a. *Cracking the code: Girls' and women's education in science, technology,*

*engineering*

*and mathematics (STEM)*. Paris, UNESCO.

______. 2017b. A guide for ensuring inclusion and equity in education. Paris: UNESCO .

______2015. *From insult to inclusion: Asia-Pacific report on school bullying, violence and discrimination on the basis of sexual orientation and gender identity*. UNESCO.

______. 2009. *Promoting gender equality through textbooks: A methodological guide*. Paris, UNESCO.

UNESCO Institute for Statistics. 2024. UIS Data Browser. Gross enrolment rate for tertiary education. Accessed December 2025.

UNESCO and UN Women. 2016. *Global guidance on addressing school-related gender-based violence*. Paris, UNESCO.

UNESCO-IBE. 2025. *Pedagogical guide for developing competencies in health and well-being education for training and teaching*. Geneva, UNESCO-IBE.

UNESCO-IBE. 2013. *Glossary of curriculum terminology*. Geneva, UNESCO-IBE.

UNESCO-IIEP. n.d. Glossary, International Institute for Educational Planning. Accessed December 2025.

UNFPA. 2023. *Harmful social and gender norms that drive gender-based violence in Cambodia*. Phnom Penh, UNFPA.

UNGEI. 2023. *Ending gender stereotypes in schools: Good practices, experiences and lessons learned*. New York, UNGEI.

UNGEI and Global Partnership for Education. 2020. *Guidance for developing gender-responsive education sector plans*. Washington D.C., GPE.

UNICEF. 2022. *Addressing gender inequalities from the early years of education*. New York, UNICEF.

______. 2020. *Why are boys leaving secondary school early in Cambodia?* Phnom Penh, UNICEF. UNICEF and SEAMEO Secretariat. 2025. *SEA-PLM 2024 Main Regional Report, Children's learning in 6*

*Southeast Asian Countries*, First Edition. Bangkok, SEA-PLM Regional Secretariat.

WHO. 2019. Engaging men, addressing harmful masculinities to improve sexual and reproductive health and rights. Accessed December 2025.

WHO. 2021. *Gender and health*. Accessed December 2025.

Wolter, I., Braun, E. and Hannover, B. 2015. Reading is for girls!? The negative impact of

preschool

teachers' traditional gender role attitudes on boys' reading related motivation and skills. *Frontiers in Psychology*, Vol. 6, p. 1267.

# ការលើករបាំងចេញ៖ ការអប់រំកុមារដើម្បីសមភាពយេនឌ័រ

## សៀវភៅណែនាំស្ដីពីសម្ភារៈបង្រៀន និងរៀនដែលគាំទ្រដល់ការធ្វើបរិវត្តកម្មយេនឌ័រនៅកម្ពុជា

សម្ភារៈបង្រៀននិងរៀន(TLMs)ដើរតួនាទីយ៉ាងសំខាន់ក្នុងការតម្រឹមតម្រង់ផ្នត់គំនិតអ្នកសិក្សាឱ្យយល់ពីខ្លួនឯងអ្នកដទៃ និងទីតាំងរបស់ពួកគេនៅក្នុងសង្គម។ នៅពេលរៀបចំឡើងប្រកបដោយអត្ថន័យ សម្ភារៈបង្រៀន និងរៀនគាំទ្រដល់ការសិក្សា ហើយទន្ទឹមនឹងនោះ រួមចំណែកលើកកម្ពស់សមភាពយេនឌ័រផងដែរ។

បន្ថែមពីលើការបំពេញគោលបំណងផ្នែកសិក្សាធិការ ឬមុខវិជ្ជារបស់ពួកគេ ឯកសារនេះត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់បទដ្ឋានយេនឌ័រដែលវិជ្ជមាន និងប្រកបដោយសុខុមាលភាព។ ការសម្រេចបាននូវចំណុចនេះទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ទៅលើរបៀបដែលយេនឌ័រត្រូវបានបង្ហាញតាមរយៈអត្ថបទ រូបភាព និងការរចនា រួមទាំងបទពិសោធន៍ដែល ឯកសារនេះបង្កើតឡើងដើម្បីឱ្យអ្នកសិក្សាអាចឆ្លុះបញ្ចាំង និងចោទសួរអំពីបទដ្ឋាននិងផ្នត់គំនិតអវិជ្ជមាននានា ជាជាងបន្តអនុវត្តតាមបទដ្ឋាន និងផ្នត់គំនិតទាំងនោះ។

សៀវភៅណែនាំនេះជួយដល់អ្នកដែលពាក់ព័ន្ធក្នុងការត្រួតពិនិត្យ កែសម្រួល ឬអភិវឌ្ឍសម្ភារៈអប់រំសម្រាប់អ្នកសិក្សាគ្រប់វ័យដើម្បីធានាថាសម្ភារៈទាំងនោះគាំទ្រដល់បរិវត្តកម្មយេនឌ័រ។ សៀវភៅណែនាំនេះផ្ដល់នូវមូលដ្ឋានហេតុផលរឹងមាំសម្រាប់ការធ្វើសកម្មភាពការណែនាំជាក់ស្ដែងជាជំហានៗ និងឧបករណ៍ងាយស្រួលប្រើប្រាស់ដើម្បីជួយសម្រួលដល់ដំណើរការនៃការវិភាគ កែសម្រួល ឬអភិវឌ្ឍសម្ភារៈប្រកបដោយបរិវត្តកម្មយេនឌ័រនៅក្នុងមុខវិជ្ជានានា ៕


**សូមទំនាក់ទំនងតាម៖**

phnompenh@unesco.org

www.unesco.org/en/gender-equality/education/boys
www.gpekix.org/project/lifting-barriers-educated-boys-gender-equality

**ការិយាល័យអង្គការយូណេស្កូ ប្រចាំនៅទីក្រុងភ្នំពេញ**

ផ្ទះលេខ ៣៨ មហាវិថីសម្ដេចសុធារស
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Phnom Penh 12206
Cambodia



ក្រោមការគាំទ្រពី៖